**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royal de droit et des Sciences Economiques**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# នីតិវិធីនៃការលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ផល្លា ពណ៌**

**លន់ រ៉េនធីតា**

សាស្ត្រាចារ្យណែនាំ

លោក **ភខ ស៊ីផាន់ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **លន់ រ៉េនធីតា** និង **ផល្លា ពណ៌** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២២ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រឆ្នាំសិក្សា២០១៨ ដល់ឆ្នាំសិក្សា២០២២។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកឪពុកអ្នកម្ដាយ ជាទីគោរពស្រលាញ់នៃកូនដែលបានផ្ដល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្ដីមេត្តាករុណា និង ផ្ដល់ក្ដីស្រលាញ់តាំងពីតូចរហូតធំពេញវ័យហើយរូបលោកបានលះបង់គ្រប់បែបយ៉ាងទាំងកម្លាំងកាយ កម្លាំងចិត្ត និង ថវិកា ដើម្បីឲ្យរូបកូនបានសិក្សារៀនសូត្រព្រមទាំងខិតខំអប់រំផ្ដល់ដំបូន្មានប្រៀនប្រដៅឲ្យរូបកូនដើរផ្លូវល្អមិនឲប្រព្រឹត្ត អំពើណាដែលសង្គមស្អប់ខ្ពើមដោយឲ្យកូនប្រតិបត្តិតែអំពើសុច្ចរឹតទៀងត្រង់ព្រមទាំងបានជំរុញលើកទឹកចិត្តដល់រូបកូនក្នុងការសិក្សារៀនសូត្រ និង តម្រង់ទិសកូនឲ្យក្លាយជាពលរដ្ឋល្អក្នុងសង្គម។ ដោយការយកចិត្តទុកដាក់ គឺជាថ្ងៃដែលកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្របានជោគជ័យហើយមានចំណេះដឹងខ្លះសម្រាប់ធ្វើជាទុនក្នុងការរស់នៅ ។

ទន្ទឹមជាមួយគ្នានេះដែរ យើងទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** ដែលលោកជាអ្នកគ្រប់គ្រងនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ហើយលោកបានផ្ដល់កន្លែងសិក្សាដល់ យើងខ្ញុំទាំងពីរបានសិក្សារហូតសម្រេចលទ្ធផលបង្កើតស្នាដៃនេះឡើង។ ជាងនេះទៅទៀតសូមថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យ កង ស៊ីផាន់ណារ៉ា** ដែលជាសាស្ត្រាចារ្យណែនាំយើងខ្ញុំដែលបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ធ្វើការបង្ហាត់បង្ហាញអស់ពីកម្លាំងចិត្ត កម្លាំងកាយ និង ណែនាំ កែតម្រូវ ផ្ដល់នូវចំណេះដឹងយ៉ាងច្រើនក៏ដូចជាផ្ដល់ជាអានុសាសន៍ និង ប្រាប់ទិសដៅឲ្យយើងខ្ញុំក្នុងការបង្កើតកិច្ចការស្រាវជ្រាវមួយនេះបានជោគជ័យ។

ម៉្យាងទៀតយើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណ និង ដឹងគុណចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំបង្ហាត់បង្រៀន អស់ពីកម្លាំងកាយ កម្លាំងចិត្ត និងផ្ដល់ចំណេះដឹងយ៉ាងច្រើន និង ពិតប្រាកដដល់យើងខ្ញុំទាំងពីរឲ្យឈានដល់ការបង្កើតស្នាដៃនេះឡើង។

មួយវិញទៀត សូមថ្លែងអំណរគុណដល់បងប្អូននិស្សិតច្បាប់មិត្តភក្តិទាំងអស់ដែលបានជួយជ្រោមជ្រែងលើកទឹកចិត្ត ការផ្ដល់មតិយោបលល្អៗជាច្រើន និង ការចែករំលែកបទពិសោធន៍ល្អៗ។

ចុងបញ្ចប់នេះ យើងខ្ញុំទាំងពីរសូមអរគុណដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកក្នុងការថែរក្សាការពារនិងប្រសិទ្ធពរជ័យជូនដល់លោកទាំងអស់ជួបតែសេចក្ដីសុខចម្រើន សុខភាពល្អ អាយុយឺនយូរ និង ទទួលបានជោគជ័យគ្រប់ភារៈកិច្ច និងជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំកន្លងមក និង បានសិក្សាលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និង ផ្នែកនីតិសាធារណៈរួចមក យើងខ្ញុំទាំងពីរទទួលបានចំណេះដឹងទូលំទូលាយលើ មុខវិជ្ជាទាំងអស់នោះក្រោមការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់មកដល់យើងខ្ញុំ។ ដោយការជ្រោមជ្រែង និង ការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្តទាំងអស់នេះហើយ ទើបធ្វើឲ្យយើងខ្ញុំអាចឈានមកដល់ការចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ ការរៀបចំសរសេរសារណានេះឡើងក្នុងគោលដៅដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២២ និង ដើម្បីចូលរួមចំណែកនៅក្នុងសង្គម។ ការសរសេរសារណាត្រូវតម្រូវឲ្យយើងមានសមត្ថភាព និង ចំណេះដឹងខ្ពស់ក្នុងការចងក្រងវាឡើងមកព្រោះថាការចងក្រងសារណាមួយឡើងមក យើងត្រូវជួបប្រទះ នឹង ការលំបាកជាច្រើនទើបយើងអាចទទួលបាននូវលទ្ធផលល្អ។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងទៅនឹងផ្នែកឯកជនដែលមានចំណងជើងថា **"នីតិវិធីនៃការលែងលះ"**។ ការជ្រើសរើសប្រធានបទនេះឡើងមកគឺ ដើម្បីឲ្យបុគ្គលគ្រប់រូបយល់ដឹងកាន់តែច្បាស់អំពីបែបបទនៃ នីតិវិធីនៃការលែងលះដែលមានលក្ខណៈស្របទៅតាមច្បាប់ដែលបានកំណត់មិនតែប៉ុណ្ណោះគឺ ឲ្យបុគ្គលគ្រប់រូបដែលមានបញ្ហាចំណងអាពាហ៍ពិពាហ៍ដោយមានភាពរកាំរកូសមានភាពមិនចុះសម្រុងជាមួយគ្រួសារហើយចង់ផ្តាច់ ចំណងអាពាហ៍ពិពាហ៍នោះឲ្យជ្រាបកាន់តែច្បាស់ពីនីតិវិធីនៃការលែងលះការបែងចែកទ្រព្យសម្បត្តិការផ្តល់អាហារកាព្វកិច្ចជាដើម។ នីតិវិធីនៃការលែងលះត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារដែលប្រកាសអោយប្រើនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដោយអនុក្រឹត្យលេខ៥៦។ ប៉ុន្តែក្នុងពេលបច្ចុប្បន្នច្បាប់នេះត្រូវបាននិរាករណ៍ចោលទៅហើយដោយបានជំនួសនូវក្រមរដ្ឋប្បវេណីឆ្នាំ២០០៧វិញ។

យើងខ្ញុំសង្ឃឹមថាសារណានេះនឹងអាចជាជំនួយការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និង ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលចង់ស្វែងយល់បន្ថែមទាក់ទង នឹងនីតិវិធីនៃការលែងលះដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ហើយ និង ទុកជាស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយដើម្បីសិក្សាបន្ថែមឲ្យកាន់តែច្បាស់អំពីនីតិវិធីនៃការលែងលះក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់ចំណុចខ្វះខាតមួយចំនួនក៏ដូចជា ពាក្យពេចន៍ខ្លឹមសារអត្ថន័យ ឬ អក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយអចេតនា ហើយក្រុមយើងខ្ញុំ និង ទទួលស្វាគមន៍ជានិច្ចរាល់ការរិះគន់ក្នុងអត្ថន័យស្ថាបនាជាមួយ នឹងគំនិតល្អៗរបស់មិត្តអ្នកអានទាំងអស់ ដើម្បីធ្វើការកែលំអរឲ្យល្អប្រសើរជាងមុន។

# មាតិកា

ទំព័រ

## ជំពូកទី១

## មូលហេតុដែលនាំឲ្យមានបណ្ដឹងលែងលះ

**សេចក្ដីផ្ដើម** ........................................................................................................១

១.១. ការលែងលះដោយមានការព្រមព្រៀង........................................................................... ៧

១.២. ការលែងលះដោយគ្មានការព្រមព្រៀង ...........................................................................៨

១.២.១. មូលហេតុទូទៅក្នុងគ្រួសារដែលនាំឲ្យមានការលែងលះ ..............................................៨

១.២.២. មូលហេតុទូទៅនៅក្នុងសង្គមដែលនាំឲ្យមានការលែងលះ.......................................... ១១

១.២.៣. មូលហេតុនៃការលែងលះដែលមានចែងក្នុងច្បាប់ .................................................... ១២

១.៣. ស្ថានភាពអាពាហ៍ពិពាហ៍ ........................................................................................ ១៥

១.៣.១. មានសំបុត្រអាពាហ៍ពិពាហ៍ .................................................................................. ១៦

១.៣.២. គ្មានសំបុត្រអាពាហ៍ពិពាហ៍ .................................................................................. ១៨

## ជំពូកទី២

## នីតិវិធីក្នុងការដាក់ពាក្យបណ្ដឹងរបស់សហព័ទ្ធ

២.១. ការដាក់បណ្ដឹងទៅអាជ្ញាធរដែនដី .............................................................................. ១៩

២.១.១.ការសម្របសម្រួលនៅមូលដ្ឋាន .............................................................................. ២៥

២.១.២. ការចេញសេចក្ដីសម្រេច ........................................................................................២៧

២.២. ការបញ្ជូនសំណុំរឿងទៅតុលាការ ................................................................................ ៣០

២.២.១. ករណីមានសំបុត្រអាពាហ៍ពិពាហ៍ និងមិនមានការស្រុះស្រួលគ្នា .................................. ៣០

២.៣.ការដាក់បណ្ដឹងទៅតុលាការ.........................................................................................៣២

## ជំពូកទី ៣

## ដំណើរការនៃនីតិវិធីលែងលះ


៣.១. តុលាការមានសមត្ថកិច្ច ........ ៣៥

៣.២. ការដាក់ពាក្យបណ្តឹង ........ ៣៦

៣.៣.ការត្រួតពិនិត្យបណ្តឹង ........ ៣៦

៣.៤.ការផ្សះផ្សារ ........ ៣៦

  ៣.៤.១. ការផ្សះផ្សារដោយតុលាការ ........ ៣៦

  ៣.៤.២. ការហាមឃាត់ការផ្សះផ្សារក្នុងករណីអំពើហិង្សា ក្នុងគ្រួសារធ្ងន់ធ្ងរ ........ ៣៧

៣.៥.ការត្រៀមទាញហេតុផល ........ ៣៧


## ជំពូកទី ៤

## ដំណាក់ការជំនុំជម្រះ


៤.១. ការទាញហេតុផលផ្ទាល់មាត់ ........ ៣៨

៤.២. ការចេញសាលក្រម ........ ៤០

  ៤.២.១. ការចេញសាលក្រមកំបាំងមុខ ........ ៤០

  ៤.២.២. ការចេញសាលក្រមចំពោះមុខ ........ ៤១

៤.៣. អានុភាពនៃការលែងលះ ........ ៤២

  ៤.៣.១. អានុភាពចំពោះសហព័ន្ធ ........ ៤២

  ៤.៣.២. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ ........ ៤៣

  ៤.៣.៣. អានុភាពចំពោះកូន ........ ៤៥


## សេចក្តីសន្និដ្ឋាន និង អនុសាសន៍


**សេចក្តីសន្និដ្ឋាន** ........ ៤៨

**អនុសាសន៍** ........ ៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅក្នុងសកលលោកជាធម្មជាតិជាអ្នកបង្កើតឲ្យមានមនុស្សប្រុស និង មនុស្សស្រី ហើយមនុស្សប្រុស និង មនុស្សស្រីនេះទៀតស្របពេលដែលមានវ័យកម្លោះត្រូវមានតួនាទីបង្កើតគ្រួសារជាមួយគ្នា ដើម្បីបន្តពូជពង្ស វង្សត្រកូលដោយបង្កើតឲ្យមានកូនចៅជំនាន់ក្រោយបន្តទៅទៀតក្នុងសង្គម។ ហើយអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយដែលធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ដែលប្តេជ្ញាថារួមមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ហើយដែលមិនអាចរំលាយទៅបានតាមទំនើងចិត្តរបស់ខ្លួន។ ហើយក៏មិនអាចរំលាយតាមទំនើងចិត្តបានដែលពីព្រោះតែបន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ប្តី និង ប្រពន្ធ មានចំណងគតិយុត្តជាច្រើនកើតឡើងរវាងគ្នាជាអាទិ៍ទំនាក់ទំនងនៃឋានៈបុគ្គល និង ទំនាក់ទំនងទ្រព្យសម្បត្តិ។ ការលែងលះរមែងកើតមានឡើងនៅពេលដែលគូស្វាមីភរិយាមិនមានឆន្ទៈរួមរស់ជាមួយគ្នាជាបន្តទៀត។ វាកើតមានឡើងក្នុងរូបភាពពីរគឺ ការលែងលះដោយមានការទាមទារពីភាគីតែម្ខាង(ឯកតោភាគី) និង ការលែងលះដោយការព្រមព្រៀងរបស់ភាគីទាំងសងខាង។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ច្បាប់ក៏មិនតម្រូវឱ្យបុគ្គលត្រូវតែស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍អស់មួយជីវិតឡើយមានន័យថា ប្រសិនបើប្តីប្រពន្ធមានវិវាទក្នុងគ្រួសារហើយគ្មានសង្ឃឹមថា នឹងអាចស្តារស្ថានភាពប្រក្រតីឡើងវិញ ឬភាគីទាំងពីរអស់មនោសញ្ចេតនារស់នៅជាមួយគ្នាជាប្តីប្រពន្ធពួកគេអាចរំលាយចំណងអាពាហ៍ពិពាហ៍របស់ខ្លួនចោលទៅវិញដោយប្រើវិធីនៃការលែងលះតាមផ្លូវតុលាការ។ ក្នុងស្មារតីរបស់ច្បាប់ការលែងលះតាមផ្លូវតុលាការអាចធ្វើឡើងក្រោមរូបភាពពីរគឺ ការលែងលះដោយការស្នើសុំរបស់ភាគីប្តីឬប្រពន្ធ និង ការលែងលះដោយការព្រមព្រៀងរបស់ប្តីនិងប្រពន្ធទាំងពីរ។ ជាទូទៅការលែងលះដោយការស្នើសុំរបស់ភាគីណាម្ខាងភាគីនោះដាច់ខាតត្រូវតែមានហេតុផលច្បាស់លាស់ ឬដែលបានកំណត់នៅក្នុងច្បាប់ពាក់ព័ន្ធនឹងកំហុសរបស់សហព័ទ្ធហើយនីតិវិធីនៃការដោះស្រាយត្រូវអនុទ្បោមតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលជាគោលចម្បង។ ចំណែកឯការលែងលះដោយការព្រមព្រៀងភាពចាំបាច់នៃមូលហេតុមិនត្រូវបានតម្រូវនោះទេ ពោលឱ្យតែប្តី និង ប្រពន្ធបង្ហាញពីឆន្ទៈស្ម័គ្រចិត្តលែងលះគ្នាគឺ អាចដាក់ពាក្យសុំទៅតុលាការបានហើយដំណើរការនៃនីតិវិធីដោះស្រាយត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

ក្នុងអំឡុងពេលនៃការរំលាយចំណងអាពាហ៍ពិពាហ៍ការលំបាកផ្សេងៗ អាចនឹងកើតឡើងដែលមានទាំងការខ្វែងគំនិតគ្នារវាងប្តីប្រពន្ធ និងកង្វះឯកសារចាំបាច់។ ដើម្បីឱ្យការលែងលះឆ្លងកាត់យ៉ាងឆាប់រហ័សនិងងាយស្រួលតាមដែលអាចធ្វើទៅបានអ្នកត្រូវតែចងចាំពីតម្រូវការនៃច្បាប់តាំងពីដំបូង ។ លិខិតឆ្លងដែនរបស់ប្តី

ប្រពន្ធទាំងពីរ (ប្រសិនបើមានភាគីខាងជាជនជាតិបរទេស) ពាក្យសុំលែងលះនៅការិយាល័យចុះឈ្មោះសេចក្តីអះអាងនៃការប្តឹងទៅតុលាការ នឹងច្បាប់ចម្លងរបស់ខ្លួនសំបុត្រអាពាហ៍ពិពាហ៍ (ច្បាប់ដើមនិងច្បាប់ចម្លង) សំបុត្រកំណើតរបស់កុមារ (ច្បាប់ដើមនិងច្បាប់ចម្លង) បង្កាន់ដៃបង់ប្រាក់នៃ កាតព្វកិច្ចរដ្ឋវិញ្ញាបនប័ត្រប្រាក់ឈ្នួលរបស់ប្តីប្រពន្ធ(បើចាំបាច់) សារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលទទួលបានក្នុងអាពាហ៍ពិពាហ៍ (បើចាំបាច់) ច្បាប់ថតចំលងកិច្ចសន្យាអាពាហ៍ពិពាហ៍ (បើមាន) ច្បាប់ចំលងនៃកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរស្តីពីការថែទាំកុមារនិងការបែងចែកទ្រព្យសម្បត្តិ (បើមាន) និងរបាយការណ៍វេជ្ជសាស្ត្រស្តីពីការទទួលស្គាល់ប្តីឬប្រពន្ធថា អសមត្ថភាពស្របច្បាប់ (ប្រសិនបើមាន)ដីការបស់តុលាការស្តីពីការទទួលស្គាល់ប្តីឬប្រពន្ធដែលបានបាត់ខ្លួន (ប្រសិនបើមាន) ដីការបស់តុលាការលើពាក្យសម្រាប់សហព័ទ្ធក្នុងកន្លែងដែលដកហូតសេរីភាព (បើមាន) ។

អាស្រ័យហេតុនេះហើយទើបក្រុមយើងខ្ញុំបានលើកយកប្រធានបទដែលទាក់ទងទៅនឹង **"នីតិវិធីនៃការលែងលះ"** នេះយកមកបកស្រាយ។ ដោយសារប្រធានបទនេះអាចជួយកែប្រែរាល់ការអនុវត្តដែលមិនល្អមួយចំនួន ដើម្បីចែករំលែកឲមហាជនទាំងអស់អោយយល់ដឹងនឹងស្វែងយល់ឲកាន់តែច្បាស់ថែមទៀត ។

## ២.ចំណោទបញ្ហា

នៅពេលមានវិវាទអាពាហ៍ពិពាហ៍កើតឡើង តើមានមូលហេតុអ្វីខ្លះដែលនាំឲ្យមានការលែងលះ? ហើយស្ថាប័នណាខ្លះ ដែលមានសមត្ថកិច្ចដោះស្រាយនឹងមាននីតិវិធីក្នុងការដោះស្រាយប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ ដើម្បីឲ្យការលែងលះនោះឲ្យមានអានុភាពគតិយុត្ត?

## ៣. គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ

គោលបំណងនៃប្រធានបទ គឺដើម្បីចង់ឲ្យប្រជាពលរដ្ឋយល់ដឹងអំពីដំណើរការនីតិវិធីនៃការលែងលះក្នុងប្រទេសកម្ពុជាហើយគេប្រព្រឹត្តតាមរបៀបណាខ្លះ និង ស្របច្បាប់បានកំណត់។ ម៉្យាងវិញទៀតយើងចង់ឱ្យអាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីភារកិច្ចទាក់ទងទៅនឹងផ្នែកនេះ អាចអនុវត្តការងារឲ្យបានកាន់តែម៉ត់ចត់ជាងនឹងហើយយកចិត្តទុកដាក់ចំពោះការងារ ដើម្បីផ្តល់ភាពងាយស្រួល នឹងបង្កើនទំនុកចិត្តដល់ប្រជាពលរដ្ឋដែលមានបញ្ហាទាំងអស់នោះ។ ត្រូវតែមានការចូលរួមការអនុវត្តពីស្ថាប័នដែលពាក់ព័ន្ធ នឹងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ដែលជារឿងដែលចាំបាច់បំផុត ដើម្បីឲសង្គមមាន ការអភិវឌ្ឍន៍ និង រីកចម្រើនទៅមុខខ្លាំង។ ដូចនេះអាជ្ញាធរដែលមានភារកិច្ចទាក់ទង នឹងផ្នែកនេះមិនត្រូវឲ្យមានការធ្វេសប្រហែសចំពោះការងាររបស់ខ្លួនឡើយ។ ការរួមគ្នាអនុវត្តច្បាប់អោយបានត្រឹមត្រូវទាំងអាជ្ញាធរនឹងទាំងប្រជាពលរដ្ឋ គឺជាចំណែកមួយដ៏សំខាន់បំផុត

ដើម្បីឲ្យប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាយើងមានភាពរឹងមាំហើយ នឹងមានភាពរីកចំរើនទៅមុខយ៉ាងឆាប់រហ័ស។

សារៈប្រយោជន៍នៃប្រធានបទនេះ គឺដើម្បីឲ្យមហាជនក៏ដូចជាសិស្សានុសិស្ស និង និស្សិតបញ្ញវន្តទាំងអស់ឲ្យបានយល់ដឹងកាន់តែច្បាស់អំពីនីតិវិធីនៃការលែងលះ នៅក្នុងប្រទេសកម្ពុជាមួយវិញទៀតអោយមានលក្ខណៈស្របទៅតាម នឹងច្បាប់របស់ប្រទេសកម្ពុជាយើងនៅពេលមានវិវាទអាពាហ៍ពិពាហ៍កើតឡើងយើងមិនដឹងថាត្រូវទៅរកស្ថាប័នណាមួយអោយជួយដោះស្រាយ យើងមិនដឹងពីបែបបទក្នុងការដោះស្រាយបញ្ហាជាដើម ។

ជាងនេះទៅទៀតការរៀបចំ និង ចងក្រងប្រធានបទមួយនេះដើម្បីចូលរួមក្នុងចំណែកអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឲកាន់តែមានភាពរីកចម្រើនប្រសើរឡើង។

## ៤. វិធីសាស្ត្រស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទខាងលើនេះយើងខ្ញុំបានខិតខំស្រាវជ្រាវដើម្បីប្រមូលនូវឯកសារមួយចំនួន និង ច្បាប់ពាក់ព័ន្ធនៃការស្រាវជ្រាវតាមបណ្តាញអ៊ីនធឺណេតរួមទាំងចំណេះដឹងដែលទទួលបានពីលោកគ្រូ អ្នកគ្រូ ដែលជាសាស្ត្រាចារ្យដើម្បីធ្វើការចងក្រងបង្កើតស្នាដៃនេះឡើង ។

ប្រធានបទខាងលើនេះ មានដែនកំណត់ស្ថិតក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទង នឹងឋានៈបុគ្គល ច្បាប់ស្តីពីបណ្តឹងវិវាទគ្រួសារ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង នឹងអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន។ ប្រធានបទស្តីពីនីតិវិធីនៃការលែងលះនេះមានវិសាលភាពគ្រប់ដណ្តប់ទៅលើផ្នែកនៃ នីតិអាពាហ៍អាពាហ៍ និង គ្រួសារក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

## ៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ "នីតិវិធីនៃការលែងលះ" យើងខ្ញុំបានធ្វើការចែកជា៤ជំពូកសំខាន់ៗមានដូចខាងក្រោម ៖

ជំពូកទី១ មូលហេតុដែលនាំឲ្យមានបណ្តឹងលែងលះ

១.១ ការលែងលះដោយមានការព្រមព្រៀង

១.២ ការលែងលះដោយគ្មានការព្រមព្រៀង

១.៣ ស្ថានភាពអាពាហ៍ពិពាហ៍

ជំពូកទី២ នីតិវិធីក្នុងការដាក់ពាក្យបណ្តឹងរបស់សហព័ទ្ធ

២.១ ការដាក់បណ្តឹងទៅអាជ្ញាធរដែនដី

២.២ ការបញ្ជូនសំណុំរឿងទៅតុលាការ

២.៣ ការដាក់បណ្តឹងទៅតុលាការ

ជំពូកទី៣ ដំណើរការនៃនីតិវិធីលែងលះ

៣.១ តុលាការមានសមត្ថកិច្ច

៣.២ ការដាក់ពាក្យបណ្តឹង

៣.៣ ការត្រួតពិនិត្យបណ្តឹង

៣.៤ ការផ្សះផ្សារ

៣.៥ ការត្រៀមទាញហេតុផល

ជំពូកទី៤ ដំណាក់ការជំនុំជម្រះ

៤.១ ការទាញហេតុផលផ្ទាល់មាត់

៤.២ ការចេញសាលក្រម

៤.៣ អានុភាពនៃការលែងលះ

# ជំពូកទី១

# មូលហេតុដែលនាំឲ្យមាន
# បណ្ដឹងលែងលះ

# ជំពូកទី១
# មូលហេតុដែលនាំឲ្យមានបណ្តឹងលែងលះ

**សញ្ញាណនៃការលែងលះ** ការរៀបអាពាហ៍ពិពាហ៍ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលមាននៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ អាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាកិច្ចសន្យាឱឡារិកមួយដែលធ្វើឡើងដោយគូស្រករពីរនាក់បុរស និង នារីហើយប្តេជ្ញាថា នឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ហើយមិនអាចរំលាយបានទៅបានតាមទំនើងចិត្តរបស់ខ្លួន[1]។ ដោយហេតុថាកិច្ចសន្យានេះជាកិច្ចសន្យាឱឡារិកអាពាហ៍ពិពាហ៍ នឹងមានអានុភាពពេលគ្រប់លក្ខណៈច្បាប់លុះត្រាតែអាពាហ៍ពិពាហ៍ស្របទៅតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ជាធរមាន។ ក្នុងន័យនេះអាពាហ៍ពិពាហ៍មិនមែនត្រឹមជាការបំពេញតួនាទីតាមក្រឹត្យក្រមច្បាប់ និង បទបញ្ញត្តិប៉ុណ្ណោះទេប៉ុន្តែក៏តាមក្រឹត្យក្រមធម្មជាតិផងដែរ។ គួរបញ្ជាក់ផងដែរថា បុរស និង នារី មានសេរីភាពពេញលេញក្នុងការជ្រើសរើសគូស្រករក្នុងការសាងគ្រួសាររួមរស់សុខទុក្ខនឹងគ្នា និង ជាមួយកូនចៅរបស់ខ្លួន។ ប៉ុន្តែចំណងអាពាហ៍ពិពាហ៍បែរជាជួបបញ្ហាល្អក់ក្រករដោយសារការរស់នៅមិនចុះសម្រុង និងគ្នា ដោយសារហេតុផលច្រើនយ៉ាងដូចជា ទស្សនទាន ខ្វែងគំនិតគ្នា ការប្រើប្រាស់ហិង្សា ការជេរប្រមាថជាដើមដែលអាចឈានទៅរកការចែកផ្លូវគ្នាតាមរយៈការលែងលះ។ ដូច្នេះមានតែតុលាការទេដែលអាចសម្រេចរឿងលែងលះបាន ។

**ការលែងលះ** គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធដែលបានរៀបការពេញលក្ខណៈច្បាប់ពេលដែលអ្នកទាំងពីររស់នៅជាមួយគ្នា អាស្រ័យដោយសហព័ទ្ធទាំងសងខាងព្រមព្រៀងគ្នា ឬសហព័ទ្ធណាម្ខាង ដោយមិនអាចរួមរស់នៅជាមួយគ្នាបានក៏ធ្វើសំណូមពរសុំដាច់សមគ្គសង្វាស នឹងត្រូវបានតុលាការសម្រេចចិត្តតាមបញ្ញត្តិច្បាប់។ ទាក់ទិននឹងការឱ្យនិយមន័យពាក្យថាការលែងលះនេះផងដែរក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ដែលចូលជាធរមាននៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១១ ហើយត្រូវបានអនុវត្តសព្វថ្ងៃនេះមិនមានមាត្រាណាមួយបានផ្តល់និយមន័យជាក់លាក់ចំពោះអត្ថន័យនៃការលែងលះនេះទេពោលគឺមានចែងតែអំពីមូលហេតុនៃការលែងលះប៉ុណ្ណោះគួរឱ្យកត់សម្គាល់ផងចំពោះការឱ្យនិយមន័យពាក្យថាការលែងលះគឺ មានលក្ខណៈខុសគ្នាដូចតទៅៈ

- យោងតាមវចនានុក្រមសម្តេចសង្ឃ ជួន ណាត ការលែងលះជាការផ្តាច់ចំណងសមគ្គសង្វាសដែលប្រកាសដោយសាលក្រមរបស់តុលាការ[2] ។

[1] មាត្រា៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

[2] យោងតាមវចនានុក្រមខ្មែរអង្គដែលធ្វើការកែសម្រួលពីវចនានុក្រមសេក្តីសង្ឃរាជជួនណាត ទំព័រ៧៣

- ចំណែកវចនានុក្រម Cambridge បានឱ្យនិយមន័យពាក្យ នៃការលែងលះយ៉ាងខ្លីថាគឺជាការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់[3] ។
- និងយោងតាមមាត្រា៣៨ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារឆ្នាំ១៩៨៩ បានឱ្យនិយមន័យនៃពាក្យថា ការលែងលះ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបការពេញច្បាប់ក្នុងពេលរស់នៅទាំងពីរនាក់ ។

លក្ខខណ្ឌដែលអាចលែងលះបាន គឺការលែងលះអាចធ្វើបានតាមផ្លូវតុលាការលុះត្រាតែភាគី នៃបណ្តឹងជាសហាព័ទ្ធដែលមានអត្ថិភាពនៃ ចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ដែលអ្នកទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និង បានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋាន[4]។ អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍បាន ដើរតួជាលក្ខខណ្ឌគ្រឹះនៅក្នុងរឿងក្តីនៃការលែងលះដោយហេតុថានៅពេលដំណើរការដោះស្រាយរឿងក្តីលែងលះតុលាការតែងតែបង្គាប់ដោយសហាព័ទ្ធផ្តល់នូវសំបុត្រអាពាហ៍ពិពាហ៍ដើម្បីធ្វើការពិនិត្យក្នុងករណីដែលសហាព័ទ្ធមិនបានផ្តល់តាមការបង្គាប់នេះទេតុលាការនឹងមិនជឿថាមានអង្គហេតុនៃ ការបង្កើតចំណងគតិយុត្តឡើយ ដូច្នេះពាក្យបណ្តឹង ឬពាក្យសុំនឹងត្រូវបានច្រានចោលដោយដីកាសម្រេចហេតុនេះដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ជាដំបូងសហាព័ទ្ធគឺត្រូវមានសំបុត្រអាពាហ៍ពិពាហ៍ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានតាមការស្នើសុំពីសហាព័ទ្ធទាំងពីរ ដូចនេះសហាព័ទ្ធណាម្ខាងអាចធ្វើការដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបានដើម្បីឱ្យតុលាការធ្វើការសម្រេចបាន។ បន្ថែមពីនេះទៅទៀតនោះពាក្យបណ្តឹងនោះត្រូវមានមូលហេតុត្រឹមត្រូវដូចដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ត្រង់មាត្រា៩៧៨ ។ អនុលោមតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និង គ្រួសារ ប្តីប្រពន្ធអាចប្តឹងសុំលែងលះគ្នាបានដោយផ្អែកលើពីរករណី គឺទីមួយប្តីប្រពន្ធអាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន និង ទីពីរបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថាខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។

ដូចគ្នាដែរចំពោះក្រមរដ្ឋប្បវេណីក៏បានកំណត់អំពីការលែងលះចែកចេញជា ២ ( ពីរ ) ប្រភេទ គឺការលែងលះដោយការព្រមព្រៀង និង ការលែងលះដោយគ្មានការព្រមព្រៀង។ ដោយសារតែការលែងលះដោយគ្មានការព្រមព្រៀង គឺភាគីទាំងសងខាងមិនមានឆន្ទៈព្រមព្រៀងគ្នាលែងលះទេ ដូច្នេះភាគីនៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន ។

[3] Cambridge University Press 1995 Page 403

[4] មាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ១.១. ការលែងលះដោយមានការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង គឺជាការលែងលះដែលកើតឡើងចេញពីឆន្ទៈពិតប្រាកដរបស់សហព័ទ្ធទាំងពីរក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍។ ម៉្យាងទៀតការលែងលះប្រភេទនេះគឺ ជាជម្រើសមួយនៃការលែងលះរបស់សហព័ទ្ធបើសិនជាសហព័ទ្ធទាំងពីរដែលមានចំណងអាពាហ៍ពិពាហ៍នឹងគ្នាដែលខ្លួនយល់ឃើញថាមិនអាចរួមរស់នៅជាមួយគ្នាអស់និស្ស័យនឹងគ្នាហើយ និង អស់មនោសញ្ចេតនានឹងគ្នាហើយបានព្រមព្រៀងគ្នារួចជាស្រេចអំពីការលែងលះអាចដាក់ពាក្យបណ្តឹងទៅតុលាការបាន។ ប៉ុន្តែតុលាការអាចនឹងឱ្យលែងលះបានក្រោយពីបានយល់ឃើញថាសហព័ទ្ធទាំងពីរ (សងខាង) មានឆន្ទៈពិតប្រាកដនៅក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍[5]។ ឆន្ទៈពិតប្រាកដក្នុងការព្រមព្រៀងលែងលះក្នុងន័យនេះចង់សំដៅដល់ការបង្ហាញឆន្ទៈព្រមព្រៀងដោយស្ម័គ្រចិត្តរបស់គូភាគីទាំងសងខាងដោយមិនមានវិការៈ ដូចជាការគំរាមគំហែង ការឆបោក ការភាន់ច្រឡំ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀតអំពើឆ្លៀតឱកាសដោយមានគោលបំណងកងចំណេញហួសហេតុជាអាទិ៍[6]។ ចំពោះការលែងលះប្រភេទនេះដោយពុំពិចារណាទៅលើមូលហេតុនៃការលែងលះដែលកំណត់ដោយក្រមរដ្ឋប្បវេណីឡើយ ហេតុនេះការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរគឺ ជាលក្ខខណ្ឌចំបាច់សម្រាប់ឱ្យតុលាការត្រូវយកធ្វើជាមូលដ្ឋាននៃការពិចារណាក្នុងការវិនិច្ឆ័យដើម្បីចេញដីកាសម្រេចនៃការលែងលះ។ ប្រសិនបើគូភាគី (ប្តីប្រពន្ធ) ព្រមព្រៀងគ្នាថាពួកគេមិនអាចរួមរស់នៅជាមួយគ្នាទៅទៀតបានបញ្ញត្តិ[7] អនុញ្ញាតឱ្យភាគីអាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបានហើយបើតុលាការរក ឃើញថាភាគីមានឆន្ទៈព្រមព្រៀងគ្នាពិតប្រាកដក្នុងការរំលាយចំណងអាពាពិពាហ៍តុលាការត្រូវតែសម្រេចឲ្យភាគីលែងលះគ្នាតាមដីកាសម្រេចនៃ ការលែងលះ[8] ការលែងលះនាំឲ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវទំនាក់ទំនងឋានៈបុគ្គល ដូចនេះទោះបីជាមានការព្រមព្រៀងគ្នារវាងភាគីក្នុងការលែងលះ មិនអាចបង្កើតកិច្ចសន្យាលែងលះក្រៅផ្លូវការ ឬគ្រាន់តែប្រើវិធីដាក់លិខិតជូនដំណឹងទៅសាលាឃុំ-សង្កាត់ បានទេចាំបាច់ត្រូវតែមានសេចក្តីសម្រេចរបស់តុលាការទើបការលែងលះមានអានុភាពតាមផ្លូវច្បាប់ ។ ប្តី ឬប្រពន្ធអាចលែងលះគ្នាដោយស្ម័គ្រចិត្តបានលក្ខខណ្ឌមួយគត់នៃការលែងលះនេះ ការព្រមព្រៀងគ្នារវាងសហព័ន្ធទាក់ទង នឹងការលែងលះដោយមានការព្រមព្រៀងគ្នានេះច្បាប់ក៏ទាមទារឲ្យមានបណ្តឹងលែងលះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង បញ្ជាក់មូលហេតុនៃការលែងលះ។ ចៅក្រមត្រូវពិនិត្យ

[5]មាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] មាត្រា៣៤៦ និង មាត្រាបន្តន្ទាប់ទៀត នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[7] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៧៩

[8] មាត្រា៣២ នៃច្បាប់ស្តីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង

ផងដែរនៅក្នុងករណីការសុំលែងលះគ្នាដោយព្រមព្រៀងនេះអំពីភាពប្រកាតប្រជានៃ ការព្រមព្រៀងមានន័យថា ប្រសិនបើមានការស៊ើបសួរចៅ ក្រមរកឃើញថាការសុំលែងលះគ្នានោះធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ នឹងដោយស្ម័គ្រចិត្តពិតប្រាកដនាំឲ្យគាត់ត្រូវសម្រេចចិត្តឲ្យមានការលែងលះ។

## ១.២. ការលែងលះដោយគ្មានការព្រមព្រៀង

ប្រសិនបើភាគី មិនមានឆន្ទៈព្រមព្រៀងគ្នាលែងលះទេនៅពេលដែលមានបណ្ដឹងចូលមកតុលាការត្រូវតែស្វែងរកមូលហេតុដែលនាំឲ្យភាគីលែងលះតាមផ្លូវច្បាប់បាន។

ការលែងលះដែលមានមូលហេតុដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណេ គឺជាការលែងលះដោយមិនមានការព្រមព្រៀងមានន័យថាភាគីម្ខាង (ប្ដីឬប្រពន្ធ) នៃអាពាហ៍ពិពាហ៍មិនមានឆន្ទៈក្នុងការលែងលះប៉ុន្តែភាគីម្ខាងទៀតទទួលឱ្យមានការលែងលះដោយមិនអាចរួមរស់នៅជាមួយគ្នាទៀតបាន។ ម៉្យាងទៀតដោយសារទ្រាំមិនបាននិងភាគីម្ខាងទៀត (ប្ដីប្រពន្ធ) បានធ្វើអំពើពុំគប្បីមិនសមរម្យណាមួយមិនអាចនឹងអធ្យាស្រ័យបានហើយការប្រព្រឹត្តនោះជះឥទ្ធិពលខ្លាំងទៅដល់ភាគីម្ខាងនៃជនរងគ្រោះ កូន សាច់ញាតិ នាំឱ្យបាត់បង់នូវសេចក្ដីថ្លៃថ្នូរនៅក្នុងគ្រួសារហើយក៏ជាមូលហេតុ នៃការលែងលះដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ៩៧៨ កថាខណ្ឌ១ផងដែរ។ភាពមិនសុខចិត្តភាគីនៃ ជនរងគ្រោះដែលទទួលរងអំពើនោះក៏បានសម្រេចចិត្តដាក់ពាក្យបណ្ដឹងសុំលែងលះ ដើម្បីឱ្យតុលាការធ្វើការវិនិច្ឆ័យហើយចេញសាលក្រមលែងលះឆ្លើយតបនឹងអ្វីដែលភាគីនៃជនរងគ្រោះដែលជាដើមបណ្ដឹងបានទាមទារនៅក្នុងពាក្យបណ្ដឹង ។

### ១.២.១. មូលហេតុទូទៅក្នុងគ្រួសារដែលនាំឲ្យមានការលែងលះ

- **ភាពមិនស្មោះត្រង់**

ភាពមិនស្មោះត្រង់ ជាកត្តាសំខាន់ដែលបណ្ដាលឲ្យសហព័ទ្ធភាគច្រើនឈានទៅដល់ការលែងលះនិងការបែកគ្នាក្នុងសង្គមនាពេលបច្ចុប្បន្ន។ សម្រាប់សហព័ទ្ធទាំងសងខាងអាកប្បកិរិយាមិនស្មោះត្រង់ចំពោះគ្នា គឺជាការពិបាកទទួលយកបំផុតនៅក្នុងការរស់នៅប្រចាំថ្ងៃនៃជីវិតគ្រួសារ។ ភាពមិនស្មោះត្រង់ទាំងនេះមិនសំដៅទៅលើតែលើទំនាក់ទំនងស្នេហាបែបត្រីកោណតែមួយមុខទេវា អាចជាភាពមិនស្មោះត្រង់លើទ្រព្យសម្បត្តិផងដែរ[៩]។

- **កង្វះចំណេះដឹង**

កង្វះចំណេះដឹងរបស់ប្ដីប្រពន្ធទាំងសងខាង ជាកត្តាសំខាន់មួយដែលធ្វើឲ្យប្ដីប្រពន្ធទាំងសងខាងជួបនៅបញ្ហាលែងលះគ្នា។ ករណីជាក់ស្ដែងដែលយើងមើលឃើញក្នុងសង្គមនាពេលបច្ចុប្បន្នទាក់ទងទៅនឹង

[9] https://km.warbletoncouncil.org/causas divorcio 5432#menu 12

ចំណេះដឹងនេះគឺ ប្តីប្រពន្ធដែលរស់នៅតាមទីជនបទផ្ទាល់តែម្តងដែលពួកគាត់មានជីវភាពក្រីក្រ និងមិនបានបន្តការសិក្សាបានជ្រៅជ្រះធ្វើឲ្យពួកគាត់ខ្វះការអំណត់ចិត្តបង្កជាអំពើហិង្សា រហូតបណ្តាលឲ្យមានការលែងលះគ្នាកើតឡើង។

❖ **កង្វះការប្តេជ្ញា**

កង្វះការប្តេជ្ញាចិត្ត គឺជាកត្តាដែលកើតមានជាទូទៅក្នុងចំណោមការលែងលះ និង ការបែកបាក់គ្នា។ ប្រសិនបើយើងវិភាគលក្ខណៈនៃ ទំនាក់ទំនងរវាងគូអាពាហ៍ពិពាហ៍វាបង្ហាញឱ្យឃើញថាការប្តេជ្ញាចិត្ត គឺជាទិដ្ឋភាពដែលមិនអាចខ្វះបាន។ បើគ្មានឆន្ទៈក្នុងការប្តេជ្ញាចិត្តទេវាពិតជាលំបាកខ្លាំងណាស់ក្នុងការរក្សាទំនាក់ទំនងជាមួយគ្នា ដូច្នេះគេសង្កេតឃើញថាគូស្វាមីភរិយាជាច្រើនដែលសម្រេចចិត្តរៀបការដោយមិនមានការតាំងចិត្តគ្រប់គ្រាន់ស្ទើរតែប្រែទៅជាការលែងលះដោយស្វ័យប្រវត្តិក្នុងឆ្នាំបន្តបន្ទាប់[10] ។

❖ **ការប្រច័ណ្ឌ**

ការប្រច័ណ្ឌជ្រុលហួសហេតុពេកដោយមិនយកហេតុផលមកពិចារណាឱ្យបានត្រឹមត្រូវងាយ នឹងប៉ះពាល់ដល់ការរស់នៅជាមួយគ្នាខ្លាំង។ ពីព្រោះកាលណាបើសិនជាមួយថ្ងៃៗ គិតតែពីរករឿងគិតតែពីខឹងគ្នានោះនឹងធ្វើឲ្យសហព័ទ្ធងាយការបែកបាក់គ្នាងាយរស់នៅផ្សេងគ្នា និង តែងតែមានបញ្ហាក្នុងគ្រួសាររហូតដល់ឈានដល់ការលែងលះគ្នា។

❖ **រៀបការនៅក្មេងពេក**

សព្វថ្ងៃនេះមានការយល់ស្របខ្ពស់ក្នុងការបញ្ជាក់ថា អាពាហ៍ពិពាហ៍ដែលបង្កើតឡើងក្នុងភាពវ័យក្មេងពេកត្រូវបានបង្ហាញថាជាកត្តាហានិភ័យខ្លាំងបំផុតនៃ ការលែងលះ។ ពីព្រោះសហព័ទ្ធដែលមានភាពវ័យក្មេងពួកគេនៅខ្វះចំណេះដឹងក្នុងការប្តេជ្ញាចិត្ត និង ភាពអត់ធ្មត់ពេលរស់នៅជាមួយគ្នា។ មួយវិញទៀតបទពិសោធន៍ក្នុងសង្គមក៏ហាក់នៅខ្វះខាតជាពិសេសការងារដែលច្បាស់លាស់មួយសម្រាប់ចិញ្ចឹមគ្រួសារក៏មិនទាន់មានទៀតផងដែលជាហេតុនាំឲ្យសេដ្ឋកិច្ចគ្រួសារគ្មានលំនឹងរហូតឈានដល់ការប្រេះឆាក្នុងគ្រួសារកើតឡើង[11] ។

❖ **រៀបការដោយមិនពេញចិត្ត**

ពេលបច្ចុប្បន្នពាក្យថានំមិនធំជាងនាលនៅតែបន្តប្រើប្រាស់ទៅលើកូនៗ នៅក្នុងគ្រួសារមួយចំនួនដដែល។ កត្តានេះហើយដែលធ្វើឲ្យប្តីប្រពន្ធមួយចំនួនមិនបានស្វែងយល់ពីគ្នាឲ្យបានស៊ីជម្រៅមុនពេលសម្រេចចិត្តរៀបការជាមួយគ្នាផងដែរជាហេតុនាំឲ្យសហព័ទ្ធងាយនឹងលែងលះគ្នា។

[10] h t t p s ://k m.wa r bl e t oncounci l .o r g/c a u s a s -di vo r ci o -5437#me n u -12

[11] h t t p s ://k m.wa r bl e t oncounci l .o r g/c a u s a s -di vo r ci o -5432#me n u -12

❖ **ការប្រើប្រាស់អំពើហិង្សា**

អំពើហិង្សាក្នុងគ្រួសារ សំដៅលើហិង្សាដែលកើតមាន និង អាចកើតមានទៅលើប្តីឬប្រពន្ធ កូនក្នុងបន្ទុក ឬជនទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះ និង ក្នុងបន្ទុកគ្រួសារ[12]។ បើក្រឡេកមើលនៅក្នុងជម្លោះរវាងប្តីប្រពន្ធអំពើហិង្សាក្នុងគ្រួសារបានបង្កឱ្យមានអំពើវាយដំ ប្រើសំដីបរិហារកេរ្តិ៍គ្នាទៅវិញទៅមករហូតឈានទៅដល់ការបែកបាក់កូនចៅ ប្តីប្រពន្ធ និង ក្រុមគ្រួសារទាំងមូល។ អំពើហិង្សាសំដៅយកការរំលោភបំពានឬបង្ខិតបង្ខំផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ ផ្លូវសេដ្ឋកិច្ចរួមបញ្ចូលទាំងការប្រមាថមាក់ងាយ ការគំរាមគំហែង ការដាក់ឱ្យនៅឯកោដាច់ពីគេឯង និងការរំលោភបំពានផ្នែកជីវភាពសេដ្ឋកិច្ចពីសំណាក់បុគ្គលម្នាក់ ឬច្រើនដើម្បីត្រួតត្រាទៅលើបុគ្គលផ្សេងៗទៀត។ មូលហេតុនៃអំពើហិង្សាកើតឡើដោយសារភាពមិនចុះសម្រុងគ្នាខាង ផ្លូវកាយ ផ្លូវចិត្ត និងការចែករំលែកផលប្រយោជន៍មិនស្មើគ្នា។ អំពើហិង្សាកើតឡើងចំពោះមនុស្សគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមមិនថា អ្នកមាន អ្នកក្រ អ្នកមានចំណេះដឹងខ្ពស់ អ្នកមានប្រាក់ចំណូលខ្ពស់ ឬតិចឡើយ។ ភាពមិនចុះសម្រុងគ្នាខាងផ្លូវកាយ ផ្លូវចិត្ត ការខ្វែងគំនិតគ្នាធ្វើឱ្យអារម្មណ៍មានការឈឺចាប់ដែលឈានទៅរកការប្រើប្រាស់វិធីផ្សេងៗ ដើម្បីយកឈ្នះលើភាគីម្ខាងទៀតដោយពុំបានគិតពីទង្វើរនេះល្អ ឬអាក្រក់ ខុសច្បាប់សង្គមឡើយ។ បញ្ហានេះបណ្តាលឱ្យមានកំហឹងពុំអាចរកវិធីដោះស្រាយដោយសន្តិវិធី អធ្យាស្រ័យហើយឈានទៅដល់ការវាយដំណាក់ការប្រើអំពើឃោរឃៅ អមនុស្សធម៌។ ម្យ៉ាងទៀតអំពើហិង្សាអាចកើតមានឡើងពីការដណ្តើមផលប្រយោជន៍គ្នា ការជួបអំពើអយុត្តិធម៌ ការដុតកំហឹង ការប្រកាន់បក្សពួក ប្រកាហារកេរ្តិ៍គ្នាទៅវិញទៅមក ឬការឈានដល់ការបែកបាក់កូនចៅ ប្តីប្រពន្ធ និងក្រុមគ្រួសារ ។

❖ **ការរស់នៅមិនចុះសម្រុងគ្នា**

ជាការពិតណាស់ភាពមិនចុះសម្រុងគ្នាខាង ផ្លូវកាយ ផ្លូវចិត្ត និងការខ្វែងគំនិតគ្នាបានធ្វើឱ្យសហព័ទ្ធណាម្នាក់មានអារម្មណ៍មិនអាចទទួលយកបានរហូតឈានទៅរកការលែងលះ ដើម្បីយកឈ្នះលើភាគីម្ខាងទៀត ឬក៏ដើម្បីចាកចេញពីសម្ពាធផ្លូវចិត្តដែលបណ្តាលមកពីភាពមិនចុះសម្រុងគ្នា។

❖ **បញ្ហាសេដ្ឋកិច្ច ឬជីវភាព**

ជីវភាពបានបង្ខំឲ្យសហព័ទ្ធឃ្លាតឆ្ងាយពីគ្នា។ នេះជាស្ថានភាពពិតមួយដែលកំពុងតែកើតឡើងជារៀងរាល់ថ្ងៃនៅក្នុងប្រទេសយើង។ បញ្ហានេះភាគច្រើនត្រូវបានគេសម្គាល់ឃើញថា កើតឡើងចំពោះសហព័ទ្ធបំរើការងារនៅក្នុងវិស័យឧស្សាហកម្ម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធជាដើម។ ការរស់នៅបែកគ្នាបែបនេះ នឹងធ្វើឲ្យភាគីណាមួយចាប់ផ្តើមអស់មនោសញ្ចេតនា ជាមួយគ្នារហូតឈានទៅដល់ការសុំលែងលះគ្នាជាក់ជាមិនខាន។

[12] មាត្រា២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥

អាពាហ៍ពិពាហ៍ងាយនឹង បែកគ្នាណាស់ ប្រសិនបើមានការលំបាកផ្នែកហិរញ្ញវត្ថុ។ ទោះយ៉ាងណាក៏ដោយកង្វះភាពយល់ដឹងរវាងប្តី ប្រពន្ធក្នុងវិស័យហិរញ្ញវត្ថុទំនងជាបញ្ហាសំខាន់ជាង។

**១.២.២. មូលហេតុទូទៅក្នុងសង្គមដែលនាំឲ្យមានការលែងលះ**

❖ **ការផ្សព្វផ្សាយគ្រឿងស្រវឹង**

ការផ្សព្វផ្សាយគ្រឿងស្រវឹងបណ្តាលឲ្យមានបញ្ហាជាច្រើនក្នុងគ្រួសារ និងសង្គមជាតិទាំងមូល ។ ចំពោះការផ្សព្វផ្សាយនេះបានជំរុញឲ្យមានការប្រើប្រាស់នូវគ្រឿងស្រវឹងកាន់តែខ្លាំងឡើងៗដែលជាហេតុនាំឲ្យសង្គមគ្រួសារដែលកំពុងប្រើប្រាស់គ្រឿងស្រវឹងស្រាប់នោះមានជីវភាពកាន់តែក្រីក្រទៅៗ និងថែមទាំងមានការប្រើប្រាស់ហឹង្សាក្នុងគ្រួសារជាញឹកញាប់ទៀតផង ។

❖ **ការបើកកន្លែងកំសាន្តពេលរាត្រី**

កន្លែងកំសាន្តពេលរាត្រីនាពេលបច្ចុប្បន្នកំពុងតែរីកដុះដាលដូចផ្សិតស្ទើរតែគ្រប់ទីកន្លែងទៅហើយ ។ ហេតុផលមួយនេះអាចនឹងឲ្យសហព័ទ្ធណាម្នាក់ ជាពិសេសភាគីខាងប្តីងាយស្រួលមែនទែនក្នុងការទៅរកកន្លែងកំសាន្តនៅខាងក្រៅរហូតភ្លេចគ្រួសារ នឹងអាចឈានទៅដល់មានដៃគូខាងក្រៅលួចលាក់ប្រពន្ធមិនឲ្យដឹងទៀតផង។ កត្តាទាំងនេះបានបង្កជាជម្លោះក្នុងគ្រួសារជាញឹកញាប់ រហូតឈានដល់ការលែងលះគ្នាក្នុងរង្វង់គ្រួសារដែលករណីនេះសម្បូរកើតឡើងណាស់នាពេលបច្ចុប្បន្ន។

❖ **ការប្រើប្រាស់គ្រឿងញៀន**

ក្នុងសង្គមបច្ចុប្បន្នគ្រឿងញៀន គឺជាមូលហេតុធំណាស់ដែលនាំឲ្យមានការលែងលះគ្នាក្នុងគ្រួសារព្រោះគ្រឿងញៀនបានបង្កឲ្យមានផលវិបាកចំពោះគ្រួសារដូចជា បាត់បង់សមត្ថភាពក្នុងការបំពេញការងា របាត់បង់អាជីពការងារ ចំណូលគ្រួសារថយចុះ ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ និងបង្កឲ្យកិត្តិយសគ្រួសារអាប់ឱនជាដើម។ ក្រៅពីផលប៉ះពាល់ចំពោះគ្រួសារ គ្រឿងញៀនបានបង្កឲ្យមានផលវិបាកផ្សេងៗទៀតដល់សហគមន៍ និង សង្គមជាតិដូចជា បង្កឲ្យមានឧក្រិដ្ឋកម្ម ឃាតកម្ម ចោរកម្ម អសន្តិសុខ ធនធានមនុស្សនៃ សង្គមជាតិថយ ចុះការអភិវឌ្ឍន៍សង្គមមានការយឺតយ៉ាវ សីលធម៌សង្គមធ្លាក់ចុះទាបប្រពៃណីវប្បធម៌ជាតិធ្លាក់ចុះ ប្រទេសជាតិទន់ខ្សោយជាដើម។

❖ **ការប្រារព្ធពិធីផ្សេងៗដែលមានការផឹកគ្រឿងស្រវឹង**

នៅពេលមានការប្រារព្ធពិធីផ្សេងៗ នៅក្នុងសង្គមយើងសង្កេតឃើញថាការដាក់គ្រឿងស្រវឹងសម្រាប់ឲ្យភ្ញៀវដែលចូលរួមសម្រាប់ពិសារក្នុង កម្មវិធីហាក់មិនដែលរំលងនោះទេប្រាកដណាស់ការដាក់គ្រឿងស្រវឹងនៅក្នុង

កម្មវិធីផ្សេងៗ វាមិនអាក្រក់ទេតែបើការដាក់នោះច្រើនលើសលប់ពេកធ្វើឲ្យបុគ្គលដែលចូលរួមពិសារគ្រឿងស្រវឹង រហូតផឹកច្រើនពេកបង្កជាជម្លោះក្នុងគ្រួសារ ។

❖ **ការសេពគប់មិត្ត**

ក្នុងសង្គមសម័យទំនើបនេះការសេពគប់មិត្តភក្តិជារឿងសំខាន់ណាស់បំផុតដើម្បីទទួលបានសុភមង្គល ក្នុងគ្រួសារទាំងមូល បើយើងយកបុគ្គលបែបណាជាមិត្តនោះយើង នឹងប្រាកដស្មោះត្រង់ជាមួយមិត្តនោះជាក់ជាមិនខាន។ ព្រោះបើមិត្តយើងជាមនុស្សដែលចូលចិត្តការដើរលេងផឹកស៊ី នោះយូរៗទៅយើង នឹងក្លាយជាមនុស្សបែបនោះដែរជាមិនខាន ហេតុផលទាំងនេះហើយដែល នឹងនាំឲ្យមានភាពរកាំរកូសបន្តិចម្តងៗក្នុងរង្វង់គ្រួសារ។

**១.២.៣. មូលហេតុនៃការលែងលះដែលមានចែងក្នុងច្បាប់**

**ក. ករណីប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ**

ករណីយុត្តិសាស្ត្ររបស់ប្រទេសជប៉ុនបានឲ្យនិយមន័យអំពើផិតក្បត់ថាគឺ ជាការមានចំណងផ្លូវភេទនឹងបុគ្គលផ្សេងៗ ក្រៅពីសហព័ទ្ធ។ និយមន័យនៃយុត្តិសាស្ត្រប្រទេសជប៉ុននេះ គឺមានន័យដូចនិយមន័យនៃច្បាប់ស្តីពីឯកពន្ធភាព[13] នៅប្រទេសកម្ពុជាដែរ “ **អំពើផិតក្បត់** ” គឺជាការរួមសវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រលាយជាមួយស្ត្រីដទៃ ក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីប្រពន្ធរបស់ខ្លួន ។

ដោយគោរពទៅលើគោលការណ៍ឯកពន្ធភាពបុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ[14]។ មានន័យថាសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ហើយពុំអាចរៀបការជាមួយស្ត្រី ឬបុរសដទៃ ក្រៅសហព័ទ្ធខ្លួនដែលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ឡើយ ជាទូទៅបុរសត្រូវមានប្រពន្ធតែមួយ ឯស្ត្រីត្រូវមានប្តីតែមួយដូចគ្នាផ្ទុយពីនេះត្រូវចាត់ទុកថាជាអំពើផិត។ អំពើផិតគឺជារួមសេវនកិច្ចរវាងបុរសដែល មានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្តីដទៃ ក្រៅពីសហព័ទ្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍នឹងគ្នា ហើយលួចទៅប្រព្រឹត្តអំពើក្បត់ជាមួយស្តី ឬបុរសដទៃក្រៅពីសហព័ទ្ធខ្លួន[15] ដែលផ្ទុយទៅនឹងច្បាប់បានបញ្ញត្តិត្រូវចាត់ទុកថាជាអំពើដែលមានពិរុទ្ធផងដែរ[16]។ ការប្រព្រឹត្តអំពើផិតគឺ ជាលក្ខខណ្ឌដែលសហព័ទ្ធម្ខាងបានទទួលរងនូវការបំពានសិទ្ធិអាចដាក់ពាក្យបណ្តឹងលែង

[13] មាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព

[14] មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[15] មាត្រា៣ នៃច្បាប់ស្តីពីឯកពន្ធភាព ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៦

[16] មាត្រា៦ នៃច្បាប់ស្តីពីឯកពន្ធភាព ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៦

លះបាន ។ ឧទាហរណ៍ A បានរៀបអាពាហ៍ពិពាហ៍ជាមួយ B ២ឆ្នាំ ក្រោយមក A បានមានសម្ព័ន្ធភាពផ្លូវភេទជាមួយនឹងនារី C រឿងនេះបានដឹងដល់ B គាត់មានការឈឺចិត្តយ៉ាងខ្លាំងជាហេតុធ្វើឲ្យ B លែងចង់រួមរស់នៅជាមួយតទៅទៀត ក្នុងករណីនេះ B អាចលែងលះជាមួយ A បាន។

**ខ. ករណីមានការបោះបង់ចោលសហព័ន្ធដោយគ្មានមូលហេតុត្រឹមត្រូវ**

ករណីខាងលើនេះមានន័យថា សហព័ទ្ធណាមួយ ឬប្តីប្រពន្ធបានចុះចោល ឬចាកចេញដោយគ្មានប្រាប់មូលហេតុច្បាស់លាស់ដោយផ្ទុយនឹងគោលបំណងនៃការរៀបអាពាហ៍ពិពាហ៍ពោលគឺ សហព័ទ្ធម្ខាងមិនយកចិត្តទុកដាក់លើសហព័ទ្ធម្ខាងទៀត។

ការបោះបង់ចោលសហព័ទ្ធដោយគ្មាន មូលហេតុត្រឹមត្រូវដោយភាគីណាម្ខាងនៃសហព័ទ្ធ គឺជាហេតុផលមួយនៃ ការមិនរួមរស់ជីវភាពជាមួយគ្នាសហការគ្នា និង សង្គ្រោះគ្នាទៅវិញទៅមកដូចមានបញ្ញត្តិនៅក្នុងមាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណីនេះសរបញ្ជាក់ឱ្យឃើញថាភាគីនោះគ្មានឆន្ទៈបន្តជីវភាពរស់នៅជាប្តីប្រពន្ធតទៅទៀតនោះទេ។ ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ គឺជាលក្ខខណ្ឌដែលអាចឱ្យភាគីម្ខាងនៃជនដែលត្រូវបានបំពានសិទ្ធិហើយជាជនរងគ្រោះថែមទៀតនោះមានហេតុផលគ្រប់គ្រាន់ក្នុង ការអះអាងសិទ្ធិរបស់ខ្លួននៅចំពោះមុខតុលាការ។

ឧទាហរណ៍ទី១៖ A (ប្តី) B (ប្រពន្ធ) បានឈ្លោះទាស់ទែងគ្នា A បានបណ្តេញ B ឱ្យចេញពីផ្ទះ B គ្មានកន្លែងស្នាក់នៅបានទៅរស់នៅផ្ទះជាមួយគាត់រយៈពេល១ឆ្នាំហើយ ទំនាក់ទំនងរវាង A និង B នៅតែមិនត្រូវគ្នាក្នុង ករណីនេះ B អាចទាមទារឱ្យលែងលះបាន ។ ឧទាហរណ៍ទី២ A (ប្តី) បានឈ្លោះទាស់ទែងជាមួយ B (ប្រពន្ធ) ហើយ A បានប្រមូលទ្រព្យសម្បត្តិទាំងអស់ចាកចេញទៅករណីនេះក៏ត្រូវរាប់ចូលក្នុងករណីបោះបង់សហព័ទ្ធដោយ គ្មានមូលហេតុត្រឹមត្រូវដែរ ។

**គ. ករណីមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់អស់រយៈពេលជាង ០១ឆ្នាំ**

ប្រសិនបើសហព័ទ្ធណាមួយបានចាកចេញ ឬចុះចោលសហព័ទ្ធម្ខាងទៀតដោយបាត់ដំណឹងសូន្យគ្មានបាន ផ្តល់ដំណឹងឲ្យសហព័ទ្ធមួយទៀតឲ្យបានដឹងហើយបានចុះចោលជិតមួយឆ្នាំសហព័ទ្ធណាមួយអាចដាក់ពាក្យសុំលែងលះ ឬជូនដំណឹងទៅឃុំ/សង្កាត់ឲ្យបានដឹងឮ។

នៅត្រង់ចំនុចនេះជា ករណីដែលសហព័ទ្ធម្ខាងមិនបានទទួលដំណឹងពីសហព័ទ្ធណាម្ខាងមិនបានទទួលដំណឹងពីសហព័ទ្ធណាម្ខាងទៀតដែលបានចាកចេញពីទីលំនៅរបស់ខ្លួនទៅបំពេញការងារ ឬភារកិច្ចណាមួយ ហើយការចាកចេញនោះទៅបាត់សូន្យឈឹងមិនដឹងថាទៅដល់ទីណាធ្វើអ្វីនៅកន្លែងណានោះទេ គឺគ្មានដំណឹងអស់រយៈពេលជាង០១ឆ្នាំក្រោយពីថ្ងៃចាកចេញនោះ។ ទាក់ទិនទៅ នឹងបញ្ហាខាងលើនេះសហព័ទ្ធម្ខាង

ទៀតអាចដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីលែងលះដោយបញ្ជាក់ពីអំឡុងពេលដែលសហព័ទ្ធម្ខាងទៀតបានចាកចេញហើយបាត់ដំណឹងសូន្យមិន ឃើញត្រឡប់មកវិញមកដល់ពេលបច្ចុប្បន្នដែលនេះជាលក្ខខណ្ឌតែមួយឆ្លើយតបទៅនឹងការទាមទាររបស់ភាគីម្ខាងនៃជនរងគ្រោះ។ អំឡុងពេលជាង០១ឆ្នាំគិតចាប់ពីថ្ងៃបន្ទាប់ដែលសហព័ទ្ធចាកចេញហើយមិនបានផ្ដល់ដំណឹងថានៅរស់ ឬស្លាប់គិតរាប់ចាប់ពីថ្ងៃបន្ទាប់ដែលសហព័ទ្ធនោះចាកចេញលើកលែងតែ អំឡុងពេលនោះបានចាប់ផ្ដើមពីម៉ោងសូន្យទៅគឺ ម៉ោងរំលងអាធ្រាត្ររហូតដល់ពេលបច្ចុប្បន្ន។[17]

ឧទាហរណ៍៖ (ប្ដី) បានចាកចេញពីផ្ទះពីថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១៤ ដោយមិនឃើញត្រលប់មកវិញអស់រយៈពេលជាង០១ឆ្នាំហើយ នៅ តែមិនឃើញសហព័ទ្ធត្រលប់មកវិញទេក្នុងករណីនេះ ប្រពន្ធអាចទាមទារឱ្យលែងលះបាន ។ សំណួរសួរថាតើអំឡុងពេលជាង ០១ឆ្នាំត្រូវគណនាចាប់ពីពេលណា? អំឡុងពេលជាង០១ឆ្នាំត្រូវគណនាលើមាត្រា៣៣១ នៃក្រមរដ្ឋប្បវេណី។ ឧទាហរណ៍ ប្ដី នៅថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១៤ បានចាកចេញពីផ្ទះទៅធ្វើការដូចរាល់ដងប៉ុន្តែចាប់តាំងពីថ្ងៃនោះមក មិនបានត្រលប់មកផ្ទះវិញទេ ហើយក៏បាត់ដំណឹងសូន្យមិនដឹងថាស្លាប់ ឬ រស់ឡើយ ការបាត់ដំណឹងនេះ មានអំឡុងពេលជាង០១ឆ្នាំហើយគិត ចាប់ពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន។ ប៉ុន្តែប្រសិនបើសហព័ទ្ធដែលបានបាត់ពីផ្ទះដោយជួបបញ្ហាគ្រោះថ្នាក់ដូចជា ធ្លាក់យន្តហោះជាដើមហើយគេមិនដឹងថាស្លាប់ ឬរស់ ក្នុងករណីនេះអំឡុងពេលជាង០១ឆ្នាំ ត្រូវបានបកស្រាយថាគិតចាប់ពីថ្ងៃដែលបានគ្រោះថ្នាក់នោះបានកើតឡើង។ ដូចនេះតុលាការនឹងសម្រេចពីការប្រកាសអំពីការបាត់ខ្លួនតាមការស្នើរសុំពីសហព័ទ្ធម្ខាងទៀតនៃ ជនរងគ្រោះនោះបានដោយគ្រាន់បង្ហាញភស្តុតាងដែលអាចបញ្ជាក់អំពីស្ថានភាពដែលបាត់ដំណឹងអំពីសហព័ទ្ធដោយមិនដឹងថា ស្លាប់ ឬ រស់អស់រយៈពេលជាង០១ឆ្នាំនោះគ្រប់គ្រាន់ដើម្បីលែងលះ។

**ឃ. ករណីសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ឆ្នាំ**

ករណីសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ឆ្នាំ ផ្ទុយទៅនឹងគោលបំណងនៃ អាពាហ៍ពិពាហ៍ការរស់នៅឆ្ងាយដោយសារការងារមិនចាត់ចូលនៅក្នុងករណីនេះទេ ។

ជាទូទៅសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍គ្នាគឺ ត្រូវតែរួមរស់នៅជាមួយគ្នាក្នុងដំបូលផ្ទះតែមួយ។ វាជារឿងចម្លែកទៅវិញទេដែលសហព័ទ្ធដែលបានរៀបអាពាហាហ៍ពិពាហ៍ហើយមិនរួមរស់នៅជាមួយគ្នានោះ ប៉ុន្តែក៏មានករណីលើកលែងមួយចំនួន នៅពេលដែលសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ហើយត្រូវចាកចេញដើម្បីទៅបំពេញការងារណាមួយនៅឆ្ងាយ ដើម្បីបំពេញតម្រូវការនៃជីវភាពរស់នៅ ឬការងារចាំបាច់ដែលខានមិនបានដូច

[17] មាត្រា៣៣៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ជាការបំពេញការងារជាមន្ត្រីស្ថានទូតជាដើម។ ប៉ុន្តែសម្រាប់ការរស់នៅបែកគ្នាដូចប្តីប្រពន្ធហើយលែងមានសម្ព័ន្ធផ្លូវភេទជាមួយគ្នាដែលផ្ទុយទៅនឹង គោលបំណងអាពាហ៍ពិពាហ៍ដែលចាត់ចូលទៅនឹងករណីនេះជាទូទៅការរស់នៅបែកគ្នានោះត្រូវបន្តជាប់គ្នារហូត ក្នុងន័យនេះមិនមែនមិនឱ្យឃ្លាតពីគ្នាមួយជំហានសោះឡើយនោះទេ ប៉ុន្តែត្រូវស្ថិតក្នុងអំឡុងពេល ឬរយៈពេលមួយសមរម្យដែលសហព័ទ្ធទទួលយកបាន និងមិនផ្ទុយទៅនឹងគោលបំណងអាពាហ៍ពិពាហ៍ ។ ឧទាហរណ៍ ប្តី ប្រពន្ធ បានឈ្លោះទាស់ទែងគ្នាបានចាកចេញពីផ្ទះមករស់នៅផ្ទះឪពុកម្តាយរបស់គាត់មួយអាទិត្យត្រលប់មកផ្ទះម្តង ក្នុងគោលបំណងមកមើលកូនហើយលែងមាន សម្ព័ន្ធផ្លូវភេទជាមួយគ្នា ចាប់ពីពេលនោះមកក្នុងករណីនេះប្រពន្ធអាចទាមទារលែងលះគ្នាបាន ។

**ង. ករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ឬករណីផ្សេងទៀត**

ករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ឬករណីផ្សេងទៀតដែលគ្មានសង្ឃឹមថា និង អាចបដិទានឡើងវិញបានបញ្ញត្តិចំណុចនេះមានលក្ខណៈទូលាយ និយាយរួមទោះបីជា មូលហេតុទាំងឡាយដែលមិនចូលក្នុងចំណុច ពី “ ក ” ដល់ " ឃ " គឺស្ថានភាពនោះអាចនឹងត្រូវបានគេរាប់បញ្ចូលទៅក្នុងចំណុច “ ង ” នេះ។ តុលាការគប្បីត្រូវពិចារណាដល់ស្ថានភាពនានា ដូចជាសកម្មភាព និង អាកប្បកិរិយារបស់អ្នកទាំងពីរ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (វាយដំធ្វើទុកបុកម្និញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬញាតិរបស់សហព័ទ្ធមានចរិយាផ្ទុយពីសីលធម៌ ឬប្រព្រឹត្តិអនាចារ) ឆន្ទះចង់បន្តចំណងអាពាហ៍ពិពាហ៍ឬទេ ស្ថានភាពអពលនុភាពនៃ លឹង្គស្ថានភាពសេដ្ឋកិច្ចជាអាទិ៍។

យោងតាមច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ ការលែងលះដោយឯកតោភាគីអាចធ្វើឡើងទៅបានលុះត្រាតែមាន មូលហេតុត្រឹមត្រូវ និងគ្រប់គ្រាន់បញ្ជាក់បានថាសហព័ទ្ធទាំងពីរនាក់ពុំអាចរស់នៅជាមួយគ្នាតទៅទៀតបាន ។ មាត្រា ៣៩ បានចែងនូវមូលហេតុ៦ជាអាទិ៍ដែលអាចឲ្យសហព័ទ្ធទាំង២សុំលែងលះបាន៖

- ការចុះចោលលំនៅដ្ឋានដោយពុំមានមូលហេតុត្រឹមត្រូវ និងមិនបានចូលរួម
- ចំណែកផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបម្រុងកូនសោះ
- ការប្រើប្រាស់អំពើហិង្សា វាយដំឃោរឃៅធ្វើទុក្ខបុកម្នេញប្រមាថមើលងាយ ធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬបុព្វញាតិរបស់សហព័ទ្ធនោះ
- ចរិយាផ្ទុយពីសីលធម៌ និងការប្រព្រឹត្តអនាចារ
- ការបែកគ្នាអស់រយៈពេលជាងមួយឆ្នាំ
- អពលានុភាពនៃលិង្គ

## ១.៣. ស្ថានភាពអាពាហ៍ពិពាហ៍

នៅក្នុងសង្គមខ្មែរបុរស និងនារីនៅពេលដល់អាយុពេញវ័យ ឪពុក-ម្តាយ តែងតែរៀបចំទុកដាក់ឲ្យមានគូស្រករដើម្បីបង្កើតគ្រួសារបន្តពូជវង្សត្រកូលតាមរយៈការរៀបចំពិធីអាពាហ៍ពិពាហ៍ដែលមានលក្ខណៈតូច ឬធំទៅតាមលទ្ធភាពគ្រួសារ និងគោរពទៅតាមប្រពៃណីទំនៀមទម្លាប់ខ្មែរ។ ប្រជាពលរដ្ឋមួយចំនួនជាពិសេសនៅតាមជនបទហាក់មានទំនោរយ៉ាងខ្លាំងទៅលើការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណី ទំនៀមទម្លាប់ ដោយមិនមានការចាប់អារម្មណ៍ទៅលើការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលប្រជាពលរដ្ឋមួយចំនួនតែងនិយមហៅថា « អេតាស៊ីវិល » ដែលជាពាក្យរបស់បារាំងអាពាហ៍ពិពាហ៍គឺ ជាកិច្ចសន្យាដ៏អោឡារិកមួយធ្វើឡើងដោយបុរសម្នាក់និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបទបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ អាពាហ៍ពិពាហ៍ និង មានអានុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ។ បុរស និង នារីដែលមានអាយុពេញលក្ខណច្បាប់មានសិទ្ធិពេញលេញក្នុងការសំរាចចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ។ គ្មាននណាម្នាក់ អាចបង្ខំបុគ្គលណាម្នាក់អោយរៀបការ ឬរាំងមិនឲ្យរៀបអាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះឡើយ។ ហើយអាពាហ៍ពិពាហ៍ នឹងអាចចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បានលុះត្រាតែបុរស និង នារីដែលស្ម័គ្រចិត្តយកគ្នាជាប្តីប្រពន្ធនោះបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ខាងលំនៅរបស់នារី។ កិច្ចសន្យាត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្តីប្រពន្ធ និងសាក្សីជានីតិជនទាំងពីរនាក់។ បើបុរស និង នារីទាំងពីរនាក់នោះបានរៀបអាពាហ៍ពិពាហ៍តែមិនបានទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ទេនោះ ការរៀបអាពាហ៍ពិពាហ៍របស់គាត់ទាំងពីរនឹងមិនទទួលបាននូវភាពស្របច្បាប់ឡើយ (អនីតិសង្វាស)។ នៅក្នុងស្ថានភាពអាពាហ៍ពិពាហ៍យើងក៏បានបែងចែកជាពីរផងដែរ។

### **១.៣.១. មានសំបុត្រអាពាហ៍ពិពាហ៍**

បើបុរស និងនារីទាំងពីរនោះបានរៀបអាពាហ៍ពិពាហ៍ហើយត្រូវទៅ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬសំបុត្រអាពាហ៍ពិពាហ៍ក្នុងបញ្ជីអាពាហ៍ពិពាហ៍ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្តីប្រពន្ធ និងសាក្សីនីតិជនទាំងពីរនាក់ នោះទើបអាពាហ៍ពិពាហ៍របស់គាត់ទាំងពីរស្របច្បាប់ ឬយើងអាចនិយាយបានថាគាត់ទាំងពីរមានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ។ ដើម្បីឲ្យអាពាហ៍ពិពាហ៍ស្របច្បាប់ បុរស-នារីត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោមៈ

**ក.លក្ខខណ្ឌសារធាតុៈ**

**១. ការព្រមព្រៀង** ៖ អាពាហ៍ពិពាហ៍ គឺការព្រមព្រៀងដែលកើតចេញពីឆន្ទៈពិតប្រាកដរបស់បុរស-នារី ដើម្បីរួមរស់ជាមួយគ្នា ហើយគ្មានភាគីណាមួយអាចរំលាយ អាពាហ៍ពិពាហ៍នេះទៅតាមទំនើងចិត្តបានឡើយ។

**២. ភេទ** ៖ ការរៀបអាពាហ៍ពិពាហ៍ ភាគីចាំបាច់ត្រូវតែមានភេទផ្ទុយគ្នា។ ច្បាប់មិនអនុញ្ញាតឲ្យភាគីមានភេទដូចគ្នារៀបអាពាហ៍ពិពាហ៍ឡើយ។

**៣. អាយុ** ៖ បុរស-នារីដែលដល់នីតិភាព ពោលគឺចាប់ពីអាយុ១៨ឆ្នាំឡើងទៅអាចរៀបអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាពហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលរបស់អនីតិជននោះ។ បើអ្នកដែលមានអំណាចមេបាម្ខាងណាមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាងជាការគ្រប់គ្រាន់។ ក្នុងករណីដែលអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជន បដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យអនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍អាចទាមទារទៅតុលាការឲ្យសម្រេចសេចក្ដីជំនួសការយល់ព្រមនោះបាន។[18]

**៤. នៅលីវ** ៖ ច្បាប់បានទទួលស្គាល់តាមគោលការណ៍ស្មគ្រចិត្តប្ដីមួយប្រពន្ធមួយហេតុនេះបុរស-នារីដែលមានបំណងរៀបអាពាហ៍ពិពាហហ៍ត្រូវតែនៅលីវ។ ប្រសិនបើភាគីណាមួយកំពុងមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ត្រូវតែបញ្ចប់ចំណងអាពាហពិពាហ៍នោះជាមុនសិនតាមរយៈសេចក្ដីសម្រេចរបស់តុលាការ។ ក្រៅពីលក្ខខណ្ឌខាងលើច្បាប់បានហាមឃាត់ការរៀបអាពាហ៍ពិពាហ៍មួយចំនួនដូចខាងក្រោម៖

* **ហាមឃាត់មិនឲ្យមានទ្វេពន្ធភាព** ៖ បុគ្គលដែលមានសហព័ទ្ធ (ប្ដី-ប្រពន្ធ) ហើយពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។

* **អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត** ៖ នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ថ្ងៃ ពុំទាន់បានកន្លងផុតគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។[19] ដើម្បីជៀសវាងក្នុងករណីដែលនារីមានផ្ទៃពោះមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយលុបចោលហើយបានសម្រាលកូន ឬចំពោះករណីដែលមានលិខិតបញ្ជាក់ពីលារគ្មានផ្ទៃពោះ ពីវេជ្ជបណ្ឌិត។[20]

[18] មាត្រា៥ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

[19] មាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី

[20] មាត្រា៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ , មាត្រា២២៨ និង មាត្រា២៩៦ នៃក្រមរដ្ឋប្បវេណីបារាំង

*__ហាមឃាត់អាពាហ៍ពិពាហរវាងញាតិ__ ៖ អាពាហ៍ពិពាហ៍មិនអាចធ្វើឡើងរវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង ៣ ថ្នាក់រាប់ទាំងថ្នាក់ទី ៣ ផង និងរវាងញាតិពន្ធនៃខ្សែផ្ទាល់ព្រមទាំងរវាងសាខាញាតិពន្ធនៅក្នុង ៣ ថ្នាក់រាប់ទាំងថ្នាក់ទី៣ ផង។[21]

**ខ. ទម្រង់ ឬនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍**

**១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍** ៖ បុរស-នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍នៅពេលខាងមុខ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃ ឃុំ-សង្កាត់លំនៅដ្ឋានសាមីខ្លួនខាងនារី។ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យឲ្យបានហ្មត់ចត់នូវពាក្យសុំនោះ ដោយផ្អែកទៅលើលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ ។

**២. ការប្រកាសអាពាហ៍ពិពាហ៍** ៖ បន្ទាប់ពីបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវហើយមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដើម្បីយកទៅបិទផ្សាយជាសាធារណៈនៅលំនៅដ្ឋាននិងនៅសាលាឃុំ-សង្កាត់នៃសាមីខ្លួននារី និងនៅមុខលំនៅដ្ឋាន និងសាលាឃុំ/សង្កាត់សាមីខ្លួនបុរស។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល១០ថ្ងៃមុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឲ្យជនដែលមានប្រយោជន៍ក្នុងរឿងនេះអាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបានប្រសិនបើមានការមិនយល់ស្រប។ ផុតរយៈពេល១០ថ្ងៃអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានបើគ្មានការប្ដឹងជំទាស់។ បើមានបណ្ដឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែបណ្ដឹងជំទាស់នោះត្រូវបានសមត្ថកិច្ចដោះស្រាយចប់។

**៣. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍** ៖ បន្ទាប់ពីបានបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍បាន ចំនួន១០ថ្ងៃ ដោយមិនមានការប្ដឹងជំទាស់ទេ និង រៀបចំពិធីអាពាហ៍ពិពាហ៍ចប់សព្វគ្រប់ សាមីខ្លួនទាំងសងខាងត្រូវទៅសាលាឃុំ/សង្កាត់ ដើម្បីចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋានខាងលំនៅដ្ឋាននារី។ ការចុះសំបុត្រអាពាហ៍ពិពាហ៍ត្រូវមានសាក្សីពីរនាក់គ្រប់អាយុការទៅជាមួយ ដើម្បីបញ្ជាក់ពីការដឹងលឺ ឬធ្វើជាសាក្សី ។

**៤. ការចុះបញ្ជីអាពាហ៍ពិពាហ៍** ៖ បន្ទាប់ពីបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួច មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឲ្យសាមីខ្លួនប្ដី-ប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ច្បាប់ដើម និងចេញសេចក្ដីចម្លងតាមការស្នើសុំរបស់សាមីខ្លួនដើម្បីទុកប្រើប្រាស់។

[21] មាត្រា៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

### ១.៣.២. គ្មានសំបុត្រអាពាហ៍ពិពាហ៍

បុរស និងនារីបើគ្រាន់តែរៀបអាពាហ៍ពិពាហ៍ (រៀបការ) តាមបែបប្រពៃណី ទំនៀមទម្លាប់ ឬពិធីតាមបែបសាសនាណាមួយ ដោយមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ឬមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី នោះមិនអាចចាត់ទុកថា មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ជាប្តីប្រពន្ធឡើយ។ ការរួមរស់ជាប្តីប្រពន្ធដោយមិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់បែបនេះ ត្រូវបានហៅថាអនីតិសង្វាស់អាចនាំឲ្យកូនដែលកើតមក គឺជាកូនរបស់ម្តាយប៉ុន្តែអាចមិនមែនជាកូនរបស់ឪពុកឡើយមានន័យថាបើគ្មានអាពាហ៍ពិពាហ៍ស្របច្បាប់ទេ យើងមិនអាចសន្មត់ថាបុគ្គលណាមួយជាឪពុករបស់ក្មេងឡើយ ប៉ុន្តែគេអាចទទួលស្គាល់ចំណងបុត្តភាពនៅពេលក្រោយបាន។ ក្រៅពីចំណុចនេះក៏អាចនាំឲ្យភាគីម្ខាងលបលួចទៅរួមរស់ ឬ រួមសេវនកិច្ចជាមួយបុរស និង នារីផ្សេងទៀតហើយភាគីម្ខាងគ្មានសិទ្ធិប្តឹងភាគីម្ខាងទៀតឲ្យទទួលខុសត្រូវក្នុងបទល្មើសព្រហ្មទណ្ឌជាដើម។

# ជំពូកទី២

# នីតិវិធីក្នុងការដាក់ពាក្យបណ្តឹងរបស់សហព័ន្ធ

# ជំពូកទី២
# នីតិវិធីក្នុងការដាក់ពាក្យបណ្ដឹងរបស់សហព័ទ្ធ

នៅក្នុងពាក្យបណ្ដឹងរបស់សហព័ទ្ធបណ្ដឹងសុំលែងលះនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងចុះពីមូលហេតុដែលនាំឱ្យប្ដឹងសុំលែងលះគ្នាឱ្យបានច្បាស់លាស់ ម្យ៉ាងទៀតត្រូវសរសេរឈ្មោះ អាយុ ភេទ លំនៅរបស់អ្នកប្ដឹង និងរបស់ចុងចម្លើយឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលដល់តុលាការក្នុងការកោះអញ្ជើញឱ្យចូលខ្លួនដោះស្រាយ។ មានតែសហព័ទ្ធខ្លួនឯងទេ ដែលអាចធ្វើពាក្យបណ្ដឹងសុំផ្ដាច់ចំណងអាពាហ៍ពិពាហ៍ (រឿងលែងលះបានជនដទៃពុំអាចប្ដឹងជួសបានឡើយប្រសិនបើប្រពន្ធមានផ្ទៃពោះប្ដី នឹងអាចសុំលែងលះបានលុះត្រាតែប្រពន្ធនេះ) សម្រាលកូនរួចបាន១ឆ្នាំ ហើយការបន្ថយសិទ្ធិនេះមិនត្រូវអនុវត្តលើនារីទេ។ យោងតាមមាត្រា៩៨២[22] កថាខណ្ឌទី២ និយាយពីនីតិវិធីនៃការលែងលះគ្នាៈ

១-**ពាក្យបណ្ដឹងលែងលះគ្នា** អាចដាក់ទៅតុលាការដែលមានសមត្ថកិច្ច ដោយយោងតាមបញ្ញត្តិមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្ដីពិសេសលើរឿងក្ដីលែងលះគ្នា និង រឿងក្ដីអំពីបុគ្គភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។

២-**ភាគីអាចដាក់ពាក្យសុំលែងលះគ្នា** ទៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ឬទីសំណាក់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ១០ (សមត្ថកិច្ចសាលា ជម្រះក្ដីពិសេសលើរឿងក្ដីលែងលះគ្នា និង រឿងក្ដីអំពីបុគ្គភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។ ក្នុងករណីនេះក្រុមប្រឹក្សាឃុំសង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) គិតពីថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្ដឹងលែងលះគ្នាហើយក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបញ្ជូនពាក្យបណ្ដឹងនោះទៅតុលាការជាបន្ទាន់ ។[23]

## ២.១. ការដាក់បណ្ដឹងទៅអាជ្ញាធរដែនដី

[22] មាត្រ៩៨២ បណ្ដឹងនៃការលែងលះគ្នា

[23] ដោយអនុលោមតាមមាត្រា ៤១ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសាររបស់ប្រទេសកម្ពុជា កថាខណ្ឌទី ១ ន មាត្រានេះ បញ្ញត្តអំពីសមត្ថកិច្ចសាលាជម្រះក្ដីរបស់តុលាការចំពោះរឿងក្ដីលែងលះ ដោយផ្អែកលើមាត្រា ១០ នៃក្រម នីតិវិធីរដ្ឋប្បវេណី ។ កថាខណ្ឌទី ២ នៃមាត្រានេះក៏ដូចគ្នាផងដែរ ដោយយកមាត្រា ៤២ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជាជាមូលដ្ឋាន កថាខណ្ឌទី ២ ចែងអំពីការបែងចែកតួនាទីរបស់តុលាការដែលមានសមត្ថកិច្ច និង ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងនីតិវិធីលែងលះ ។ (មាត្រាពាក់ព័ន្ធ)មាត្រា ៤១ និង មាត្រា ៤២ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

**ក. ការលែងលះដោយមានការព្រមព្រៀង** មានន័យថាភាគី (ប្តីនិងប្រពន្ធ) នៃអាពាហ៍ពិពាហ៍បានឯកភាពគ្នាដោយស្ម័គ្រចិត្តរំលាយចំណងអាពាហ៍ពិពាហ៍ហើយភាគី ត្រូវដាក់ពាក្យសុំលែងលះដោយភ្ជាប់ជាមួយកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្ត ទៅសាលាដំបូងរាជធានី/ខេត្ត បើតុលាការរកឃើញថាភាគីទាំងពីរមានឆន្ទៈព្រមព្រៀងពិតប្រាកដក្នុង ការរំលាយចំណងអាពាហ៍ពិពាហ៍នោះតុលាការ នឹងសម្រេចឲ្យភាគីលែងលះគ្នាតាមរយៈអំណាច (ដីកាសម្រេច)[24] ការលែងលះដោយការព្រមព្រៀងត្រូវបានកំណត់នៅក្នុងមាត្រា៣ កថាខណ្ឌទី១ នៃ តារាងឧបសម្ព័ន្ធត្រង់ចំណុចទី៥ ផ្នែកទី៤ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ ហេតុនេះចំពោះការលែងលះដោយការព្រមព្រៀងគ្នាត្រូវប្រព្រឹត្តទៅតាមច្បាប់នេះ។ នៅក្នុងរឿងក្តីនៃការលែងលះដោយការព្រមព្រៀងមានតែភាគី ប្តីឬប្រពន្ធ ទេដែលជាអ្នកចាប់ផ្តើមដំណើរការនីតិវិធីដោះស្រាយដំបូងតាមរយៈ ការដាក់ពាក្យសុំទៅតុលាការមិនមែនជារឿងក្តីដែលតុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹងដោយឆន្ទានុសិទ្ធិឡើយ។ មានន័យថាកម្មវត្ថុនៃការសម្រេច និងការចេញដីកា គឺភាគីជាអ្នកកំណត់នៅក្នុងពាក្យសុំហើយតុលាការអាចចាប់ផ្តើមជម្រះក៏បានទាល់តែទទួលបានពាក្យសុំជាមុនសិន ។ ទន្ទឹមនឹងពាក្យសុំភាគីត្រូវមានកិច្ចព្រមព្រៀងលែងលះភ្ជាប់មកជាមួយផងដែរ។

ដូចនេះយើងនឹងលម្អិតទៅលើកិច្ចព្រមព្រៀងលែងលះ និងពាក្យសុំលែងលះដូចខាងក្រោមនេះ៖

- **កិច្ចព្រមព្រៀងលែងលះ**

ដើម្បីបញ្ជាក់ពីឆន្ទៈត្រូវគ្នាភាគីទាំងសងខាងនៃចំណងអាពាហ៍ពិពាហ៍ត្រូវធ្វើកិច្ចព្រមព្រៀងលែងលះ។ កិច្ចព្រមព្រៀងលែងលះនេះ គឺជាលិខិតមួយ ដែលគូរភាគីទាំងពីរ (ប្តី/ប្រពន្ធ) បានព្រមព្រៀងគ្នាធ្វើដោយឆន្ទៈពិតប្រាកដពុំមានការបង្ខិតបង្ខំពីភាគីណាម្ខាងឡើយ។ នៅក្នុងកិច្ចព្រមព្រៀងលែងលះនេះភាគីប្តីប្រពន្ធអាចធ្វើជាទម្រង់នៃការសម្តែងឆន្ទៈព្រមព្រៀងលែងលះស្តែងឡើងក្រោមរូបភាពពីរ គឺព្រមព្រៀងជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់ ។

**ទម្រង់ជាលាយលក្ខណ៍អក្សរ៖** សហព័ទ្ធទាំងពីរអាចរៀបចំកិច្ចព្រមព្រៀងលែងលះគ្នាជាមុនហើយភ្ជាប់ទៅជាមួយពេលយកពាក្យសុំដាក់នៅតុលាការ ។ ជាទូទៅកិច្ចព្រមព្រៀងនេះភាគច្រើនសរសេរនូវខ្លឹមសារជាសារធាតុចម្បង គឺឆន្ទៈនៃការព្រមព្រៀងលែងលះ និង ជាយថាហេតុការបែងចែក សិទ្ធិអំណាចមេបាលើកូនបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនការបែងចែកទ្រព្យសម្បត្តិរួម និង ការនាំយកពាក្យសុំទៅដាក់នៅតុលាការមានសមត្ថកិច្ចដើម្បីទទួលបានដីកាសម្រេចជាអាទិ៍ ។

[24] យោងតាមមាត្រា០៣ កថាខណ្ឌ២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

**ទម្រង់ដោយផ្ទាល់មាត់៖** ទម្រង់នេះភាគច្រើនត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋដែលមិនសូវយល់ដឹងអំពីច្បាប់ និង មិនមានលទ្ធភាពពឹងពាកមេធាវី ។ តាមរយៈទម្រង់នេះនៅពេលដែលប្តីប្រពន្ធសម្រេចថាលែងលះគ្នា ពួកគាត់បណ្តើរគ្នាទៅតុលាការហើយថ្លែងការណ៍អំពីឆន្ទៈនៃការព្រមព្រៀងលែងលះរបស់ខ្លួន នៅចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យសុំនោះតំណាលគ្នា នឹងដាក់ពាក្យសុំ ។

តាមទ្រឹស្តីពិតរបស់ច្បាប់ឆន្ទៈនៃការព្រមព្រៀងរបស់ប្តីប្រពន្ធ គឺជារឿងដ៏សំខាន់បំផុតដែលចៅក្រមត្រូវការវែកញែក និង ស្រាវជ្រាវដើម្បីទទួលស្គាល់ថាតើការព្រមព្រៀងនោះបានការពារនូវផលប្រយោជន៍រៀងៗខ្លួនរបស់ភាគីដោយយុត្តិធម៌ថ្មីនៅ?(ពិសេសភាគីខាងប្រពន្ធ)ពីព្រោះនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន អំពើហិង្សាក្នុងគ្រួសារដែលតែងតែកើតឡើងជាញឹកញាប់ ។

❖ **ពាក្យសុំលែងលះ**

នៅក្នុងពេលពាក្យសុំលែងលះដោយការព្រមព្រៀងភាគីណាម្ខាងដែលមាន គោលបំណងចង់ដាក់ពាក្យសុំលែងលះអាចដាក់ទៅតុលាការតែត្រូវបំពេញទម្រង់បែបបទ នៃការដាក់ពាក្យសុំតាមបញ្ញត្តិ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបានកំណត់ពាក្យសុំលែងលះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក៏បានលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

➢ **ពាក្យសុំជាលាយលក្ខណ៍អក្សរ**

ពាក្យសុំលែងលះអាចត្រូវបានធ្វើឡើងដោយអ្នកដាក់ពាក្យសុំ ឬ តាមរយៈអ្នកតំណាងដោយអាណត្តិរបស់ខ្លួនក៏បានប្រសិនបើអ្នកដាក់ពាក្យសុំបានស្នើសុំឱ្យមានដោយខ្លួនរបស់គេផ្ទាល់។ ម៉្យាងទៀតអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងដោយអាណត្តិត្រូវរៀបចំលិខិតនៃពាក្យសុំមុន និងដាក់ទៅតុលាការត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ៖

**ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកដាក់ពាក្យសុំ៖** ប្តី ឬប្រពន្ធដែលយកពាក្យសុំមកដាក់ត្រូវសរសេរឈ្មោះ ភេទ អាយុ សញ្ជាតិ និងត្រូវសរសេរ អាស័យដ្ឋាន(ផ្ទះលេខ...ផ្លូវ... ភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ...ខេត្ត/រាជ ធានី) នៅក្នុងពាក្យសុំ។ ប៉ុន្តែប្រសិនបើមានអ្នកតំណាងដោយអាណត្តិដែលច្បាប់បានកំណត់ត្រូវសរសេរឈ្មោះ និង អាស័យដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះនៅក្នុងពាក្យសុំផងដែរ។ ចំពោះខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ៖ ជាការសរសេរនូវអ្វីដែលអ្នកដាក់ពាក្យសុំបានទាមទារហើយក៏ជាការបញ្ជាក់អំពីទំហំនៃរឿងក្តីដែលត្រូវឱ្យតុលាការលើកយកមកវិនិច្ឆ័យ និងសម្រេចសេចក្តីផងដែរ។ ទាក់ទិននឹងខ្លឹមសារនៃការសរសេរពាក្យសុំលែងលះដោយការព្រមព្រៀង ចំណុចនេះត្រូវសរសេរឱ្យបានជាក់លាក់ ស្នើសុំឱ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំឱ្យអ្នកដាក់ពាក្យសុំលែងលះជាមួយភាគីម្ខាងទៀត(ការទាមទារចម្បង)

និង ជាយថាហេតុការជាមួយកូនរបស់អ្នកដែលមិនមានសិទ្ធិ អំណាចមេបា? ការទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិ (ការទាមទារបន្ទាប់បន្សំជាអាទិ៍)។ ទាមទារផ្សេងទៀតដូចជាការបែកចែកសិទ្ធិអំណាចមេបាលើការចូលជួបប្រាស្រ័យទាក់ទង ។

**អង្គហេតុជាមូលហេតុនៃការទាមទារ៖** គឺសរសេរជាមូលដ្ឋានគតិយុត្ត នៃការទាមទាររបស់ភាគីក្នុងរឿងក្តីនៃការលែងលះដោយការព្រមព្រៀង មូលដ្ឋានគតិយុត្តនៃការទាមទារដូចជាការលែងលះជាអង្គហេតុដែលអាចទាមទារលែងលះបាន គឺអង្គហេតុនៃការកើតឡើងនៃចំណងអាពាហ៍ពិពាហ៍ដែលបញ្ជាក់តាមសំបុត្រអាពាហ៍ពិពាហ៍ និង អង្គហេតុនៃការសម្តែងឆន្ទៈ នៃការព្រមព្រៀងលែងលះគ្នាដែលបញ្ជាក់ដោយកិច្ចព្រមព្រៀង ឬការអះអាងរបស់ភាគី។ រីឯការចាត់ចែងចំពោះកូនជាអង្គហេតុដែលអាចទាមទារឱ្យតុលាការសម្រេចចាត់ចែងចំពោះកូន គឺជាអង្គហេតុដែលបញ្ជាក់ថាតាមចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធបានបង្កើតកូនដែលបច្ចុប្បន្នជាអនីតិជនដែលអង្គហេតុនេះជាទូទៅអាចបញ្ជាក់ដោយសំបុត្រកំណើតរបស់កូន។ លើសពីនេះទៅទៀតគឺការចាត់ចែងទ្រព្យសម្បត្តិ គឺជាអង្គហេតុដែលអាចទាមទាឱ្យមានការចាត់ចែងទ្រព្យសម្បត្តិ ជាអង្គហេតុដែលបញ្ជាក់ពីការមានទ្រព្យសម្បត្តិរួមគ្នា (ទ្រព្យអកម្ម និង ទ្រព្យសកម្ម) ដែលអង្គហេតុបញ្ជាក់ដោយឯកសារនានាដូចជា ប័ណ្ណសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ ឬលិខិតម្ចាស់យានយន្តជាអាទិ៍។ នៅក្នុងការអនុវត្តជាក់ស្តែងទម្រង់នៃពាក្យសុំនេះគឺមិនបានសរសេរឱ្យបានត្រឹមត្រូវតាមស្មារតីនេះទេហើយ ការប្រើប្រាស់ពាក្យក៏មិនបានត្រឹមត្រូវដែរជាពិសេសការហៅឈ្មោះភាគីនៅក្នុងរឿងក្តីលែងលះដោយការព្រមព្រៀង គឺជនដាក់ពាក្យសុំ ឬអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតមិនមែនដើមចោទ និងចុងចម្លើយដូចនីតិវិធីបណ្តឹងធម្មតាទេ ។

- **ពាក្យសុំដោយផ្ទាល់មាត់**

ក្នុងករណីដែលភាគីម្ខាង នៃអ្នកដាក់ពាក្យសុំដែលមានភាពចាំបាច់ណាមួយមិនបាន បំពេញទៅតាមលក្ខខណ្ឌទម្រង់ខាងលើនេះ ដូច្នេះពួកគាត់អាចធ្វើពាក្យសុំដោយផ្ទាល់មាត់ដោយគ្រាន់តែអ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុច[25]ដែលមានរៀបរាប់ខាងលើនេះនៅចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យសុំហើយក្រឡាបញ្ជីនោះធ្វើការកត់ត្រាទុកនៅក្នុងកំណត់ហេតុកំណត់ហេតុនេះត្រូវចាត់ទុកថាជាលិខិតនៃពាក្យសុំ[26] នៅពេលដាក់ពាក្យសុំ ប្រសិនបើអ្នកដាក់ពាក្យសុំមានភស្តុតាងជាឯកសារដូចជាសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ សំបុត្របញ្ជាក់កំណើតកូន ឬ ឯកសារនានាដែលបញ្ជាក់ពីទ្រព្យសម្បត្តិជាអាទិ៍។ គាត់ត្រូវដាក់ជូនតុលាការនូវ

[25] ពាក្យសុំជាលាយលក្ខណ៍អក្សរ

[26] មាត្រា២៦ កថាខណ្ឌ៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១១

ឯកសារច្បាប់ ដើម ឬឯកសារដែលមានសេចក្តីបញ្ជាក់ដើម្បីឱ្យតុលាការងាយស្រួលក្នុងការពិនិត្យនិងឆាប់ទទួលស្គាល់អង្គហេតុ ។

**ការពិនិត្យពាក្យបណ្តឹង**

១- ក្នុងករណីដែលពាក្យបណ្តឹងផ្ទុយនឹងបញ្ញត្តិ នៃកថាខណ្ឌទី២ មាត្រា៧៥ (របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងខាងលើនេះ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្លះចំពោះពាក្យប្តឹងក្នុងអំឡុងពេលនោះ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្តឹងមិនត្រូវបានបង់តាមបញ្ញត្តិនៃមាត្រា៦១ (ពន្ធដាក់ពាក្យសុំ )។

២- ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះទេតុលាការត្រូវលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច ។

៣- ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះអាចប្តឹងជំទាស់បាន ។[27]

**ការកោះហៅគូភាគី** ក្រោយពីពិនិត្យពាក្យសុំឃើញថាត្រឹមត្រូវហើយនោះតុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទកោះហៅគូភាគីឱ្យចូលមកតុលាការដើម្បីដំណើរការនីតិវិធីរឿងក្តីលែងលះនោះ។ ដូចនេះភាគីត្រូវមានករណីយកកិច្ចចូលមកបង្ហាញខ្លួន នៅក្នុងតុលាការតាមដីកាកោះឱ្យចូលតាមកាលបរិច្ឆេទដែលបានកំណត់។ ក្នុងករណីដែលត្រូវបានកោះហៅ ដោយតុលាការដែលបានរៀបរាប់ខាងលើនេះមិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ នោះតុលាការអាចពិន័យជាប្រាក់ចំនួនមិន លើសពី១០០០០០០ (មួយលាន ) រៀលបាន[28]។ ការកោះហៅនេះ ដើម្បីឱ្យអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀតអះអាងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដើម្បីប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញចាំបាច់តុលាការអាចកោះហៅ អ្នកដាក់ពាក្យសុំភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញចាំបាច់បានដោយកំណត់កាលបរិច្ឆេទ ចំពោះកាលបរិច្ឆេទដើម្បីឱ្យអ្នកដាក់ពាក្យសុំឬភាគីម្ខាងទៀត អះអាងតុលាការទទួលស្គាល់ឱ្យសាមីខ្លួនពឹងអ្នកតំណាងដោយអាណត្តិបង្ហាញខ្លួន ជំនួសដោយមិនចាំបាច់បង្ហាញខ្លួនចំពោះមុខតុលាការដូចនីតិវិធីរដ្ឋប្បវេណីដែរ( កថាខណ្ឌទី១ មាត្រា៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី )ប៉ុន្តែចំពោះកាលបរិច្ឆេទប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពអង្គហេតុពី

[27] មាត្រា៧៨ មានអត្ថន័យដូចគ្នានឹងក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា១៣៧ នៅពេលទទួលបណ្តឹង ជាបឋម តុលាការត្រូវពិនិត្យលើទម្រង់នៃពាក្យបណ្តឹង ហើយបើឃើញថា មានភាពខ្វះចន្លោះផ្នែកទម្រង់ ភាពខុសឆ្គងនៃការបង់ពន្ធនៃការដាក់ពាក្យសុំ នោះ តុលាការត្រូវបង្គាប់ឱ្យអ្នកធ្វើបណ្តឹង កែតម្រូវ ក្នុងអំឡុងពេលសមរម្យ។ អំឡុងពេលសមរម្យ ឬ អាស្រ័យដោយឆន្ទានុសិទ្ធិរបស់តុលាការ ។ ការមិនកែតម្រូវ គឺជាមូលហេតុនៃការលើកបណ្តឹងចោលដោយដីកាសម្រេច ។

[28] មាត្រា២៩ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

អ្នកដាក់ពាក្យសុំភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ ឃើញថាចាំបាច់វិញមានភាពចាំបាច់ឱ្យសាមីខ្លួនដែលត្រូវបានកោះហៅបង្ហាញខ្លួនមកតុលាការ និងពន្យល់តុលាការអំពីកាលៈទេសៈមិនមែនដោយអ្នកតំណាងដោយអាណត្តិទេ គឺដោយផ្ទាល់ខ្លួនដើម្បីឱ្យតុលាការក្តោបនូវអង្គហេតុពិតនៅក្នុងរឿងក្តី។ម្យ៉ាងទៀតក្នុងករណីដែលសាមីខ្លួនត្រូវបង្ហាញខ្លួនអ្នកតំណាងដោយអាណត្តិក៏អាចចូលរួមជាមួយសាមីខ្លួនបានដែរ ។

**ខ. ការលែងលះដោយគ្មានការព្រមព្រៀង** ដំណើរការនីតិវិធីត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៧។ ភាគីម្ខាង(ប្តី/ប្រពន្ធ)នៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្តឹងទាមទារលែងលះគ្នាទៅសាលាដំបូងរាជធានី/ខេត្ត ហើយបើតុលាការរកឃើញថាមានមូលហេតុ និងភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ថាភាគីទាំងពីរពិតជាមិនអាចរួមរស់នៅជាមួយគ្នាជាប្តី/ប្រពន្ធទៀតបាននោះ តុលាការត្រូវសម្រេចឲ្យភាគីលែងលះគ្នា តាមរយៈអំណាច «សាលក្រម»[29] បើភាគីណាមួយដែលជាសហព័ទ្ធ (ប្តី/ប្រពន្ធ) ដែលមានបំណងពិតប្រាកដក្នុងការលែងលះដោយផ្អែកលើមូលហេតុត្រឹមត្រូវអាចដាក់ពាក្យបណ្តឹងទៅតុលាការដែលមាន សមត្ថកិច្ចដោយយោងតាមមាត្រា១០ សមត្ថកិច្ចជំរះក្តីពិសេសក្នុងរឿងក្តីលែងលះគ្នា និងរឿងក្តីដែលលែងលះគ្នា និង រឿងក្តីអំពីបុគ្គលភាព នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន[30] ។ ពោលគឺសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ច នៅលំនៅឋានរបស់ភាគី នៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធ នឹងបណ្តឹងនោះ។ ម៉្យាងទៀតតុលាការអាចដំណើរការរឿងក្តីនេះបានតាមការដាក់ពាក្យបណ្តឹរបស់ដើមបណ្តឹង ហើយនៅក្នុងបណ្តឹងត្រូវសរសេរឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់ដែលច្បាប់បានកំណត់ផងដែរ។

**ការសរសេរពាក្យបណ្តឹងលែងលះ** ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយត្រូវរៀបរាប់អំពីមូលហេតុដែលសហព័ទ្ធសុំលែងលះគ្នាហើយត្រូវចុះហត្ថលេខាដោយសហព័ទ្ធដែលជាអ្នកប្តឹង។ សហព័ទ្ធដែលជាអ្នកប្តឹងហៅថាភាគីដើមបណ្តឹង ឬ សហព័ទ្ធដែលទទួលរងការប្តឹងនោះហៅថាចុងចម្លើយ។ នៅក្នុងពាក្យបណ្តឹងលែងលះត្រូវធ្វើឡើងដោយសរសេរនៅរាល់ចំណុចដូចដែលមានចែងនៅក្នុងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះការសរសេរពាក្យបណ្តឹងលែងលះដែលធ្វើឡើងជាលាយលក្ខណ៍អក្សរមិនខុសគ្នាទៅ នឹងការសរសេរពាក្យសុំលែងលះនៅជំពូកទី២ ខាងលើនោះទេ គឺត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់។ ដោយទៅតាមសេចក្តីប្រកាសរបស់ក្រសួងយុត្តិធម៌ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧ ភាគីដើមចោទត្រូវបង់ពន្ធពាក្យបណ្តឹងលែងលះត្រូវបង់ចំនួន ៥៥០០០រៀល នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់មកតុលាការ។ បន្ថែមពីនេះទៅទៀតភាគីដើមចោទត្រូវបង់ប្រាក់ប្រដាក់ក្តីក្រៅពីពន្ធដូចជាច់នៅទឹកប្រាក់បំបាច់ ? ដើម្បីឱ្យតុលាការពិនិត្យភស្តុតាងការបញ្ជូនឯក

[29] យោងតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[30] មាត្រា៩៤២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សារ ឬ ចំនួនទឹកប្រាក់សម្រាប់សាហ៊ុយធ្វើដំណើរ នឹង សាហ៊ុយ ស្នាក់នៅរបស់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីមានការពិនិត្យភស្តុតាង នឹងសោហ៊ុយសកម្មភាពផ្សេងទៀតតាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី ដើម្បីដំណើរការស៊ើបអង្កេតរឿងនោះ[31] ។ ចំពោះចំនួនប្រាក់ប្រដាប់ក្ដីសម្រាប់ភាគីដែលទទួលបន្ទុកចេញ គឺភាគីដែលចាញ់ក្ដីជាអ្នកទទួលបន្ទុកចេញសងវិញ[32]។ កំណត់សម្គាល់បណ្ដឹងរដ្ឋប្បវេណីទូទៅច្បាប់តម្រូវឱ្យភាគីនីមួយៗ ជាអ្នកស្វែងរកភស្តុតាងដាក់ជូនទៅតុលាការខ្លួនឯង ហើយនៅក្នុងពាក្យបណ្ដឹង បើភាគីទាមទារចំណុចណាតុលាការ និងសម្រេចសេចក្ដីតាមពាក្យសុំត្រង់ ចំណុចនោះដោយផ្អែកលើភស្តុតាងដែលភាគីបានបង្ហាញដល់តុលាការប៉ុណ្ណោះ។ ដោយឡែកចំពោះចំណុចណាដែលភាគីមិនបានទាមទារ ឬភ្លេចទាមទារតុលាការមិនបានសម្រេចចំណុចដែលមិនទាមទារឡើយ ។

**កន្លែងទទួលពាក្យបណ្ដឹង** ជាទូទៅបណ្ដឹងនៃការលែងលះទីកន្លែងនៃការដាក់ពាក្យបណ្ដឹងមានពីរ ដើម្បីឱ្យភាគីជ្រើសរើសដាក់ពាក្យបណ្ដឹងសុំលែងលះ។ ដូចនេះភាគីអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ទៅតុលាការរាជធានី ខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់នៅលំនៅដ្ឋានភាគីរបស់ប្ដី ឬ ប្រពន្ធ ។

ករណីដែលលំនៅឋានរបស់ភាគីមិនស្ថិតនៅក្នុងប្រទេសកម្ពុជា ឬ លំនៅឋាននៅប្រទេសកម្ពុជាមិនពិតប្រាកដទេ តុលាការដែលមានសមត្ថកិច្ចជម្រះក្ដីជាកំណត់តាមទីសំណាក់របស់ភាគីចុងចម្លើយ បើពុំមានទីតាំងសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដនោះទេតុលាការត្រូវកំណត់តាមលំនៅដ្ឋានចុងក្រោយ ។ ហេតុផលនៃតម្រូវការនេះ គឺដើម្បីធានាចុងចម្លើយ នឹង ទទួលបានការជូនដំណឹងថាប្ដី ឬ ប្រពន្ធរបស់គេបានពាក្យបណ្ដឹងសុំលែងលះរូបគេហើយ។ បើសិនជាភាគីដើមចោទ និងភាគីចុងចម្លើយរស់នៅកន្លែងជាមួយគ្នានោះវិធាននេះមិនបង្កើតជាបញ្ហាអ្វីទេ។ ប៉ុន្តែបើភាគីដើមចោទ និង ចុងចម្លើយរស់នៅដោយឡែកពីគ្នា វិធាននេះអាចនឹងបង្កការលំបាកដល់សហព័ទ្ធ ដើមចោទ ។ ការលំបាកអាចកើតឡើងបើសិនសហព័ទ្ធដើមចោទ ការលំបាកអាចកើតឡើងបើសិនជាសហព័ទ្ធដើមចោទត្រូវធ្វើដំណើរយ៉ាងឆ្ងាយដើម្បីដាក់ពាក្យបណ្ដឹង និង ដើម្បីចូលរួមនៅក្នុងនីតិវិធី ។ លើសពីនេះសហព័ទ្ធដែលជាដើមចោទអាចនឹងមិនដឹងពីទីកន្លែងដែលចុងចម្លើយរស់នៅ ។ ការលំបាកនឹងអាចកើតឡើងដែលប្រសិនបើមេឃុំ ចៅសង្កាត់ស្គាល់ហើយមានទំនាក់ទំនងល្អជាមួយចុងចម្លើយ ដោយហេតុថាគេរស់នៅសហគមន៍ជាមួយគ្នាហើយមន្ត្រីទាំងនោះមិនបានស្គាល់សហព័ទ្ធដើមចោទដែលនៅឆ្ងាយពីនោះ។ សភាពការណ៍បែបនេះនឹងបង្កឱ្យមានការលម្អៀងទៅរកចុងចម្លើយ ។

### ២.១.១. ការសម្របសម្រួលនៅមូលដ្ឋាន

[31] មាត្រា៦២ នៃក្រមនីតីវីធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[32] មាត្រា៦៤ នៃក្រមនីតីវីធិរដ្ឋប្បវេណី ឆ្នាំ២០០៦

យោងតាមក្រមរដ្ឋប្បវេណីនៃមាត្រា៩៨២ ចំពោះការលែងលះរបស់សហព័ទ្ធអាចធ្វើទៅបានលុះត្រាតែធ្វើទៅតាមផ្លូវតុលាការ ពោលពាក្យបណ្តឹងលែងលគ្នាអាចដាក់ទៅតុលាការដែលមានសមត្ថកិច្ច ឬមុនពេលលែងលះភាគីត្រូវដាក់សុំលែងលះទៅក្រុមប្រឹក្សាឃុំសង្កាត់ខាងលំនៅដ្ឋាន ឬទីសំណាក់របស់ភាគីនៃទំនាក់ទំនង នឹងបណ្តឹងនោះឬលំនៅឋាននាពេលដែលភាគីទទួលមរណភាព។ បើលំនៅឋានដែលបានកំណត់មិនស្ថិតនៅព្រះរាជាណាចក្រកម្ពុជា ឬលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេសមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមទីសំណាក់។ បើមិនមានទីសំណាក់ឬទីសំណាក់មិនពិតប្រាកដសាលាជម្រះក្តី ត្រូវកំណត់ទីកន្លែងជាចុងក្រោយគេនៃភាគី។ ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១០ អំពីកាលែងលះគ្នាជាសមត្ថកិច្ចរបស់សាលាដំបូងរាជ/ខេត្តនៃ ខាងលំនៅរបស់ចុងចម្លើយ។

ក. ការលែងលះដោយមានការព្រមព្រៀង

➢ **ក្រុមប្រឹក្សាឃុំ សង្កាត់**

នៅក្នុងដំណាក់កាលនេះក្រុមប្រឹក្សាឃុំ សង្កាត់មិនមានសមត្ថកិច្ចអ្វី សម្រេចឱ្យគូភាគីលែងលះគ្នាបែងចែកទ្រព្យសម្បត្តិ កំណត់អ្នកមានអំណាចមេបាលើកូន និង ការបង់អាហារកាតិព្វកិច្ចនោះឡើយ។ ការដាក់ពាក្យសុំទៅក្រុម ប្រឹក្សាឃុំ សង្កាត់គ្រាន់តែជាជម្រើសរបស់ភាគីប៉ុណ្ណោះ ពោលគឺថាសហព័ទ្ធអាចដាក់ពាក្យសុំដោយផ្ទាល់ទៅតុលាការមានសមត្ថកិច្ចតែម្តងក៏បាន ។ ប៉ុន្តែប្រសិនបើភាគីណាម្ខាងបានសម្រេចចិត្តដាក់ពាក្យសុំមកកាន់ក្រុមប្រឹក្សាឃុំ សង្កាត់នាលំនៅដ្ឋានប្តី ឬប្រពន្ធ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវដើរតួនាទីជាបឋម គឺជាអ្នកផ្សះផ្សារគូភាគីជាមុនសិន ការផ្សះផ្សារគឺ ធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យគូភាគីត្រូវរ៉ូវគ្នា ហើយធ្វើការសះជានឹងគ្នាដើម្បីបន្តការរស់នៅក្នុងជីវភាពជាប្តីប្រពន្ធសារជាថ្មី។ ដូច្នេះក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវតែខិតខំធ្វើយ៉ាងណាក្នុងការបញ្ចុះបញ្ចូលគូភាគីឱ្យសះជានឹងគ្នាបានក្នុងអំឡុងពេលតាមការកំណត់របស់ច្បាប់១៥ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ[33]។ ប្រសិនបើគូភាគីត្រូវរ៉ូវគ្នាក្រោយពីទទួលបានការផ្សះផ្សាពីក្រុមប្រឹក្សាឃុំ សង្កាត់នាំឱ្យគូភាគីយល់ព្រមសះជានឹងគ្នា ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវកត់ត្រា ពីអ្វីដែលគូភាគីបានសះជានឹងគ្នានោះទុកធ្វើជាកំណត់ហេតុ និង ធ្វើលិខិតកិច្ចសន្យាឱ្យភាគីទាំងពីរដើម្បីទទួលយកការផ្សះផ្សារ។ ទន្ទឹមនឹងការផ្សះផ្សារនេះ ប្រសិនបើការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បានធ្វើអស់លទ្ធភាពហើយគូភាគីនៅតែទទូចចង់ធ្វើការលែងលះ និង គ្មានសង្ឃឹមថានឹងអាចសះជានឹងគ្នា ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់មានតែធ្វើការបញ្ជូនពាក្យសុំទៅតុលាការដើម្បីឱ្យតុលាការមានចំណាត់ការបន្តទៅតាមនីតិវិធីច្បាប់។

[33] មាត្រា៩៨២ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

➢ **សាលដំបូងរាជធានី-ខេត្ត**

ក្រោយពីក្រុមប្រឹក្សាឃុំសង្កាត់ធ្វើការផ្សះផ្សារមិនបានសម្រេចហើយពាក្យសុំក៏ត្រូវបាន បញ្ជូនមកតុលាការនៃលំនៅដ្ឋានរបស់ប្តីឬប្រពន្ធនោះ ដូច្នេះតុលាការនឹងបន្តចំណាត់ការនេះពីព្រោះថាមានតែតុលាការទេដែលអាចសម្រេចឱ្យគូភាគីលែងលះគ្នា ឬមិនអាចលែងលះគ្នាបានដោយការចេញដីកាសម្រេចតាមពាក្យសុំ។ មុននឹងឈានទៅដល់ ដំណើរការនីតិវិធីជំនុំជម្រះដោយចៅក្រមដែលបានទទួលតាមលំដាប់វេនដែលបានកំណត់ទុកជាមុនដោយដីកាសម្រេចប្រចាំឆ្នាំតាមការកំណត់មាត្រា២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីដូចនេះពាក្យសុំនោះត្រូវឆ្លងកាត់ការពិនិត្យជាមុនសិន។

ខ. ការលែងលះដោយគ្មានមានការព្រមព្រៀង

➢ **ការផ្សះផ្សារ**

ក្រោយពីក្រុមប្រឹក្សាឃុំ-សង្កាត់ ឬតុលាការទទួលបានពាក្យបណ្តឹងជាផ្លូវការដែលភាគីទាមទារលែងលះគ្នាក្រុមប្រឹក្សាឃុំ-សង្កាត់ និងតុលាការត្រូវមាននីតិវិធីមួយគឺការផ្សះផ្សារ។ មុននឹងធ្វើការផ្សះផ្សារត្រូវពិនិត្យមើលសំណុំឯកសារដែលពាក់ព័ន្ធ គឺសំបុត្រអាពាហ៍ពិពាហ៍ដើម្បីបញ្ជាក់ថាពួកគេពិតជាប្តីប្រពន្ធស្របតាមច្បាប់។

➢ **ការផ្សះផ្សារនៅថ្នាក់ឃុំ /សង្កាត់**

នៅពេលដែលមានភាគីណាម្ខាង (ប្តី/ប្រពន្ធ) បានដាក់ពាក្យបណ្តឹងលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់ឲ្យដោះស្រាយមុនដាក់ទៅតុលាការ មន្ត្រីត្រូវសាកល្បងធ្វើការផ្សះផ្សារក្នុងរយៈពេល ១៥ថ្ងៃក្រោយពីទទួលពាក្យបណ្តឹង។ ប៉ុន្តែបើភាគីទាំងពីរមិនព្រមបន្តការរួមរស់នៅជាមួយគ្នាទេ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងសុំលែងលះហើយត្រូវបញ្ជូនទៅតុលាការជាបន្ទាន់។ បើទោះបីជាក្រមរដ្ឋប្បវេណីពុំបានចែងពីការផ្សះផ្សារត្រូវធ្វើឡើងច្រើនដង ឬក៏ដោយក៏ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាចព្យាយាមធ្វើការផ្សះផ្សារជាច្រើនដងមុននឹងបញ្ជូនរឿងទៅតុលាការ។

### ២.១.២. ការចេញសេចក្តីសម្រេច

នៅក្នុងរឿងក្តីលែងលះតាមការព្រមព្រៀង ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយដីកាសម្រេច ។ តាមបញ្ញត្តិច្បាប់ ដើម្បីចេញដីកាសម្រេចអំពីរឿងក្តីតុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ពីព្រោះរឿងក្តីប្រភេទនេះជារឿងក្តីដែលមិនភាពស្មុគស្មាញ និងគ្មានចំណុចវិវាទដោយហេតុថាភាគីបានព្រមព្រៀងគ្នារួចរាល់។ ម្យ៉ាងទៀតការលែងលះ គឺជារក្សាការសម្ងាត់ផ្ទាល់ខ្លួនរបស់ភាគីហេតុនេះហើយដើម្បីចេញដីកា សម្រេចឱ្យលែងលះតាមការព្រមព្រៀងមិនចាំបាច់ទាញហេតុផលជាសាធារណៈឡើយ។ ប៉ុន្តែក្នុងករណីដែលតុលាការយល់ឃើញចាំបាច់ សម្រាប់នីតិវិធីតុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់

ដោយឆន្ទានុសិទ្ធិបាន។ ដីកាសម្រេចឱ្យលែងលះតាមការព្រមព្រៀងដែលជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជាគោលការណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសេចក្តីសម្រេចបញ្ចប់ និងសម្អាងហេតុហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនោះ។ ដីកាសម្រេចនេះនឹងមានតម្លៃដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរនៅក្នុងការសម្រេចសេចក្តីនេះដែរ អ្វីដែលជាមូលដ្ឋានដែលចៅក្រមលើកយកមកសម្រេចអំពីការលែងលះនោះគឺចៅក្រមធ្វើការពិចារណាទៅលើចំនុចជាច្រើនដែលក្នុងនោះជាដំបូងនោះ ចៅក្រមពិចារណាទៅលើស្ថានភាពគតិយុត្តនៃទំនាក់ទំនងប្តីប្រពន្ធនៃការលែងលះនោះ មានន័យថាតើប្តីប្រពន្ធនោះរៀបការត្រឹមត្រូវតាមច្បាប់ដូចជាបានចុះសំបុត្រអាពាហ៍ពិពាហ៍ជា ដើមដែលអាចបញ្ជាក់បានថា ការរៀបអាពាហ៍ពិពាហ៍ដោយមានការទទួលស្គាល់ដោយ ច្បាប់បន្ទាប់មកចៅក្រមពិចារណាទៅលើឆន្ទៈពិតប្រាកដក្នុងការព្រមព្រៀងរបស់ភាគីប្តីប្រពន្ធដែលបានលើកឡើងនៅក្នុងកិច្ចព្រមព្រៀងលែងលះថា តើភាគីប្តីប្រពន្ធនោះពិតជាមានឆន្ទៈពិតប្រាកដក្នុងការលែងលះនោះដែរឬទេ ? បើចៅក្រមធ្វើការសាកសួរហើយយល់ឃើញថាភាគីប្តីប្រពន្ធមិនមានឆន្ទៈពិតប្រាកដក្នុងការលែងលះនោះទេដូចនេះជាចំណាត់ការចំពោះរឿងក្តីនៃការលែងលះនោះមិនអាចប្រព្រឹត្តទៅរួចទេពោលគឺចៅក្រមនឹងចេញដីកាសម្រេចលើកពាក្យសុំចោលដើម្បីបញ្ចប់នីតិវិធីលែងលះនេះមាត្រា២០ ក្នុងករណីបែបនេះចៅក្រមមិនធ្វើការសម្រេចតាមឆន្ទៈព្រមព្រៀងរបស់ភាគីប្តីប្រពន្ធនោះទេ ដោយចៅក្រមអាចសម្រេចពីការលែងលះនេះបានលុះត្រាមានការព្រមព្រៀងពិតប្រាកដពីភាគីនៃការលែងលះ។ លើសពីនេះទៅទៀតចៅក្រមធ្វើការពិចារណាទៅលើចំណុចនៃការទាមទារចម្បងរបស់ភាគី គឺការលែងលះ និង ជាហេតុការទាមទារបន្ទាប់បន្សំផ្សេងទៀតដូចជា ការបែងចែក សិទ្ធិអំណាចមេបាលើកូនការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនរបស់អ្នកដែលមិនមានសិទ្ធិអំណាចមេបារទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិបំណុលជាអាទិ៍ប៉ុន្តែ ពុំមានការលំបាកឡើយដោយហេតុថាការលែងលះដោយការព្រមព្រៀងគឺ ភាគីបានព្រមព្រៀងគ្នារួចជាស្របទៅលើចំណុចទាំងនេះព្រោះថាការលែងលះដោយការព្រមព្រៀងអាចប្រព្រឹត្តទៅបាន លុះត្រាតែភាគីបានព្រមព្រៀងគ្នាគ្រប់ចំណុចទើបបានតែបើមិនមានការព្រមព្រៀងលើគ្រប់ចំណុចទេ ការសម្រេចសេចក្តីមិនអាចធ្វើទៅបានឡើយ។ ទោះក្នុងស្ថានភាពបែបណាក៏ដោយតុលាការអាចនឹងធ្វើការពិចារណា ទៅលើចំណុច ដូចខាងលើបានលុះត្រាមានការស្នើសុំពីសហព័ទ្ធ ផ្ទុយមកវិញប្រសិនបើភាគីនៃការលែងលះមិនបានលើកឡើងចំណុចនីមួយៗក្នុងកិច្ចព្រមព្រៀង ឬដោយផ្ទាល់មាត់ក៏ដោយ តុលាការមិនធ្វើការពិចារណាឡើយ ប៉ុន្តែចំណុចដែលតុលាការត្រូវពិចារណា គឺឆន្ទៈព្រមព្រៀងលែងលះរបស់ភាគីប៉ុណ្ណោះចំណែកចំណុចដែលភាគីមិនបានព្រមព្រៀងលើបញ្ហាបែងចែកទ្រព្យ ឬ បែងចែកកូនមិនមែនជាឧបសគ្គដល់ការសម្រេចសេចក្តីឡើយ។ ដីកាសម្រេចលើពាក្យសុំលែងលះដោយការព្រមព្រៀងជាដីកាសម្រេចលើអង្គសេចក្តី

រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែលត្រូវធ្វើការជូនដំណឹងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតបដិកាសម្រេច ទៅភាគីនៃការលែងលះដែលសាមីខ្លួនក្នុងរឿងលែងលះនេះតែម្តង។ ទាក់ទិនទៅនឹងការជូនដំណឹងនេះមិនចាំបាច់ដាច់ខាតត្រូវតែធ្វើតាមរយៈការបញ្ជូនដែលតម្រូវឱ្យក្រឡាបញ្ជីត្រូវប្រគល់ដោយ ផ្ទាល់ដោយយោងតាមបញ្ញត្តិមាត្រា២៥១ នៃក្រមរដ្ឋប្បវេណីដូចជាការបញ្ជូនសាលក្រម ឬសាលដីកានោះទេគឺអាចធ្វើឡើងតាមរយៈការ? ម៉្យាងទៀតដីកាសម្រេចលើពាក្យសុំឱ្យលែងលះតាមការព្រមព្រៀងក៏ដូចជាការសម្រេចលើអង្គសេចក្តីនៃរឿងក្តីដែលមិនមែនជាបណ្តឹងមានលក្ខណៈខុសគ្នា នឹងដីកាសម្រេចនៅក្នុងបណ្តឹងរដ្ឋប្បវេណីនៅត្រង់ថា កាសម្រេចអំពីអង្គសេចក្តីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមានអានុភាពដោយការចូលជាស្ថាពរមិនមែនដោយការជូនដំណឹងទេ។ មានន័យថាដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀងក៏ ដូចជាដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវបានចូលជាស្ថាពរ និង មានអានុភាពអនុវត្តនៅពេលផុតរយៈពេលប្តឹងជំទាស់ក្នុងរយៈពេល ០២ សប្តាហ៍គិតចាប់ពីបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ។ ហើយការសម្រេចចំពោះបណ្តឹងលែងលះគ្មានដោយគ្មានការព្រមព្រៀងនេះត្រូវធ្វើឡើងដោយសាលក្រម។ នៅក្នុងបណ្តឹងទាក់ទង នឹងឋានៈបុគ្គលតុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន។ ម៉្យាងទៀត ការទាញហេតុផលដោយផ្ទាល់មាត់មិនត្រូវធ្វើឡើងជាសាធារណៈឡើយ ប៉ុន្តែករណីខ្លះតុលាការអាចអនុញ្ញាតឱ្យជនណាដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន។ នៅក្នុងសាលក្រម នៃការលែងលះទោះបីជាគ្មានការទាមទារឱ្យតុលាការកំណត់អំពីអ្នកមានអំណាចមេបា ចំពោះកូនក៏ដោយតុលាការអាចកំណត់ពីអ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិបានដោយសួរយោបល់របស់កូន នឹងថ្លឹងថ្លែងទៅតាមអាយុ និងចាស់ទុំរបស់កូននោះហើយបើមានពាក្យសុំពីភាគីត្រូវធ្វើការសម្រេចអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។ មានករណីខ្លះភាគីព្រមព្រៀងគ្នាតែការលែងលះប៉ុណ្ណោះ ប៉ុន្តែមិនព្រមព្រៀងគ្នាចំពោះការបែងចែកទ្រព្យសម្បត្តិ និងការគ្រប់គ្រងបីបាច់ថែរក្សាកូនទេ។ ហេតុនេះប្រសិនបើដំបូងឡើង ភាគីដាក់ពាក្យបណ្តឹងលែងលះ ប៉ុន្តែក្រោយមកស្រាប់តែភាគីធ្វើការលែងលះដោយការព្រមព្រៀងគ្នាវិញនោះ ភាគីត្រូវដកពាក្យបណ្តឹងលែងលះ រួចដាក់ពាក្យសុំលែងលះដោយការព្រមព្រៀងហើយតុលាការនឹងចេញដីកាសម្រេចអំពីការលែងលះដោយការព្រមព្រៀងវិញ។ ហើយប្រសិនបើភាគីព្រមព្រៀងតែលើការលែងលះមិនមានការព្រមព្រៀងគ្នាអំពីការបែងចែកទ្រព្យសម្បត្តិទេនោះ តុលាការនឹងសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិដោយសាលក្រមវិញ។ សាលក្រមនៃការលែងលះក៏ដូចជាសាលក្រមនៅក្នុងវិវាទធម្មតាដែរ គឺត្រូវចូលជាធរមាននៅពេលផុតអំឡុងពេលសម្រាប់ការប្តឹងឧបាស្រ័យ គឺរយៈពេល ១ខែ គិតចាប់ពីពេលដែលបានទទួលការបញ្ជូនលិខិតសាលក្រម។

សាលក្រមនេះត្រូវបញ្ជូនទៅឱ្យគូភាគី ក្នុងអំឡុងពេល ២សប្តាហ៍គិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រម។ ការកំណត់បែបនេះ នាំឱ្យយើងឃើញថាភាពខុសគ្នាដ៏សំខាន់មួយរបស់ក្រមរដ្ឋប្បវេណី និងច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ។ មាត្រា ៤៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចែងថាតុលាការប្រជាជនខេត្តក្រុងត្រូវអញ្ជើញ អ្នកប្តឹងឱ្យចូលមកហើយសម្រួលយ៉ាងណាតាមដែលខ្លួនយល់ឃើញ ដើម្បីបញ្ចូលចិត្តអ្នកនោះឱ្យឈប់ប្តឹងលើកលែងតែតុលាការប្រជាជនខេត្ត ក្រុងយល់ឃើញថាពាក្យសុំលែងលះគ្នាមានអាងហេតុធ្ងន់ធ្ងរណាស់ ។ មាត្រា ៤៥ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារក៏បានបញ្ញត្តិផងដែរថាប្រសិនបើដើមចោទនៅតែទទូចសុំលែងតុលាការប្រជាជនខេត្ត-ក្រុងត្រូវអញ្ជើញប្តីប្រពន្ធឱ្យចូលមកកាន់តុលាការជាប្រញាប់ដើម្បីធ្វើការផ្សះផ្សារ។ ក្នុងករណីនេះមេធាវីមិនត្រូវចូលរួមស្តាប់ទេ ។ តាមន័យនេះការផ្សះផ្សារ គឺជាដំណាក់កាលកាតព្វកិច្ចដែលជាគោលការណ៍តុលាការត្រូវធ្វើការផ្សះផ្សារ។ ដោយឡែកក្រមរដ្ឋប្បវេណីចាត់ទុកថាការផ្សះផ្សារគឺជាជម្រើសរបស់តុលាការមានសមត្ថកិច្ចទៅវិញ ពោលគឺតុលាការអាចសាកល្បងធ្វើការផ្សះផ្សារបាន ។ ម៉្យាងវិញទៀតក៏មិនបានរំលេចឱ្យច្បាស់ថាតើក្នុងដំណាក់កាលនៃការផ្សះផ្សារនោះមេធាវីមានសិទ្ធិចូលរួមស្តាប់ ឬក៏អត់?

## ២.២. ការបញ្ជូនសំណុំរឿងទៅតុលាការ

➢ **ការបញ្ជូនពាក្យបណ្តឹង**

១- ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ។

២- បញ្ញត្តិនៃមាត្រា ៧៨ (ការពិនិត្យពាក្យបណ្តឹង ) ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលពាក្យបណ្តឹងមិនអាចបញ្ជូនទៅបាន។ បញ្ញត្តិនោះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលដើមចោទមិនបានបង់ប្រាក់សម្រាប់បញ្ជូនពាក្យបណ្តឹងទុកជាមុន ។[34]

នៅពេលដើមបណ្តឹងដកសំអាងរបស់ខ្លួនហើយ តុលាការបង្គាប់ឱ្យដើមបណ្តឹងបង់ថ្លៃប្រាក់ប្រដាប់ក្តីសិន នឹងបំពេញបែបបទទៅលើពាក្យបណ្តឹងគ្រប់គ្រាន់ ដើម្បីតុលាការអាចទទួលពាក្យបណ្តឹងនោះទៅធ្វើការជំនុំជម្រះបាន ប្រាក់ប្រដាប់ក្តីនេះជាប្រាក់ដែលត្រូវបង់ដោយខានមិនបានបើពុំនោះទេ តុលាការមិនមានអំណាចចាត់ការ និងជំនុំជម្រះបល្ល័ងទេ លើកលែងតែអ្នកប្តឹងនោះទីទ័លក្ររកប្រាក់បង់មិនបាន។ ក្នុងករណីក្រោយនេះគេត្រូវ

[34] ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា ១៣៨ ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ព្រោះការបញ្ជូននេះ គឺជាការឱ្យភាគីម្ខាងទៀតបានដឹងអំពីបណ្តឹងថា តើបុគ្គលណាជាអ្នកប្តឹង កម្មវត្ថុនៃបណ្តឹងជាអ្វី មធ្យោបាយតទល់របស់អ្នកប្តឹងនោះ ជាដើម ហើយជាការផ្តល់ឱកាស ឱ្យភាគីម្ខាងទៀតនោះឆ្លើយដោះសា និង រៀបចំមធ្យោបាយការពារខ្លួនពេលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅដល់ចុងចម្លើយទើបបណ្តឹងនោះត្រូវបានចាត់ការ ។ ករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងបាន មានដូចជា ករណីដែលអាសយដ្ឋានរបស់ចុងចម្លើយ ដែលដើមចោទផ្តល់ឱ្យមានភាពច្បាស់លាស់ ករណីដែលចុងចម្លើយជាអសមត្ថជនដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ករណីដែលចុងចម្លើយជាជនបរទេសដែលមានអភ័យឯកសិទ្ធិ ហើយបដិសេធការទទួលការបញ្ជូនពាក្យស្តើង ។

មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានដូចជា មេភូមិ មេឃុំជាដើម។ ក្នុងការអនុគ្រោះនេះប្រធានសាលាជម្រះក្តីមានសិទ្ធិចេញដីកាសម្រេចអនុគ្រោះ ឬមិនអនុគ្រោះអំពីសភាពទីទ័លក្រក្នុងការប្រាក់បង់ប្រដាប់ក្តី។[35]

### ២.២.១. ករណីមានសំបុត្រអាពាហ៍ពិពាហ៍ និងមិនមានការស្រុះស្រួលគ្នា

ចំពោះការលែងលះ បើមានគូភាគីណាមួយមិនអាចរួមរស់ជាមួយគ្នាបានទ ដោយមានមូលហេតុច្បាស់លាស់។តាមដំណាក់កាលដំបូងនៃការលែងលះនៅត្រឹម ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវសម្របសម្រួលឬបញ្ចុះបញ្ចូលផ្សះផ្សារ ឱ្យភាគីជាសះគ្នា ដោយមានរយៈពេល១៥ថ្ងៃគិតចាប់ពីថ្ងៃដែលបានទទួលពាក្យសុំនោះ ហើយបើមិនអាចបញ្ចុះបញ្ចូលផ្សះផ្សារបានទេត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នាហើយ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅកាន់តុលាការជាបន្ទាន់។ ពាក្យសុំលែងលះគ្នាត្រូវធ្វើជាលាយលក្ខណ៍អក្សរត្រូវចុះមូលហេតុដែលនាំឱ្យមានការលែងលះគ្នា។ បណ្តឹងនោះត្រូវដើមចោទយកទៅជូនតុលាការផ្ទាល់ក៏បាន ឬជូនក្រុមប្រឹក្សាឃុំសង្កាត់ខាងលំនៅរបស់ចុងចម្លើយដោយខ្លួនឯងផ្ទាល់ក៏បាន។ ក្នុងករណីក្រុមប្រឹក្សាឃុំសង្កាត់ត្រូវធ្វើការផ្សះផ្សារក្នុងរយៈ១៥ថ្ងៃក្រោយពីបានទទួលពាក្យបណ្តឹងសុំហើយការបើផ្សះផ្សារនៅពុំបានសម្រេចក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការ។

តុលាការត្រូវត្រួតពិនិត្យបណ្តឹងមុនពេលដំណើរការរឿងក្តីសុំលែងលះ តើអាចទទួលយកបានតាមនីតិវិធីហើយ ឬនៅមុនឈានដល់ការសម្របសម្រួល ឬដំណើរការនីតិវិធី។ នៅពេលបានត្រួតពិនិត្យរួចរាល់ហើយតុលាការត្រូវកោះហៅអ្នកប្តឹងឱ្យចូលមកហើយសម្របសម្រួលយ៉ាងណា តាមដែលខ្លួនយល់ឃើញថាដើម្បីបញ្ចុះបញ្ចូលចិត្តអ្នកនោះចង់លែងលះឱ្យឈប់ប្តឹងលើកលែងតែបើតុលាការយល់ឃើញថា ពាក្យសុំលែងលះគ្នានេះមានអះអាងហេតុធ្ងន់ធ្ងរណាស់។ ក្រោយពីពេលបានទទួលបណ្តឹងសុំលែងលះបើយល់ឃើញថាការចាំបាច់តុលាការអាចចាត់វិធាន ការបណ្តោះអាសន្នបាន ដូចជាការបំបែកលំនៅប្តីប្រពន្ធការឱ្យមើលថែរក្សាកូន ថែរក្សាទ្រព្យសម្បត្តិការផ្តល់អាហារកាតិព្វកិច្ច។ ក្នុងករណីនេះមេធាវីនៃគូភាគីអាចចូលរួមស្តាប់បានប្រសិនបើដើមចោទនៅតែទទួលសុំលែងលះតុលាការត្រូវកោះហៅប្តី-ប្រពន្ធឱ្យចូលមកកាន់តុលាការជាការប្រញាប់ ដើម្បីធ្វើការផ្សះផ្សារ។ ក្នុងករណីនេះមេធាវីមិនត្រូវចូលរួមស្តាប់ទេ។ ប្រសិនបើការផ្សះផ្សាចំពោះមុខដើមចោទ និងចុងចម្លើយ ...ហើយនៅតែពុំបានសម្រេច តុលាការអាចធ្វើការផ្សះផ្សារជាលើកទី២បាន។ ប្រសិនបើនៅពេលផ្សះផ្សារ លើកទី ១ ដើមចោទ ឬចុងចម្លើយដែលទទួលបានដីកាកោះដោយត្រឹមត្រូវហើយ នៅមិនមកបង្ហាញខ្លួនតាមការកោះហៅនោះតុលាការត្រូវកោះហៅភាគីទាំងពីរនោះជាលើកទី២ដើម្បីធ្វើការផ្សះផ្សារ។ ប្រសិនបើដើមចោទដែលបានទទួលដីកាកោះហៅដោយត្រឹមត្រូវហើយនៅមិនបានមកកាន់តុលាការទាំងលើកទី១ ទាំងលើកទី២ ដោយគ្មាន

[35] មាត្រា៥៩ ដល់ មាត្រា៦៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៦

មូលហេតុច្បាស់លាស់នោះទេត្រូវចាត់ទុកថាសុខចិត្តឈប់ប្ដឹង។ ប្រសិនបើចុងចម្លើយបានទទួលដីកាកោះហៅដោយត្រឹមត្រូវហើយនៅតែមិនព្រមចូលខ្លួនមកកាន់តុលាការទាំងលើកទី១ ទាំងលើកទី២ ដោយគ្មានមូលហេតុនោះត្រូវចាត់ទុកថាមិនព្រមសះជានឹងគ្នា។ ប្រសិនបើមានអ្នកដែលមិនបានមកតាមដីកាកោះហៅជាលើកទី១ មិនមែនជាអ្នកមិនបានមកលើកទី២ទេ តុលាការត្រូវកោះហៅភាគីនោះមកផ្សះផ្សារជាលើកទី៣។ ការផ្សះផ្សារម្ដងៗ ត្រូវឱ្យឃ្លាតពីគ្នា១ខែយ៉ាងឆាប់និង២ខែយ៉ាងយូរ។ ក្នុងការផ្សះផ្សារម្ដងៗ ទោះបីបានលទ្ធផលយ៉ាងណាក្ដីត្រូវចុះក្នុងកំណត់ហេតុបញ្ជាក់អំពីការផ្សះផ្សារបានសម្រេច ឬភាគីមិនបានចូលហើយចៅក្រមទទួលបន្ទុកការផ្សះផ្សារត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះជាមួយភាគីវត្តមាន និងលេខាធិការក្រឡាបញ្ជីតែបើការផ្សះផ្សារមិនអាចធ្វើបានសម្រេចទៅតុលាការត្រូវដំណើរការរឿងក្ដី។

## ២.៣.ការដាក់បណ្ដឹងនៅតុលាការ



បណ្ដឹងអាចធ្វើឡើងបាន ក្នុងករណីដែលបណ្ដឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង នឹងដែលវិវាទនោះអាចដោះស្រាយដោយសាលក្រម។[36]

➢ របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង

១. ការប្ដឹងត្រូវធ្វើដោយដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅតុលាការ ។

២. នៅក្នុងលិខិតនៃពាក្យបណ្ដឹងត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក. ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគីហើយឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ. ខ្លឹមសារនៃសាលក្រមដែលដើមចោមទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។

៣. នៅក្នុងពាក្យបណ្ដឹងក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី២ ខាងលើនេះដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុដែលជា មូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាងគប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់។ ក្នុងចំណោមអង្គហេតុទាំងឡូលដែលទាក់ទងនឹងអង្គហេតុផលជាមូលហេតុនៃការទាមទារ និងភស្តុតាង ។

៤. ពាក្យបណ្ដឹងដែលមានសរសេរពីមធ្យោបាយតទល់ ឬការពារខ្លួនត្រូវចាត់ជាឯកសារត្រៀមផងដែរ ។[37]

---

[36] ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុនគ្មានមាត្រាណាដែលចែងឱ្យបានច្បាស់លាស់អំពីចំណុចនេះដូចមាត្រា។ ជាគោលការណ៍បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដូចនេះ ដើម្បីឱ្យតុលាការអាចដោះស្រាយតាមគោលបំណងនេះបាន លុះត្រាតែការប្ដឹងទាមទារនោះមានកម្មវត្ថុជាវិវាទទាក់ទងនឹងសិទ្ធិរបស់បុគ្គលឯកជន។ ការចែងមាត្រានេះឡើង ដោយសារមានវិវាទខ្លះដែលមិនអាចដោះស្រាយដោយសាលក្រមហើយមានកម្មវត្ថុ មិនមែនជាវិវាទតាមផ្លូវច្បាប់ជាក់ស្ដែងដូចជា វិវាទអំពីការបកស្រាយទ្រឹស្ដីណាមួយ វិវាទអំពីអត្ថិភាពនៃព្រះអាទិទេពជាដើម ។

[37] ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មាត្រា 133 និង បទប្បញ្ញត្តិនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុនមាត្រា 53 ។

កថាខណ្ឌទី ១ ទាមទារឱ្យភាគីប្ដឹង ដោយដាក់ពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរ ដោយហេតុថា នីតិវិធីនៃបណ្ដឹងទាមទារឱ្យមានភាពច្បាស់លាស់ ។

កថាខណ្ឌទី ២ កំណត់ពីទម្រង់នៃបណ្ដឹងដែលតម្រូវឱ្យរាល់បណ្ដឹងរដ្ឋប្បវេណីត្រូវតែគោរពទៅតាមការកំណត់ន មាត្រានេះជាដាច់ខាត។ ហេតុដូចនេះហើយបានជាមានមាត្រាក្រោយៗ បានចែងតម្រូវឱ្យអ្នកប្ដឹង ធ្វើការកែតម្រូវ បើតុលាការពិនិត្យឃើញថា ពាក្យបណ្ដឹងនោះមានភាពខុសឆ្គង ឬខ្វះចន្លោះ ។ បើអ្នកសរសេរពាក្យបណ្ដឹង បានគោរពតាមមាត្រានេះ គឺក្នុងន័យថា មានអត្ថប្រយោជន៍ច្រើនដល់សកម្មភាពបណ្ដឹង ឬដល់ចំណាត់ការរបស់តុលាការ ព្រោះថាបើមានភាពច្បាស់លាស់នៃចំណុចទាមទា និងភាពច្បាស់លាស់នៃអង្គហេតុនោះ គឺជាការមួយធ្វើឱ្យតុលាការ មុនពេលតុលាការចាប់ផ្ដើមចាត់ការលើបណ្ដឹងនោះ ហើយម្យ៉ាងទៀតក៏ជាការធ្វើឱ្យភាគីម្ខាងទៀតនៃបណ្ដឹងងាយយល់ពី ការទាមទារ និង អាចឆ្លើយតបចំពោះការទាមទារនោះ ។ ដែលទទួលពាក្យបណ្ដឹងនោះ មានភាពងាយស្រួលនៅក្នុងការពិនិត្យពីភាពត្រឹមត្រូវឬមិនត្រឹមត្រូវនៃការទាមទារ។

**ការពិនិត្យពាក្យសុំ** នៅពេលដែលពាក្យសុំត្រូវបានដាក់មកដល់តុលាការ អ្នកដែលមានសមត្ថកិច្ចទទួលពាក្យសុំ ត្រឹមន្ត្រីរដ្ឋបាលដែលជាអ្នកទទួលបន្ទុកនៅក្នុងការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិកប្រចាំតុលាការ នៅពេលដែល ពាក្យសុំបានបញ្ជូនមកដល់ដៃក្រឡាបញ្ជីដោយមន្ត្រីរដ្ឋបាល ហើយតួនាទីរបស់ក្រឡាបញ្ជី គឺត្រូវធ្វើការពិនិត្យហើយធ្វើការចុះលេខលើសំណុំរឿងដែលបានទទួលនោះ។ ក្នុងករណីដែលពិនិត្យឃើញថាពាក្យសុំនោះមិនត្រឹមត្រូវតាមទម្រង់នៃច្បាប់ដែលបានកំណត់ទេនោះត្រូវរាយការណ៍ជូនចៅក្រម ដើម្បីឱ្យចៅក្រមសម្រេចថាតើត្រូវបង្គាប់ឱ្យកែតម្រូវ ឬលើកពាក្យសុំចោល (ដីកាសម្រេច)។ ផ្ទុយមកវិញប្រសិនបើពិនិត្យឃើញថាពាក្យសុំនោះត្រឹមត្រូវតាមទម្រង់នៃច្បាប់បានកំណត់ហើយ ដូច្នេះក្រឡាបញ្ជីត្រូវបញ្ជូនពាក្យសុំនោះទៅចៅក្រមដើម្បីសម្រេច បើកការជំនុំជម្រះ ។ គួរបញ្ជាក់ផងដែរក្នុងការដាក់ពាក្យសុំអ្នកដាក់ពាក្យសុំត្រូវបង់ពន្ធលើពាក្យសុំចំនួន ៥.០០០(ប្រាំពាន់)រៀល[38] ។ ចំណែកឯប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ[39] ។

[38] មាត្រា២២ កថាខណ្ឌ១ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០

[39] មាត្រា២២ កថាខណ្ឌ៣ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០

# ជំពូកទី៣
# ដំណើរការនៃនីតិវិធីលៃខលះ

# ជំពូកទី ៣
# ដំណើរការនៃនីតិវិធីលេខលះ

## ៣.១. តុលាការមានសមត្ថកិច្ច

តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹងវិនិច្ឆ័យលើរឿងក្តីហើយចេញសាលក្រម។

សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅដ្ឋាន ជាអាទិ៍បណ្តឹងចំពោះចុងចម្លើយដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ ត្រូវដាក់ពាក្យបណ្តឹងទៅសាលាដំបូងដែលមានសមត្ថកិច្ចជម្រះក្តីនៅទីកន្លែងដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោម៖

- រូបវន្តបុគ្គល
    - លំនៅដ្ឋានរបស់ចុងចម្លើយ
    - ទីសំណាក់បើពុំមានលំនៅដ្ឋាន ឬមានលំនៅដ្ឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាបក្រកម្ពុជា។
    - លំនៅដ្ឋានចុងក្រោយ បើពុំមានទីសំណាក់ ឬមានទីសំណាក់មិនពិតប្រាកដ ។
- នីតិបុគ្គលក្នុងប្រទេស
    - ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង ។
    - លំនៅដ្ឋានរបស់អ្នកតំណាង ឬ របស់អ្នកទទួលខុសត្រូវភារកិច្ច
    - ចែងបែកការងារជាចម្បងបើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មទេ ។
- នីតិបុគ្គលបរទេស
    - ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង ។
    - លំនៅដ្ឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងក្នុងព្រះរាជាណាចក្រកម្ពុជា បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។

ចំពោះបណ្ដឹងលែងលះគ្នា និងបណ្ដឹងឲ្យបញ្ជាក់ពីអត្ថិភាព(ភាពមាន)ឬនត្ថិភាព(ភាពគ្មាន) នៃបុគ្គភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគី នៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្ដឹងនោះ(... )។[40]

ហេតុនេះ តុលាការមានសមត្ថកិច្ចក្នុងរឿងក្ដីលែងលះអាចជាតុលាការខាងលំនៅឋានរបស់ដើមចោទក៏បាន ឬជាតុលាការខាងលំនៅឋានរបស់ចុងចំលើយក៏បាន។

**ឧទាហរណ៍** ៖ បុរស ក និង នារី ខ ជាប្ដីប្រពន្ធនឹងគ្នា។ អ្នកទាំងពីរមានលំនៅដ្ឋានក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារយៈពេល ២ ឆ្នាំកន្លងផុតទៅបុរស ក បានចុះចេញពីផ្ទះទៅរស់នៅជាមួយនឹងឪពុកម្ដាយរបស់គាត់នៅឯខេត្តពោធិ៍សាត់ទៅវិញក្រោយពីមានទំនាស់ជាមួយប្រពន្ធ។ ឧបមាថា នារីខ មានបំណងចង់ប្ដឹងលែងលះដូច្នេះ នារី ខ អាចដាក់ពាក្យបណ្ដឹងលែងលះនៅសាលាដំបូងរាជធានីភ្នំពេញក៏បាន ឬនៅសាលាដំបូងខេត្តពោធិ៍សាត់ក៏បាន។

## ៣.២. ការដាក់ពាក្យបណ្ដឹង

ភាគីម្ខាង (ប្ដី/ប្រពន្ធ) នៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្ដឹងទាមទារលែងលះគ្នាទៅសាលាដំបូងរាជធានី ខេត្ត ហើយបើតុលាការរកឃើញថាមានមូលហេតុ និងភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ថាភាគីទាំងពីរពិតជាមិនអាចរួមរស់នៅជាមួយគ្នាជាប្ដី/ប្រពន្ធទៀតបាន នោះតុលាការត្រូវសម្រេចឲ្យភាគីលែងលះគ្នាតាមរយៈអំណាច(សាលក្រម)នេះបើយោងតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។ បើទោះបីជាពាក្យបណ្ដឹងទាមទារការលែងលះរបស់ភាគី មានមូលហេតុដូចមានរៀបរាប់ខាងលើក៏ដោយប៉ុន្តែ ប្រសិនបើតុលាការយល់ឃើញថាការលែងលះនោះ បណ្ដាលឲ្យការទ្រទ្រង់ជីវភាពរបស់ប្ដី/ប្រពន្ធ ឬកូនក្រលំបាក ឬឈឺចាប់ដែលពុំអាចទ្រាំទ្របាន ឬដោយសារតែការទាមទារនោះផ្ទុយនឹងភាពសុចរិតនោះ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះបានដោយពិចារណាលើស្ថានភាពជាក់ស្ដែង ឬដោយឆន្ទានុសិទ្ធិ។

## ៣.៣. ការត្រួតពិនិត្យបណ្ដឹង

ក្រោយពេលតុលាការបានទទួលពាក្យបណ្ដឹងហើយត្រូវចាត់ ការត្រួតពិនិត្យលើពាក្យបណ្ដឹងនោះ ករណីចៅក្រមឃើញថា ក្នុងពាក្យបណ្ដឹងនោះមានភាពខ្វះខាត ដូចជាការមិនបានបង់ពន្ធជា ដើមតុលាការត្រូវកំណត់ពេលសមរម្យ និង បង្គាប់ដើមចោទឲ្យធ្វើការកែតម្រូវចំណុចខ្វះខាតទាំងនោះ។ ប៉ុន្តែក្រមនីតិវិធីរដ្ឋប្បវេណីមិន

[40] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០ កថាខណ្ឌទី១

បានកំណត់ជាក់ច្បាស់អំពីថេរវេលាប៉ុន្មានដែលតុលាការត្រូវពិនិត្យលើពាក្យបណ្ដឹងថា មានខ្វះចន្លោះត្រង់ណា ដែលនាំឲ្យដំណើរការប្រើរយៈយូរ នឹងជាហេតុដែលនាំឲ្យភាគីនោះជួបការលំបាក។

### ៣.៤. ការផ្សះផ្សារ

តុលាការអាចសាកល្បងធ្វើការផ្សះផ្សារ ទោះបីជាបណ្ដឹងស្ថិតក្នុងក្នុងដំណាក់កាលណាក៏ដោយទោះបីជាគូភាគីទាមទារយ៉ាងលែងលះយ៉ាងខ្លាំងក៏ដោយ។

#### ៣.៤.១. ការផ្សះផ្សារដោយតុលាការ

ចំពោះនីតិវិធីនៅតុលាការមានលក្ខណៈដូចគ្នាមិនថាតុលាការទទួលបណ្ដឹងដោយផ្ទាល់ពីភាគីដើមចោទ ឬតុលាការទទួលពាក្យបណ្ដឹងពី មេឃុំ ចៅសង្កាត់ទេក្រោយទទួលពាក្យបណ្ដឹងតុលាការត្រូវចាត់តាំងចៅក្រមមួយរូបដើម្បីធ្វើការផ្សះផ្សា។ ទោះបីជាសហព័ទ្ធទាមទារលែងលះគ្នាខ្លាំងយ៉ាងណា ក៏តុលាការអាចនឹងធ្វើការផ្សះផ្សារដោយឆន្ទានុសិទ្ធិ ។ ការផ្សះផ្សារ គឺមិនមែនធ្វើឲ្យភាគីសះជាគ្នាដោយការលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារនោះទេ គឺផ្សះផ្សាដើម្បីឲ្យមានការដកពាក្យបណ្ដឹងលែងលះវិញ ហើយរួមរស់នៅជាមួយគ្នាជាប្ដីប្រពន្ធវិញ។

#### ៣.៤.២. ការហាមឃាត់ការផ្សះផ្សារក្នុងករណីអំពើហិង្សា ក្នុងគ្រួសារធ្ងន់ធ្ងរ

ករណីដែលមានបណ្ដឹងលែងលះគ្នាអាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការផ្សះផ្សារ ករណីដែលបណ្ដឹងលែងលះនោះមិនមានប្រើអំពើហិង្សា ឬករណីមានប្រើអំពើហិង្សាដែលជាបទល្មើសប៉ះពាល់ខាងផ្លូវកាយ ឬផ្លូវចិត្តបទល្មើសមជ្ឈិមស្រាល ឬបទលហុ។ ចំពោះការផ្សះផ្សារ ឬការសម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង។

ក្នុងករណីបណ្ដឹងលែងលះគ្នាដែលមានលក្ខណៈជាបទឧក្រដ្ឋឬជាបទមជ្ឍឹមធ្ងន់ធ្ងរ អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សារឬសម្របសម្រួលបានទេ។ រីឯអំពើហិង្សាដែលមានចរិតជាបទល្មើសព្រហ្មទណ្ឌ ដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬជាបទមជ្ឍឹមធ្ងន់ធ្ងរ ត្រូវតែជាកម្មវត្ថុនៃបណ្ដឹងអាជ្ញា ទោះបីជាអំពើហិង្សានេះបានកន្លងទៅហើយក៏ដោយ។

### ៣.៥. ការត្រៀមទាញហេតុផល

ក្នុងដំណាក់កាលសម្រាប់ត្រៀមការទាញហេតុផ្ទាល់មាត់តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគីបំភ្លឺនៅចំណុចវិវាទនៃរឿងក្ដីដែលគូភាគីមិនយល់ស្របគ្នា និងរៀបចំនៅភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដីនោះ ដើម្បីអាចធ្វើជាការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ឱ្យបានយ៉ាងល្អិតល្អន់។

ជាគោលការណ៍ គូភាគីជាអ្នកស្នើសុំទៅតុលាការពិនិត្យភស្តុតាងនិយាយម្យ៉ាងវិញទៀតថា គូភាគីជាអ្នកស្វះស្វែងរកភស្តុតាងផ្សេងៗមកដាក់ជូនតុលាការពិនិត្យដើម្បីជាផលប្រយោជន៍របស់ខ្លួន។ ស្របគ្នាដែរ តុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ហើយជាពិសេសតុលាការអាចធ្វើការយកអង្គហេតុដែលមិនបានអះអាងដោយគូភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន។

# ជំពូកទី៤
# ដំណាក់ការជំនុំជម្រះ

# ជំពូកទី ៤
# ដំណាក់ការជំនុំជម្រះ

## ៤.១. ការទាញហេតុផលផ្ទាល់មាត់

ជាទូទៅនីតិវិធីត្រៀម គឺជាដំណាក់កាលដើមមួយនៃនីតិវិធីរដ្ឋប្បវេណីដែលធ្វើឡើងដើម្បីផ្តល់ឱកាសដល់តុលាការក្នុងការរៀបចំនូវសេចក្តីអះអាងរបស់ភាគី ដើម្បីបំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងទៅនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់។ លើសពីនេះទៅទៀតចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីលើកកម្ពស់និងសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានគោលបំណងធ្វើការបំភ្លឺអំពីចំណុចវិវាទរវាងគូភាគីដោយរៀបចំជាមុននូវសេចក្តីអះអាងរបស់ភាគី និងធ្វើការរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទដែលត្រូវធ្វើការត្រួតពិនិត្យ។ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីនីមួយៗតែងតែតវ៉ា ចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថាមានប្រយោជន៍ នឹងធ្វើឲ្យមានការលំបាកក្នុងការស្វែងរកការពិត។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ហើយនីតិវិធីនេះពុំចាំបាច់បើកជាសាធារណៈនោះទេ។ នីតិវិធីត្រៀមនេះមិនសំដៅដល់តុលាការទទួលបន្ទុកធ្វើការសើបសួរដោយសកម្មទៅលើបណ្តឹងនោះឡើយ គឺត្រូវតែតម្រូវឲ្យមានគូភាគីបំភ្លឺចំណុចវិវាទរបស់ខ្លួនដែលបានលើកឡើងមិនស្របគ្នាតែប៉ុណ្ណោះ និងធ្វើកិច្ចការត្រៀមមួយចំនួនដូចជាការត្រៀមដាក់មធ្យោបាយតទល់ ឬការពារខ្លួន។ នៅក្នុងការអនុវត្តបច្ចុប្បន្ន នីតិវិធីនៃការសើបអង្កេតអនុញ្ញាតឲ្យមានការសើបសួរទៅលើសាក្សី ឬទៅលើភាគីទាំងពីរហើយលទ្ធផលនៃការសាកសួរនោះត្រូវបានគេចាត់ទុកថាជាមូលដ្ឋាន នៃការសម្រេចសេចក្តីនាពេលសវនាការខាងមុខ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយនីតិវិធីថ្មីគឺមិនអនុញ្ញាតឲ្យមានការសាកសួរទៅលើសាក្សី និងលើគូភាគីឡើយនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ យ៉ាងណាមិញតុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឲ្យពិនិត្យភស្តុតាង និងអាចពិនិត្យភស្តុតាងជាឯកសារបាន។ ចំណុចនេះចង់បញ្ជាក់ថាតុលាការមិនអាចធ្វើការសាកសួរទៅលើភស្តុតាងថា ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តីឲ្យបានត្រឹមត្រូវភាគច្រើនគេត្រូវការភស្តុតាងជាឯកសារហេតុដូច្នេះហើយបានជាគេអនុញ្ញាតឲ្យតុលាការពិនិត្យភស្តុតាងជាឯកសារនៅក្នុងកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តីប៉ុណ្ណោះ។ នីតិវិធីត្រៀមសម្រាប់

ការទាញហេតុផលមានគោលដៅផ្តោតយ៉ាងសំខាន់ផងដែរ គឺឲ្យតុលាការទទួលបាននូវព័ត៌មានទាក់ទងនឹងចំណុចមួយចំនួន។ តើភាគីអះអាងពីអ្វីខ្លះថាតើទទួលស្គាល់ចំណុចណាខ្លះ ថាតើបដិសេធចំណុចណាខ្លះ។

ជាគោលការណ៍តុលាការត្រូវធ្វើការផ្សះផ្សារជា លើកដំបូងសិននៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលទោះបីជាបញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ បានតម្រូវឲ្យតុលាការត្រូវតែធ្វើការសាកល្បងក្នុងការផ្សះផ្សារគូភាគីទំនាស់ក៏ពិតមែនក៏ប៉ុន្តែការដែលតុលាការសម្រេចចិត្តថានឹងត្រូវផ្សះផ្សារ ឬ/និងមិនត្រូវផ្សះផ្សានោះ គឺអាស្រ័យទៅលើ ស្ថានភាព និងគោលបំណងរបស់គូភាគីនៃរឿងក្តីនីមួយៗ សម្រាប់ឲ្យតុលាការធ្វើការពិចារណាយកធ្វើជាមូលដ្ឋានក្នុងការសម្រេចចិត្តសាកល្បងធ្វើការផ្សះផ្សារឬមិនត្រូវផ្សះផ្សាវិវាទនោះ។ ក្នុងករណីដែលអនុញ្ញាតឲ្យធ្វើបែបនេះ ពីព្រោះថាបើសិនណាតុលាការសម្រេចចិត្តសាកល្បងធ្វើការផ្សះផ្សារហើយមិនបានសម្រេចនៅខណៈនោះក៏ដោយក៏នៅតែអាចសាកល្បងធ្វើការផ្សះផ្សារម្តងទៀតបានដែរ នៅក្នុងក្រមនីតិវិធីរដ្ឋវប្បវេណីបានបញ្ញត្តិយ៉ាងច្បាស់ថា តុលាការអាចសាកល្បងធ្វើការផ្សះផ្សារបានទោះបីបណ្តឹងនោះស្ថិតក្នុងដំណាក់កាលណាក៏ដោយ។ បើប្រៀបធៀបទៅនឹងនីតិវិធីដែលតុលាការកម្ពុជាបានអនុវត្តកន្លងមកនោះមាន បញ្ញត្តិស្តីពីគោលការណ៍ដែលត្រូវធ្វើការផ្សះផ្សារជាមុនដាច់ខាត។ ដើម្បីឲ្យការផ្សះផ្សាទទួលបាននូវលទ្ធផលល្អ ចៅក្រមអាចប្រើប្រាស់នូវវិធីសាស្ត្រសមរម្យផ្សេងៗ របស់ខ្លួនបានតាមឆន្ទានុសិទ្ធិមានដូចជា តុលាការអាចស្នើឲ្យភាគីម្ខាងចេញទៅក្រៅបន្ទប់នៅខណៈពេលដែលតុលាការព្យាយាមបញ្ចុះបញ្ចូលភាគីម្ខាងទៀត ទោះបីជាយ៉ាងណាក៏ដោយចំពោះការសម្រេចចិត្តឲ្យភាគីម្ខាងចេញក្រៅបន្ទប់ មិនអាចឲ្យភាគីម្ខាងនោះមានកើតមន្ទិលសង្ស័យថាតុលាការមានភាពលំអៀង។ ដូច្នេះដើម្បីចៀសវាងនូវបញ្ហានេះជាការប្រសើរបំផុតនោះ តុលាការតម្រូវឲ្យមានការយល់ព្រមពីគូភាគីជាមុនសិន។ សម្រាប់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានតុលាការធ្វើការកំណត់ដែលមានរយៈពេលចំនួន(៣០ថ្ងៃ) បន្ទាប់ពីពាក្យបណ្តឹងបានដាក់ចូលទៅតុលាការ។ លើសពីនេះទៅទៀត នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទនៃរឿងក្តីនិងភស្តុតាងហើយនោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីទាំងសងខាងអំពីលទ្ធផលនៃការរៀបចំនេះ ដើម្បីឲ្យមានឯកភាពគ្នា ព្រមទាំងអង្គហេតុដែលត្រូវបំភ្លឺដើម្បីត្រៀមធ្វើការពិនិត្យលើភស្តុតាងឲ្យបានល្អិតល្អន់ នៅពេលធ្វើការត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់នាខណៈពេលខាងមុខ។ មិនត្រឹមតែប៉ុណ្ណោះទេនៅកាលបរិច្ឆេទនៃ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឲ្យពិនិត្យភស្តុតាង ឬដីកាសម្រេចផ្សេងៗ ទៀតដែលអាចសម្រេចបានក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងអាចពិនិត្យភស្តុតាងជាឯកសារដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង។ តាមធម្មតាចំពោះការពិនិត្យភស្តុតាងត្រូវធ្វើឡើងក្នុងនីតិវិធីនៃការទាញហេតុផលផ្ទាល់

មាត់ដែលត្រូវធ្វើជាសាធារណៈ ក៏ប៉ុន្តែការពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយការអានឯកសារនោះដោយចៅក្រម ហេតុដូចនេះហើយបើសិនជាប្រៀបធៀបទៅនឹងការសាកសួរសាក្សីជាដើមមិនសូវមានទំនាក់ទំនងខ្លាំងនឹងគោលការណ៍បើកជាសាធារណៈទេ ម្យ៉ាងវិញទៀតនោះដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តីឲ្យបានត្រឹមត្រូវ។ ចំពោះដីកាសម្រេចនេះតុលាការអាចចេញនូវដំណាក់កាលមួយដែលអង្គហេតុត្រូវបានបំភ្លឺបញ្ជាក់ និងភាពចាំបាច់នៃការស្នើសុំឲ្យមានការសាកសួរលើសាក្សីត្រូវបានគេបញ្ជាក់។ ភាគីដែលស្នើសុំឲ្យមានការសាកសួរទៅលើសាក្សីត្រូវភ្ជាប់ជាមួយឯកសារដែលកំណត់អំពីចំណុចដែលត្រូវសួរ។ ចំពោះចំណុចសំខាន់ដែលត្រូវប្រាប់ទៅភាគីអំពីការប៉ាន់ប្រមាណលើពេលវេលាចាំបាច់នៃការពិនិត្យលើភស្តុតាងនិងសាក្សីនោះ។ តួយ៉ាងនៅក្រោយពេលដែលការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយនោះភាគីនីមួយៗ មិនអាចដាក់មធ្យោបាយតទល់ ឬ ការការពារខ្លួនបានតទៅទៀតទេពីព្រោះមានន័យថា វាប្រៀបដូចជាការបញ្ចប់នីតិវិធីអញ្ចឹងដែរ។ ដូច្នេះតុលាការត្រូវធ្វើការបញ្ជាក់ដោយប្រុងប្រយ័ត្នទៅភាគីថាតើបានដាក់នូវមធ្យោបាយតទល់ ឬការពារសមរម្យដើម្បីស្នើសុំឲ្យមានការបញ្ជាក់នូវអង្គហេតុណាមួយ ឬភាពមិនច្បាស់លាស់នៃផ្នែកគតិយុត្តិ ឬសុំឲ្យភាគីដាក់នូវមធ្យោបាយតទល់ ឬការពារខ្លួន។ ជាចុងក្រោយនេះនៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល បានចប់សព្វគ្រប់អស់ហើយនោះ តុលាការត្រូវធ្វើកាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយត្រូវកោះហៅគូភាគីឲ្យមកចូលរួម។

## ៤.២. ការចេញសាលក្រម

តាមគោលការណ៍សាលក្រមលែងលះគ្នាត្រូវសម្រេចនៅចំពោះមុខគូរក្តី។ ប្រសិនបើសាលក្រមនោះជាសាលក្រមកំបាំងមុខគូរក្តីអាចប្តឹងទាស់បានក្នុងរយៈ១៥ថ្ងៃ។ រយៈពេលនេះគិតពីថ្ងៃដែលបានឱ្យដំណឹងពីសាលក្រមកំបាំងមុខដល់គូរក្តីផ្ទាល់ ឬដល់លំនៅរបស់គូរក្តី។ បណ្តឹងទាស់នឹងសាលក្រមកំបាំងមុខដោយសាមីខ្លួនជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់នៅតុលាការ។ ចំពោះបណ្តឹងទាស់នាំឱ្យផ្អាកការអនុវត្តសាលក្រម ប្រសិនបើផុត រយៈពេលប្តឹងទាស់ សាលក្រមកំបាំងមុខនឹងទៅជាសាលក្រមស្ថាពរ។ ប្រសិនបើអ្នកប្តឹងទាស់បានប្តឹងក្នុងរយៈពេលកំណត់ ប៉ុន្តែមិនបានចូលខ្លួនមកក្នុងពេលជំនុំជម្រះដោយគ្មានមូលហេតុ នោះសាលក្រមកំបាំងមុខត្រូវដំកល់ទុកជាបានការនឹងទៅជាសាលក្រមស្ថាពរ។ ប្រសិនបើបណ្តឹងទាស់ត្រឹមត្រូវតាមទម្រង់ច្បាប់តុលាការត្រូវពិនិត្យ និង ជំនុំជំរះសាជាថ្មីលើអង្គហេតុនិងអង្គច្បាប់។

### ៤.២.១. ការចេញសាលក្រមកំបាំងមុខ

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលសម្រេចកំបាំងមុខគូភាគីណាមួយ ពោលគឺ ជាសាលក្រមដែលសម្រេចសេចក្តីដោយគ្មានមុខដើមចោទ ឬ ចុងចម្លើយ។ មាត្រា៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើ

ជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការនោះទេ ហើយនិងប្រសិនបើគ្មានភ័ស្តុតាងបង្ហាញឲ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនខ្លួនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមនេះអាចត្រូវប្ដឹងទាស់បាន។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីចូលបង្ហាញខ្លួននៅពេលសវនាការ ឬមាន អ្នកតំណាងដោយត្រឹមត្រូវនោះសាលក្រមត្រូវតែជាសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី។ សាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវជូនដំណឹងដល់សាមីខ្លួនទេ។ សាលក្រមនេះអាចប្ដឹងឧទ្ធរណ៍បានដោយយោងតាមមាត្រា៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

តុលាការអាចដំកល់ការកែប្រែ ឬបដិសេធសាលក្រមកំបាំងមុខដែលបានសម្រេចសេចក្ដីលើកមុនបាន កុំឱ្យតែបំពានលើច្បាប់ ឬ គោលការណ៍នៃច្បាប់។ កាលបើសាលក្រមលែងលះជាសាលក្រមស្ថាពរតុលាការត្រូវចាត់ចែងឱ្យចម្លងសេចក្ដីវិនិច្ឆ័យនៃសាលក្រមស្ថាពរនោះ ចុះនៅរឹមទំព័រនៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវរំលាយ។ ប្រសិនបើប្រពន្ធមានផ្ទៃពោះប្ដីអាចនឹងសុំលែងលះគ្នាបាន លុះត្រាតែប្រពន្ធនោះសម្រាលកូនរួចបាន១ឆ្នាំសិន។ ការបន្ថយសិទ្ធិខាងលើមិនត្រូវអនុវត្តលើនារីទេ។ នារីអាចសុំលែងលះបាននៅពេលមានផ្ទៃពោះដោយមានភស្តុតាងត្រឹមត្រូវនិងអាចទទួលបាន។ ចំពោះការចិញ្ចឹមកូនភាគីទាំងពីរមានកាតព្វកិច្ចផ្ដល់អាហារកាតិព្វកិច្ចលុះដល់កូនមានអាយុ១៨ឆ្នាំបន្ទាប់ពីការលែងលះគ្នាបានពេញលេញតាមច្បាប់។

### ៤.២.២. ការចេញសាលក្រមចំពោះមុខ

សាលក្រមចំពោះមុខ គឺជាប្រភេទនៃសាលក្រមមួយដែលចេញ និងប្រកាសចំពោះមុខដើមចោទឬចុងចម្លើយ ឬចំពោះមុខអ្នកតំណាងរបស់ដើមចោទ ឬចុងចម្លើយក្នុងករណីដែលភាគី ឬអ្នកតំណាងមានវត្តមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់[41] ឬអាចនិយាយបានថាសាលក្រមចំពោះមុខ[42] គឺជាជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសាវនាការនោះសាលក្រម ជាសាលក្រមចំពោះជនជាប់ចោទ ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវឲ្យដំណឹងដល់ជននោះទេ ។ [43]សាលក្រមនៅតែជាសាលក្រមសាលក្រមចំពោះមុខដដែល

[41] មាត្រា ៣៦១ (សាលក្រមដែលចាត់ថាចំពោះមុខ) ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួន នៅពេលសវនាការនោះទេ ប៉ុន្តែសាមីខ្លួនបានដឹង អំពីដីកាបញ្ជូនទៅ ជំនុំជម្រះផ្ទាល់ ឬ បានដឹងពីការកោះហៅហើយនោះសាលក្រមត្រូវចាត់ទុកថាជា សាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមអាចចាត់ទុកថាចំពោះមុខនេះត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រម នេះអាចត្រូវប្ដឹងឧទ្ធរណ៍បាន។ ក្នុងករណីដែលជនជាប់ចោទអវត្តមានដោយមានការបង្ហាញមូលហេតុ អំពីការអវត្តមាន របស់ខ្លួនហើយតុលាការ ក៏បានទទួលស្គាល់ថាត្រឹមត្រូវនោះតុលាការ អាចលើករឿងទៅជំនុំជម្រះនៅសវនាការមួយក្រោយទៀត។

[42] យោងតាម មាត្រា ៣៦០ សាលក្រមចំពោះមុខ នៃ នីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជាបានចែងថា ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួន នៅពេលសវនាការនោះសាលក្រមជា សាលក្រមចំពោះមុខជនជាប់ចោទ។

[43] សាលក្រមចំពោះមុខអាចប្ដឹងឧទ្ធរណ៍បាន

ទោះបីជាជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ ។ សាលក្រមគឺជាសាលក្រមចំពោះមុខដែរកាលណាជនជាប់ចោទត្រូវបានសួរចម្លើយនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៣០៩[44] នៃសាលក្រមនេះ ។ យោងតាមមាត្រា ៣៦៤ សាលក្រមដែលចេញចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណីប្រសិនបើបុគ្គល ដែលកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅពេលសវនាការ ឬ ក៏មានអ្នកតំណាងដោយត្រឹមត្រូវសាលក្រមនោះ ជាសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមចំពោះមុខនេះមិនត្រូវឲ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ សាលក្រមនេះអាចត្រូវប្តឹងឧទ្ធរណ៍បាន។

ប្រសិនបើបុគ្គលកោះហៅក្នុងឋានៈអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការ និង គ្មានអ្នកតំណាងត្រឹមត្រូវទេសាលក្រម ត្រូវសម្រេចដោយកំបាំងមុខអ្នកទទួល ខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះត្រូវឲ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។[45]

## ៤.៣. អានុភាពនៃការលែងលះ

ការលែងលះមានអនុភាពផ្តាច់ចំណងអាពាហ៍ពិពាហ៍ រវាងសហព័ទ្ធនៅពេលដែលសេចក្តីសម្រេចអំពីការលែងលះបានចូលជាស្ថាពរ។ សេចក្តីអំពីការលែងលះនឹងចូលជាស្ថាពរនៅពេលដែល អំឡុងពេលនៃបណ្តឹងឧបាស្រ័យបានកន្លងផុត។ បើសេចក្តីសម្រេចនេះជាសាលក្រមអំឡុងពេលប្តឹងឧទ្ធរណ៍ គឺ០១ខែ គិតចាប់ពីថ្ងៃដែលបានទទួលលិខិតសាលក្រម។ នៅក្នុងករណីដែលសេចក្តីសម្រេចនេះជាដីការសម្រេច គឺត្រូវប្តឹងជំទាស់ក្នុងអំឡុងពេលពីរសប្តាហ៍គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីដីកាសម្រេចនេះ[46]ដូច្នេះនៅពេលដែលផុតអំឡុងពេលដូចបានបញ្ជាក់ជូនខាងលើនេះ សេចក្តីសម្រេចអំពីការលែងលះនឹងចូលជាស្ថាពរ។

### ៤.៣.១. អានុភាពចំពោះសហព័ន្ធ

ការលែងលះនាំអោយសហព័ទ្ធរួចផុតពីកាតព្វកិច្ចទាំងឡាយដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែទន្ទឹមនឹងនេះច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារអនុញ្ញាតអោយសហព័ទ្ធម្ខាង ទាមទារអាហារកាតិព្វកិច្ចពីសហព័ទ្ធម្ខាងទៀតបានកាលបើមានលក្ខខណ្ឌសមស្របដូចខាងក្រោម[47] ៖

- អតីតសហព័ទ្ធដែលអ្នកស្នើសុំនោះគ្មានកំហុសក្នុងការលែងលះគ្នា។
- អតីតសហព័ទ្ធមានការខ្វះខាតបានសេចក្តីថា ភាគីគ្មានកំហុសពុំមានទ្រព្យសម្បត្តិ ឬមុខរបរជាក់លាក់សម្រាប់ចិញ្ចឹមជីវិតខ្លួន។ គួរកត់សម្គាល់ថា ការខ្វះខាតនេះមិនសំដៅតែទៅលើការខ្វះ

[44] ជនជាប់ចោទដែលពុំអាចចូលបង្ហាញខ្លួន

[45] សាលក្រមនេះអាចប្តឹងបាន

[46] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/កម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៤០

[47] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ១៩៨៩ មាត្រា៧៦ និង មាត្រា៧៧

ខាតម្ហូបអាហារសម្រាប់បរិភោគប៉ុណ្ណោះទេ គឺសំដៅទៅលើអ្វីដែលជាធាតុចាំបាច់សម្រាប់ឲ្យជនដែលមានសិទ្ធិទទួលអាហារកាតិព្វកិច្ចអាចរស់ នៅដោយសមស្របដូចជាអាចមានជម្រកសម្លៀកបំពាក់លទ្ធភាពទិញថ្នាំសង្កើវជាដើម។

ជាធម្មតាអតីតសហព័ទ្ធដែលត្រូវផ្តល់អាហារកាតិព្វកិច្ច ត្រូវមានលទ្ធភាពផ្តល់អាហារកិច្ចនោះ។ ក្នុងករណីនេះចៅក្រមពិនិត្យទៅលើប្រាក់បៀវត្ស លទ្ធភាពនៃការរកប្រាក់ចំណូល អាយុ សុខភាពរបស់ជននោះដើម្បីកំណត់ពីអាហារកិច្ចដែលត្រូវបង់។ ក៏ប៉ុន្តែប្រសិនបើជនដែលត្រូវទទួលអាហារកិច្ចរៀបអាព៌ពិពាហ៍ជាថ្មីទៀតជននោះលែងមានសិទ្ធិទទួលអាហារកិច្ចនោះទៀតហើយ។

ចំណែកប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍អាចប្រើនាមត្រកូលដែលមាននៅមុនរៀបអាពាហ៍ពិពាហ៍បាន ឬអាចប្រើនាមត្រកូលដែលបាននៅពេលលែងលះគ្នាក៏បាន។

**ឧទាហរណ៍៖** ព្រំ បញ្ញា បានរៀបការជាមួយនឹងនារីម្នាក់ឈ្មោះ ផាន់ បូផា។ ក្នុងករណីនេះ ផាន់ បូផា អាចប្រើនាមត្រកូលរបស់ប្តីនាងបានដោយប្តូទៅជា ព្រំ បូផា ដដែលកបាន ឬប្តូទៅប្រើឈ្មោះ ផាន់ បូផា វិញក៏បាន។[48]

### ៤.៣.២. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ

ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ ត្រូវធ្វើទៅតាមគោលការណ៍យល់ព្រមរបស់គូភាគីទាំងសងខាង។ ផ្ទុយទៅវិញបើពុំអាចពិភាក្សាគ្នាបានទេ គឺត្រូវតែធ្វើការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកទៅតាមចំណុចនីមួយៗ ដូចខាងក្រោម[49] ៖

- សហព័ទ្ធម្នាក់ៗត្រូវទទួលបាននៅទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន។
- បន្ថែមពីលើទ្រព្យដោយឡែកសហព័ទ្ធម្នាក់ៗត្រូវទទួលបាន នៅ ១ ភាគ ២ នៃទ្រព្យរួម។

**ឧទាហរណ៍៖** ចិន្តា និង សុភាពបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅ ឆ្នាំ ២០០៥។ មុនពេលរៀបអាពាហ៍ពិពាហ៍ ចិន្តាបានទិញរថយន្តមួយគ្រឿង សម្រាប់ប្រកបរតាក់ស៊ី។ ក្រោយរៀអាពាហ៍ពិពាហ៍ចិន្តា នៅតែប្រើប្រាស់រថយន្តនោះដដែល បើម្បីបម្រើជីវភាពគ្រួសារដោយទទួលបាននៅចំណូលគួសម ចំណែកឯសុភាពជាប្រពន្ធវិញ ជាអ្នកធ្វើកិច្ចការផ្ទះ និងមើលថែទាំកូន។ តាមរយៈប្រាក់ចំណូលនេះ ចិន្តា បានទិញដីមួយកន្លែងនៅឆ្នាំ ២០០៨។ នៅឆ្នាំ ២០១៣ នេះ ចិន្តា និង សុភាព បានលែងលះគ្នា ដូច្នេះ ចិន្តា មានសិទ្ធិយកម៉ូតូដែលជាទ្រព្យសម្បត្តិដោយឡែករបស់គាត់បានចំណែកឯដីភូមិវិញដែលជាទ្រព្យរួមគឺត្រូវបែងចែកស្មើគ្នារវាងចិន្តា និង សុភា

[48] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨១

[49] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨០ កថាខណ្ឌទី១ និង កថាខណ្ឌទី២

៣។ ក៏ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តី ឬប្រពន្ធណាមួយតុលាការក៏អាចធ្វើការបែងចែកទ្រព្យសម្បត្តិរួមដោយធ្វើការពិចារណាទៅលើស្ថានភាពផ្សេងៗដូចជាៈ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សារ ឬកាបង្កើនទ្រព្យ អំឡុងពេលរៀបអាពាហ៍ពិពាហ៍ កម្រិតជីភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ វិជ្ជាជីវៈប្រាក់ចំណូលលទ្ធភាពធ្វើការងាររបស់ភាគីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍ ។[50]

**ឧទាហរណ៍ៈ** កញ្ញា សារឿន គឺ ជាប្តីប្រពន្ធនឹងគ្នា ហើយបានសម្រេចចិត្តលែងលះពីគ្នានៅឆ្នាំ ២០១៣ នេះ។ នៅក្នុងចំណងរៀបអាពាហ៍ពិពាហ៍ទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរមាន ៖ ម៉ូតូ មួយគ្រឿង (តម្លៃប្រហែល ៣លានរៀល ) ដែល សារឿន យកទៅប្រប្រាស់ដើម្បីរត់ម៉ូតូឌុប មានគោមួយក្បាលតម្លៃ ២លានរៀល ) និងប្រាក់ចំនួន ៣លានរៀល។ អ្នកទាំងពីរមានកូនពីរនាក់ជាអនតិជន។ ឧបមាថា អ្នកទាំងពីរបានព្រងព្រៀងគ្នាថាឱ្យកញ្ញាជាម្តាយជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ក្រោយពេលលែងលះ។ នៅក្នុងករណីនេះដោយគិតអំពីផលប្រយោជន៍របស់កូនតុលាការអាចប្រគល់ម៉ូតូតម្លៃប្រហែល ៣លានរៀល ឱ្យទៅសារឿន និងគោមួយក្បាលតម្លៃ២លានរៀល និងប្រាក់ ៣លានរៀលឱ្យទៅ កញ្ញា ជាប្រពន្ធ។ ក្នុងសម្តកម្មនេះឃើញថាទ្រព្យសម្បត្តិរួមរបស់ប្តី ប្រពន្ធត្រូវបានបែងចែកទៅអោយកញ្ញាជាប្រពន្ធច្រើជាង សារឿន ដោយខុសពីគោលការណ៍ដែលចែងថាទ្រព្យសម្បត្តិរួមត្រូវបានបែងចែកពាក់កណ្តាលម្នាក់រវាងសហព័ទ្ធ។ ជាក់ស្តែងក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យធ្វើការបែងចែកបែបនេះដើម្បីជាផលប្រយោជន៍របស់កូន។

សូមធ្វើការកត់សម្គាល់ថា ការលែងលះអាចមកពីមូលហេតុបណ្តាលមកពីការប្រើអំពើហិង្សាផ្សេងៗ។ តាមច្បាប់ការប្រើអំពើហិង្សារវាងប្តីប្រពន្ធគឺជាអំពើអនីត្យានុកូល ដែលឈានទៅដល់ការសម្រេចអំពីសំណងនៃការខូចខាតផងដែរ។ ក្នុងអត្តន័យនេះការទាមទារលែងលះ និងការទាមទារសំណងនៃការខូចខាតដូចខាងលើនេះអាចធ្វើក្នុងបណ្តឹងតែមួយបាន។[51]

ផ្សេងពីនេះទៀត តុលាការក៏អាចសម្រេចឲ្យសហព័ទ្ធណាម្នាក់សងតម្លៃនៃទ្រព្យសម្បត្តិដោយឡែកដែលភាគីម្ខាងទៀតបានបំផ្លាញក្នុងអំឡុងពេលមានចំណងរៀបអាពាហ៍ពិពាហ៍បានដែរ។

**ឧទាហរណ៍ៈ** ឈ្មោះ ក និង ឈ្មោះ ខ ជាប្តីប្រពន្ធ និងគ្នា។ ឈ្មោះ ក បានយកខ្សែដៃមាសរបស់ ឈ្មោះ ខ ជាប្រពន្ធ (ខ្សែដៃដែលម្តាយរបស់ឈ្មោះ ខ បានផ្តល់ជាអំណោយឱ្យ ខ ) ទៅលក់ដើម្បីយកប្រាក់ទៅលេងល្បែង

[50] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨០ កថាខណ្ឌទី២ ចំណុច ខ

[51] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា១១

ដោយមិនឲ្យមិនឲ្យ ឈ្មោះ ខ ដឹងឡើយ។ នៅពេលលែងលះតុលាការអាចសម្រេចឲ្យឈ្មោះ ក សងតម្លៃនៃខ្សែដៃឱ្យ ខ វិញ ព្រោះថាខ្សែដៃនោះជាទ្រព្យដោយឡែករបស់ឈ្មោះ ខ។

**៤.៣.៣. អានុភាពចំពោះកូន**

នៅក្នុងករណីមានការលែងលះតុលាការត្រូវតែកំណត់ពីអ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ពោលគឺទោះបីជាមិនមានពាក្យសុំពីភាគីក៏ដោយ។[52] ជាគោលការណ៍ការកំណត់ត្រូវតែធ្វើឡើងតាមការពិភាក្សារបស់សហព័ទ្ធ។ ប៉ុន្តែប្រសិនបើមិនអាចពិភាក្សាគ្នាបានទេតុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាទៅលើផលប្រយោជន៍របស់កូន។[53]

**ឧទាហរណ៍៖** ឈ្មោះ ក បានប្ដឹងលែងលះពីឈ្មោះ ខ។ អ្នកទាំងពីមានកូនម្នាក់ដែលមានអាយុ ៨ឆ្នាំប៉ុណ្ណោះ។ អ្នកទាំងពីរទាមទារសិទ្ធិគ្រប់គ្រងចិញ្ចឹមកូនរៀងៗខ្លួន។ ឈ្មោះ ក មានមុខរបបរជាកសិករចំណែកឯឈ្មោះជាប្រពន្ធពុំមានប្រាក់ចំណូលអ្វីទេ។ ក៏ប៉ុន្តែឈ្មោះ ក ចូលចិត្តផឹកស្រាស្រែកឡូឡាដេរគេដេរឯង។ ក្នុងករណីនេះទោះបីជាឈ្មោះ ក មានមុខរបរមានប្រាក់ចំណូល កដោយចរិតលក្ខណះរបស់ឈ្មោះ ក ដែលចូលចិត្តផឹកស្រា ស្រែកឡូឡា ដេរគេដេរឯង អាចធ្វើឲ្យមានផលអវិជ្ជមានយ៉ាងខ្លាំង ដល់កូនដែករស់នៅជាមួយ។ ហេតុដូច្នេះ តុលាការអាចប្រគល់អំណាចមេបាលើកូនទៅឱ្យឈ្មោះ ខ វិញ។

ម៉្យាងវិញទៀតប្រសិនបើមានការលែងលះ នៅពេលដែលកូនកើតម្ដាយគឺជាអ្នកមានអំណាច។ ប៉ុន្តែក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាលើកូនបាន តាមរយៈការពិភាក្សារវាងឪពុកម្ដាយ។[54] ផ្ទុយទៅវិញប្រសិនបើមិនអាចពិភាក្សាគ្នាបានទេ តុលាការជាអ្នកសម្រេចនៅពេលដែលមានពាក្យសុំរបស់ឪពុកដោយផ្អែកតាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

ចំពោះភាគីដែលមិនមានអំណាចមេបាលើកូន គាត់មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងកូន និងមានករណីយកកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។[55] ជាគោលការណ៍ការកំណត់ពីបញ្ហានេះត្រូវធ្វើឡើងដោយ ផ្អែកតាមការសិក្សារបស់ឪពុកម្ដាយហើយនៅក្នុងករណីដែលមិនអាចពិភាក្សាគ្នាបានទេតុលាការជាអ្នកកំណត់តាមការទាមទាររបស់ឪពុកម្ដាយណាម្ខាង។ ពាក់ព័ន្ធនឹងការសម្រេចសេចក្ដីពីការចូលជួប និងប្រាស្រ័យទាក់ទងក្រមរដ្ឋប្បវេណីតម្រូវអោយតុលាការអាចពិចារណាទៅលើផលប្រយោជន៍កូនជាអាទិភាព។

[52] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២

[53] ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៧ កថាខណ្ឌទី១ និង កថាខណ្ឌទី៣

[54] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៧ កថាខណ្ឌទី២

[55] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៤០ កថាខណ្ឌទី១

ក្នុងន័យនេះតុលាការអាចពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជាទំនាក់ទំនងរវាងកូន និងឪពុកម្តាយនៅពេលរស់នៅជាមួយគ្នា អាយុ ស្ថានភាពសុខភាពរបស់កូនបំណងរបស់កូនបំណងភាគីសងខាង ព្រមទាំងស្ថានភាពផ្លូវចិត្តរបស់ភាគីសងខាងជាដើម។ សម្រាប់សោហ៊ុយចាំបាច់ ដើម្បីសគ្រប់គ្រងថៃរក្សាកូនក្រមរដ្ឋប្បវេណីបានតម្រូវ អោយតុលាការពិចារណាទៅលើស្ថានភាព នៃជីវភាពនិងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយទាំងសងខាង។ ជាទូទៅ ការតម្រូវអោយភាគីម្ខាងបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថៃរក្សាកូន គឺធ្វើឡើងដោយកំណត់ទៅតាមខែនីមួយៗ ហើយតុលាការនឹងសម្រេចថាត្រូវបង់សោហ៊ុយនេះចាប់ពីពេលណារហូតដល់ពេលណាជាកំណត់ជាក់លាក់។

**ឧទាហរណ៍៖** សំភី និង រស្មី បានលែងលះគ្នា។ តុលាការបានសម្រេចប្រគល់កូន ឈ្មោះ ដារ៉ា ដែលមានអាយុទើបតែ ៥ ឆ្នាំ ទៅអោយ រស្មី ជាម្តាយមានអំណាចមេបាលើ ដារ៉ា។ ចំណែកឯ សំភី ជាឪពុកដែលពុំមានអំណាចមេបាលើ ដារ៉ា ទេ។ ទន្ទឹមនឹងនេះ តុលាការបានសម្រេចឲ្យ សំភី ចូលជួបប្រាស្រ័យទាក់ទងជាមួយ នឹង ដារ៉ា ម្តងក្នុង១សប្តាហ៍ ដោយកំណត់ដោយយកថ្ងៃអាទិត្យចាប់ពីម៉ោង ១៤៖០០ រហូតដល់ម៉ោង ១៧: ០០នៅលំនៅដ្ឋានរបស់ រស្មី។ ត្រង់ចំណុចនេះគឺជាសិទ្ធិចូលជួប និងប្រាស្រ័យទាកទងរបស់ សំភី។ ក្រៅពីនេះតុលាការបានសម្រេចឲ្យ សំភី បង់ប្រាក់ដើម្បីឲ្យ រស្មី ចិញ្ចឹមបីបាច់ថៃរក្សា ដារ៉ា ចំនួន ១លានរៀលក្នុងមួយខែដោយគិតចាប់ពីពេលសេចក្តីសម្រេចលែងលះចូលជាស្ថាពរ រហូតដល់កូនមាននីតិភាព។ នេះគឺជាសេចក្តីសម្រេចអំពីសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថៃរក្សាកូន ឬក៏ពេលខ្លះគេប្រើពាក្យថាអាហារកាតព្វកិច្ច។

ទាក់ទងនឹងការសម្រេចសេចក្តីពីការកំណត់អ្នកមានអំណាចមេបា ឬការចាត់ចែងទាក់ទងនឹងបីបាច់រក្សាកូនដូចបានរៀបរាប់ខាងលើនេះតុលាការត្រូវពិចារណាថ្លឹងថ្លែងទៅលើយោបល់របស់កូនសមស្របទៅតាមអាយុនិងសភាពចាស់ទុំរបស់កូននោះ។[56]

ទោះបីជាតុលាការបានសម្រេចសេចក្តីពីការកំណត់អ្នកមានអំណាចមេបាការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនព្រមទាំងសោហ៊ុយចាំបាច់ ដើម្បីថៃរក្សាកូនរួចហើយក៏ដោយក៏សេចក្តីសម្រេចទាំងនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរបានដែរ។[57]

**ឧទាហរណ៍៖** លក្ខិណា បានលែងលះគ្នាពី សារ៉ាយហើយនាងត្រូវបានតុលាការសម្រេចប្រគល់អំណាចមេបា លើកូនម្នាក់ដែលជាអនីតិជន។ មូលហេតុនៃការសម្រេចយ៉ាងដូចច្នេះ គឺមកពីសារ៉ាយ តែងតែផឹកស្រាស្ររវឹងជាប្រចាំ។ ឧបមាថា សារ៉ាយ បានកែប្រែខ្លួនដោយឈប់ផឹកស្រាបង្ករឿងរ៉ាវដល់អ្នកដ៏ទៃទៀតហើយចំណែក

[56] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២ កថាខណ្ឌទី៤

[57] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា១០៣៩ និង មាត្រា ១០៤០ កថាខណ្ឌទី៥

លក្ខិណាមានការខ្វះខាតយ៉ាងខ្លាំងក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនហើយពេលខ្លះ លក្ខិណា បានឲ្យកូនសុំទានយកប្រាក់មកផ្គត់ផ្គង់ជីវភាពទៀតផង។ ក្នុងស្ថានភាពបែបនេះបើសិនជា សារ៉ាយ ស្នើសុំឱ្យតុលាការផ្លាស់ប្ដូរអំណាចមេបាលើកូន ពោលគឺទាមទារឲ្យ លក្ខិណាប្រគល់កូនឲ្យ សារ៉ាយមានឪកាសច្រើននឹងទទួលបានអំណាចមេបាលើកូនវិញ។

ដូចគ្នាដែរក្នុងសម្មតិកម្មខាងលើដែលតុលាការសម្រេចអោយ សំភី ជាឪពុកបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់ គ្រងថែរក្សាកូន១លានរៀលក្នុងមួយខែ ក៏ប៉ុន្តែក្រោយមក សំភី បានបាត់បង់ការងារដែលមិនអាចរកចំណូលបានច្រើនដូចពីមុន។ ក្នុងករណីបែបនេះ សំភី អាចសុំដាក់ពាក្យទៅតុលាការឲ្យបន្ថយចំនួនសោហ៊ុយនេះបាន (ឧទាហរណ៍ ដូចជាសម្រេចអោយបន្ថយសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនមកត្រឹមតែ ៤សែនរៀល ក្នុងមួយខែវិញ)។ លើសពីនេះទៅទៀតប្រសិនភាគីដែលមានករណីយកិច្ចត្រូវបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ឬអាហារកិច្ច តាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការហើយបែជាមិនព្រមគោរពតាមសេចក្តីសម្រេចនេះនឹងនាំឲ្យមានទណ្ឌកម្មពីរប្រភេទគឺ៖

- **ទណ្ឌកម្មរដ្ឋប្បវេណី៖** ម្ចាស់បំណុល (ជនដែលមានសិទ្ធិទាមទារអាហារកិច្ច ) អាចដាក់ពាក្យសុំដើម្បីឲ្យមានការអនុវត្តករណីយកិច្ចរបស់ខ្លួនតាមក្រមនីតិវិធីរដ្ឋប្បវេណី ដូចជាការរឹបអូសទ្រព្យសម្បត្តិជាដើម។
- **ទណ្ឌកម្មព្រហ្មទណ្ឌ៖** ការមិនគោរពតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ ដោយមិនព្រមបង់ក្នុងរយៈពេល ២ខែ យ៉ាងតិចនូវអាហារកាតព្វកិច្ចដល់សហព័ទ្ធ ឬអតីតសហព័ទ្ធរបស់ខ្លួនដល់កូនជាអនីតិជន ដល់បច្ឆាញាតិ ឬបុព្វញាតិផ្សេងទៀតរបស់ខ្លួននោះត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារពី ១ខែទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១ សែនរៀលទៅ ២ លានរៀល (មាត្រា ៣២៤ នៃក្រមព្រហ្មទណ្ឌ ) សរុបសេចក្តីមកអំពើនេះត្រូវបានចាត់ទុកថាជាបទល្មើសដែលមានឈ្មោះថាបទបោះបង់គ្រួសារ។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តបតាមការបកស្រាយខាងលើក្រុមរបស់យើងខ្ញុំយល់ឃើញថាទាក់ទងនឹងការលែងលះក្រមរដ្ឋប្បវេណីថ្មីមានចំណុចដូចគ្នា និង ចំណុចពិសេសពីបទប្បញ្ញត្តិនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។ ចំណងអាពាហ៍ពិពាហ៍មួយអាចកើតឡើងបានលុះត្រាតែភាគីទាំងសងខាង គោរពទៅតាមនីតិវិធីដែលច្បាប់បានចែង ក៏ដូចជាលក្ខខណ្ឌនានាដែលច្បាប់តម្រូវឱ្យភាគីនីមួយៗអនុវត្តតាម។

ជាងនេះទៅទៀត ប្រសិនបើចំណងអាពាហ៍ពិពាហ៍ដែលស្របច្បាប់របស់ពួកគាត់មានភាពរង្គោះរង្គើ ឬជួបប្រទះនូវបញ្ហាមួយចំនួនដែលនាំឱ្យឈានដល់ ដំណាក់កាលដែលមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ទោះបីជាពួកគាត់ធ្លាប់ទទួលបាននូវការផ្សះផ្សារ ដែលពេលខ្លះការផ្សះផ្សារនោះទទួលបានជោគជ័យហើយបញ្ហាមួយចំនួនមិនអាចធ្វើការផ្សះផ្សារបានដែលមូលហេតុទាំងនេះហើយដែលធ្វើឱ្យ ចំណងអាពាហ៍ពិពាហ៍របស់ពួកគាត់ឈានទៅដល់ការលែងលះ។

ក្នុងករណីដែលពួកគាត់ចង់លែងលះគ្នា សហព័ទ្ធទាំងពីរត្រូវតែដាក់ពាក្យសុំលែងលះទៅតុលាការ និងត្រូវឆ្លងកាត់នូវនីតិវិធីតាមផ្លូវតុលាការជា ច្រើនដំណាក់កាលទៀតទើបពួកគាត់អាចធ្វើការលែងលះគ្នាបាន ។ ដោយយោងទៅតាមបញ្ញត្តិមាត្រាដែលមានចែងនៅក្នុង ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានការពារនូវផលប្រយោជន៍របស់សហព័ទ្ធទាំងសងខាង បន្ទាប់ពីពួកគាត់បានលែងលះគ្នាហើយនោះមិនថាជាភាគីប្តី ឬ ប្រពន្ធ ព្រមទាំងកូនផងដែរត្រូវទទួលបាននូវការការពារពីច្បាប់។ នៅពេលដែលការលែងលះមានអានុភាពហើយ នោះសហព័ទ្ធទាំងពីរត្រូវតែធ្វើការព្រមព្រៀងគ្នានូវការបែងចែកទ្រព្យសម្បត្តិ ការផ្តល់នូវអាហារកាតព្វកិច្ចដល់កូននឹងដល់អតីតសហព័ទ្ធណាមួយដែលមានការខ្វះខាតក្រោយការលែងលះការប្រគល់អំណាចមេបាដោយឲ្យកូនទៅរស់នៅជាមួយសហព័ទ្ធណាមួយ និងសហព័ទ្ធដែលមានអំណាចមេបាត្រូវផ្តល់ឱកាសឱ្យសហព័ទ្ធដែលមិនមានអំណាចមេបាបានជួបប្រាស្រ័យទាក់ទងជាមួយកូនផងដែរ។

អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថាបច្ចុប្បន្ននេះក្រមរដ្ឋប្បវេណីដាក់ឱ្យអនុវត្ត ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីហើយបទបញ្ញត្តិនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារត្រូវបាននិរាករណ៍ស្ទើរទាំងស្រុង លើកលែងតែបទប្បញ្ញត្តិទាក់ទងនឹងអាពាហ៍ពិពាហ៍ជាមួយជនបរទេសតែប៉ុណ្ណោះ។

ទោះយ៉ាងណាក៏ដោយ ការលែងលះបានជះផលវិបាកជាច្រើនចំពោះទំនាក់ទំនងសង្គម។ បើសិនជាសង្គមមួយសម្បូរទៅដោយការលែងលះនោះគេ នឹងជួបនូវបញ្ហាច្រើនជាពិសេសផលវិបាកដែលមានទៅលើសារតីរបស់កូនដែលជាទំពាំងស្នងឫស្សី។ យើងសង្ឃឹមយ៉ាងជឿជាក់ថាប្រជាពលរដ្ឋកម្ពុជានឹងរក្សាជំហរមុតមាំក្នុងការកសាងសុភមង្គលគ្រួសារនិងបន្តពូជពង្សត្រកូលដោយចីរកាល។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសរសេរ និងរៀបចំនូវសារណាបញ្ចប់ការសិក្សានេះរួចមកឃើញថាប្រជាជនមួយចំនួនមិនមានការយល់ដឹងអំពីអាពាហ៍ពិពាហ៍ និងការលែងលះនៅឡើយដោយពួកគាត់ពុំបានទទួលនូវការផ្សព្វផ្សាយអំពីឯកសារច្បាប់ដែលពាក់ព័ន្ធ ដើម្បីធ្វើការរៀបអាពាហ៍ពិពាហ៍ និងការលែងលះគ្នាជាដើម។ ជាពិសេសប្រជាជនដែលរស់នៅតំបន់ជនបទដាច់ស្រយាល ពុំបានយល់ដឹងអំពីនីតិវិធីដែលនាំឱ្យមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ ដោយពួកគាត់អនុវត្តតាមទំនៀមទម្លាប់ប្រពៃណីដែលមានតាំងពីដូនតាមកម្លេះដោយពួកគាត់គ្រាន់តែរៀបចំប្រារព្ធនូវអាពាហ៍ពិពាហ៍ដើម្បីជាការបង្ហាញថា កូនកំលោះ កូនក្រមុំ ជាស្វាមីភរិយានឹងគ្នាហើយដោយពុំបានបំពេញទៅតាមផ្លូវច្បាប់ដូចជាគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍អ្វីឡើយ ។ មួយវិញទៀតនៅពេលដែលវិវាទកើតឡើងរវាងប្តី និង ប្រពន្ធ មិនដឹងថាតើត្រូវទៅប្តឹងទៅសមត្ថកិច្ចណាមួយឱ្យជួយដោះស្រាយ ដើម្បីទទួលបាននូវអានុភាពនៅក្រោយពេលលែងលះ។

ដោយកង្វះខាតមួយចំនួននេះហើយទើបក្រុមរបស់យើងខ្ញុំ សូមចូលរួមនូវការផ្តល់ជាមតិយោបល់មួយចំនួនក្នុងគោលដៅដើម្បីធ្វើការកែតម្រូវនូវចំណុចទាំងនោះដូចជា៖

រដ្ឋាភិបាលត្រូវផ្តល់ការផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យប្រជាជនបានយល់ច្បាស់អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ និងនីតិវិធីនៃការលែងលះ ដើម្បីជាភាពងាយស្រួលដល់ពួកគាត់ហើយក៏ជាភាពងាយស្រួលដល់ពួកគាត់ ហើយក៏ជាចំណេះដឹងបន្ថែមទៀតសម្រាប់ពួកគាត់បើប្រាស់នៅពេលណាដែលគាត់ជួបប្រទះបញ្ហាទាំងនោះ ហើយក៏ជាវិធីមួយដើម្បីជួយកាត់បន្ថយនូវការលែងលះគ្នាផងដែរ។ សហព័ទ្ធទាំងពីរ ត្រូវតែស្មោះស្ម័គ្រមួយនឹងមួយ ដោយពុំមានចិត្តវៀចវេដើម្បីរក្សានូវចំណងអាពាហ៍ពិពាហ៍កុំឱ្យឈានដល់ការលែងលះដែលជាមូលហេតុធ្វើឱ្យគ្រួសារដែលធ្លាប់តែមានសុភមង្គល ប្រែទៅជាគ្រួសារដែលបែកបាក់ទៅវិញ។ រាល់កំហុសតិចតួចដែលសហព័ទ្ធណាម្ខាងបានប្រព្រឹត្តត្រូវតែចេះអត់អោន អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមកដើម្បីបញ្ចៀសនូវការបែកបាក់។

ជាចុងក្រោយបំផុតក្នុងគោលបំណង និងឆន្ទៈដើម្បីធ្វើឲ្យស្នាដៃមួយនេះអាចយកទៅអនុវត្តបានយ៉ាងត្រឹមត្រូវសមស្របទៅនឹងស្ថានភាពនិងកាលៈទេសៈជាក់ស្តែងក៏ដូចជាកាត់បន្ថយការលែងលះក្នុងសង្គម យើងខ្ញុំសូមការអនុញ្ញាតលើកឡើងនូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ចំពោះរដ្ឋ ឬរដ្ឋាភិបាល

-សូមរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឱ្យបានយល់ដឹងគ្រប់ៗគ្នាជាពិសេសដាក់ទណ្ឌកម្មដល់អ្នករំលោភបំពានច្បាប់នេះ និងអ្នកប្រើប្រាស់អំពើ

ហិង្សាក្នុងគ្រួសារឲមានលក្ខណៈធ្ងន់ធ្ងរសូមឲ្យមានការការពារផ្លូវច្បាប់ដោយតុលាការ នៅក្នុងករណីមានការលែងលះគ្នា។

-សូមឲ្យស្ថាប័នដែលពាក់ព័ន្ធគួរតែបណ្តុះបណ្តាល ដល់មន្ត្រីដែលធ្វើការផ្អែកអត្រានុកូលដ្ឋានតាមមូលដ្ឋានឲ្យយល់ដឹងបានទូលំទូលាយពីសេវាសាធារណៈនេះ ដើម្បីឲ្យពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារជូនប្រជាពលរដ្ឋ។

-សូមរាជរដ្ឋាភិបាល មេត្តាទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងឲ្យមានប្រសិទ្ធភាព និងស្របតាមពេលវេលាជាក់ស្តែង។

-សូមរាជរដ្ឋាភិបាលជួយទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននៅ ក្នុងសង្គមឲ្យមានប្រសិទ្ធភាពខ្ពស់។

➢ ចំពោះមន្ត្រីអនុវត្តច្បាប់

-សូមឲ្យមន្ត្រីនៅថ្នាក់មូលដ្ឋានដែលពាក់ព័ន្ធទៅ នឹងសំណុំរឿងនៃការលែងលះគួរតែជួយផ្សះផ្សារសហព័ន្ធនោះឲ្យអស់លទ្ធភាពជាមុនសិន មុនពេលសម្រេចចិត្តឲ្យពួកគាត់លែងលះគ្នាតាមផ្លូវតុលាការ។

-សូមឲ្យអាជ្ញាធរដែនដីធ្វើអន្តរាគមន៍ជា បន្ទាន់រាល់ពេលមានអំពើហិង្សាកើតឡើង ដើម្បីទប់ស្កាត់កុំឲ្យមានអំពើហិង្សាធ្ងន់ធ្ងររហូតឈានទៅដល់ការលែងលះគ្នា។

-សូមឲ្យមន្ត្រីដែលពាក់ព័ន្ធ មេត្តាផ្តល់នូវជំនួយផ្លូវច្បាប់ណាមួយដែលសមស្របតាមរយៈកាលៈទេសៈជាក់ស្តែង និងធានាសុវត្ថិភាពដល់គូភាគីនៅពេលមានបណ្តឹងលែងលះកើតឡើង។

-សូមមន្ត្រីនៅថ្នាក់មូលដ្ឋាន ចុះបណ្តុះបណ្តាលជូនពលរដ្ឋរបស់ខ្លួនពីផលប៉ះពាល់ នៃការលែងលះ និងផលប៉ះពាល់នៃការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ

➢ ចំពោះប្តីប្រពន្ធ

-សូមប្តីប្រពន្ធគិតឲ្យបានវែងឆ្ងាយមុនសម្រេចចិត្តលែងលះគ្នា ព្រោះផលប៉ះពាល់ដែលបណ្តាលមកពីការលែងលះគ្នា នឹងធ្លាក់ទៅលើកូនៗរបស់យើងខ្លាំងជាងគេ។

-សូមប្តីប្រពន្ធទាំងឡាយរៀនតាំងចិត្តថែរក្សាទំនាក់ទំនងឲ្យមានភាពរឹងមាំព្រោះគ្មានអ្វីដែលថា ធ្វើមិនបាននោះទេប្រសិនបើមានការតាំងចិត្ត ។ ការតាំងចិត្តថែរក្សានូវទំនាក់ទំនងប្តីប្រពន្ធតម្រូវផងដែរឲ្យដៃគូទាំងសងខាងមានការតាំងចិត្តខ្ពស់ទើបអាចថែរក្សានូវទំនាក់ទំនងប្តីប្រពន្ធឲ្យមានភាពរឹងមាំ និងមិនអាចប្រះឆាគ្នាបាន ។

-សូមប្តីប្រពន្ធទាំងសងខាងរៀនគិតវិជ្ជមានអំពីគ្នាទៅវិញទៅមក ព្រោះវាមិនត្រឹមតែធ្វើឱ្យយើងរស់នៅយ៉ាងមានក្តីសុខនោះទេ វាក៏ជារឿងមួយដែលមានប្រយោជន៍ជាខ្លាំងសម្រាប់ទំនាក់ទំនងប្តីប្រពន្ធព្រោះ ថានៅ

ពេលដែលគិតអ្វីដែលល្អៗ អំពីគ្នាវាក៏ជាវិធីសាស្ត្រមួយដែលធ្វើឲ្យមនុស្សពីរនាក់បង្កើននូវការទុកចិត្តគ្នា លើសពីនេះវាក៏ជួយឱ្យទំនាក់ទំនងរវាងប្តីប្រពន្ធរបស់មនុស្សពីរនាក់ជៀសផុតពីការឈ្លោះប្រកែកគ្នា។

-សូមប្តីប្រពន្ធចេះប្រើពាក្យសុំទោសដាក់គ្នានៅពេលដែលធ្វើខុសពិតណាស់ក្នុង ការរក្សាជីវិតគូឱ្យមានសុភមង្គល គឺតម្រូវឱ្យមនុស្សពីរនាក់ចេះប្រើនូវពាក្យសុំទោសនៅពេលដែលធ្វើខុស លើសពីនេះរៀនធ្វើជាចាញ់ និងមិនចង់ឈ្នះគ្នា នោះហើយដែលជាវិធីមួយដែលអាចជួយឲ្យបញ្ហារបស់ប្តីប្រពន្ធកាន់តែមានភាពធូរស្រាល ពីបញ្ហាដែលបានកើតឡើងនោះ។

-សូមប្តីប្រពន្ធចេះជួយកែតម្រូវគ្នាទៅវិញទៅមក ព្រោះមនុស្សយើងកើតមកមិនមាននរណាម្នាក់ថាមិនចេះធ្វើខុសនោះទេ ដូច្នេះហើយជីវិតជាប្តីប្រពន្ធក៏រមែងតែងមានការធ្វើខុស ចំពោះគ្នាដោយមិនដឹងខ្លួនអញ្ចឹង ហើយវាក៏តម្រូវឱ្យមនុស្សពីរនាក់មានការកែតម្រូវឲ្យគ្នាទៅវិញទៅមកនូវចំណុចណាមួយដែលខ្វះខាត លើសពីនេះការធ្វើបែបនេះវាក៏ធ្វើឱ្យទំនាក់ទំនងប្តីប្រពន្ធរបស់មនុស្សពីរនាក់កាន់តែមានភាពស្និទ្ធស្នាល និងកាន់តែយល់ចិត្តគ្នាទៀតផង។

-សូមប្តីប្រពន្ធគ្រប់គូព្យាយាមមើលពីបញ្ហាគ្នាទៅវិញទៅមក ព្រោះគូស្នេហ៍ដែលរស់នៅជាមួយគ្នាយ៉ាងមានសុភមង្គលនោះ គឺពួកគេតែងតែព្យាយាមយល់នូវបញ្ហាដែលបានកើតឡើង ចំពោះជីវិតប្តីប្រពន្ធរបស់ពួកគេ។ ជាងនេះទៅទៀតពួកគេមិនមែនខឹងគ្នា ឬបន្ទោសគ្នាទៅវិញទៅមកនោះទេគឺពួកគេតែងតែចំណាយពេលវេលាដើម្បីពិភាក្សានិងរកដំណោះស្រាយជាមួយគ្នា ដូច្នេះហើយមិនថាបញ្ហាតូច ឬធំខ្លាំងប៉ុណ្ណានោះទេក៏មិនអាចបំផ្លាញសុភមង្គលប្តីប្រពន្ធរបស់ពួកគេបាននោះទេ។

# ឯកសារយោង

## ឯកសារយោង

## ច្បាប់ និងបទដ្ឋានគតិយុត្តជាតិ

- ក្រមនីតិវិធីរដ្ឋប្បវេណី ចុះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណី ចុះនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីបណ្តឹងវិវាទគ្រួសារ
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩
- ច្បាប់ស្តីពីឯកពន្ធភាព ចុះនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦
- ច្បាប់ស្តីពី នីតិវិធីបណ្តឹងពាក់ព័ន្ធ នឹងឋានៈបុគ្គល ឆ្នាំ២០១០
- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចុះនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ស្តីអំពីរបៀបចាក់ចែងរឿងក្តីលែងលះ
- អនុក្រឹត្យលេខ១០៣អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ចុះនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០

## សៀវភៅផ្សេងៗ

- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត
- វចនានុក្រមភាគ១ និងភាគ២ សម្តេចព្រះសង្ឃរាជ ជួន ណាត ១៦ វចនានុក្រមខ្មែរអង្គរដែលធ្វើការកែសម្រួលពីវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ទំព័រ៧៣
- វចនានុក្រមអង់គ្លេស Cambridge University Press 1995 Page 403
- សៀវភៅក្រមរដ្ឋប្បវេណីភាគ១ ដល់ ៦ បោះពុម្ព ខែកក្កដា ឆ្នាំ២០០៧
- សៀវភៅសេចក្តីពន្យល់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណ( គត្តិទី៧)
- សៀវភៅសេចក្តីពន្យល់មាត្រានីមួយៗ ក្រមនីតិវិធីរដ្ឋប្បវេណ សៀវភៅ និតិបេតិកកណ្ឌ និងគ្រួសាររបស់សាស្រ្តារ្យ អ្នកស្រី វណ្ណធី
- សាស្រ្តាចារ្យ ឥន យឿន, ឆ្នាំ២០១៣ នីតិគ្រួសារ និងអាពាហ៍ពិពាហ៍
- សាស្រ្តាចារ្យ អម សុផាណារ៉ាត, ឆ្នាំ២០១៥ នីតិរដ្ឋប្បវេណី
- សាស្រ្តាចារ្យ អ្នកស្រីវណ្ណធី, ឆ្នាំ២០១៨ នីតិបេតិកណ្ឌ និងគ្រួសារ

## គេហទំព័រ

- លោកស្រី ហ៊ុយ ច័ន្ទរស្មី ជាសិស្សក្រឡាបញ្ជីជំនាន់ទី៥ នៃរាជបណ្ឌិត សភាវិជ្ជាជិវៈតុលាការ

ឆ្នាំ២០១៨

- លោកមេធាវី YOSHI SAWA TOSHI YUKI , ឆ្នាំ២០១៨ ការលែងលះ និងនីតិវិធីនៃការលែងលះ
- សៀវភៅស្តីពី នីតិគ្រួសារ ដោយលោកស្រី ចាំង ស៊ីណាត
- សារណាបញ្ចប់ការសិក្សា ការលែងលះ របស់លោក ឡេា គ្រឹម ឆ្នាំ២០១២
- សារណាបញ្ចប់ការសិក្សាអាពាហ៍ពិពាហ៍ និងគ្រួសារ របស់លោក កែវ ពេជ្រ និង លោក ឡុង វីរៈ ឆ្នាំ២០១៧
- សារណាបញ្ចប់ការសិក្សា ការលែងលះនៅកម្ពុជាបច្ចុប្បន្ន របស់លោក អុន ផល្លីន និង កញ្ញា ពុទ្ធលីនថាវី ឆ្នាំ២០១៩
- សារណាបញ្ចប់ការសិក្សា អាពាហ៍ពិពាហ៍ និងការលែងលះ របស់លោក ក្វាស ភិក និងលោក ឆាយ ម៉េនឈុន ឆ្នាំ២០២០
- សារណាបញ្ចប់ការសិក្សា ការលែងលះ និងផលប៉ះពាល់នៃការលែងលះ របស់បង ហ៊ួ រ័ត្ននៈ និង បងងៀន ពុទ្ធារី ឆ្នាំ២០២១
- សាលាត្រាជូ p(salatraju.com)
- សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-បារាំង-អង់គ្លេស អនុម័តនៅឆ្នាំ ២០០៧ ដោយគណៈកម្មការបណ្ឌិតសភា
- ទទួលបន្ទុកអនុម័តពាក្យច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី
- វាក្យស័ព្ទច្បាប់អេឡិចត្រូនិក online terminology របស់សមាគមសាលាត្រាជូ
- https://salatraju.com/index.php/post?p=22
- [https://km.warbletoncouncil.org/causas-divorcio-5432#menu-12](https://km.warbletoncouncil.org/causas-divorcio-5432#menu-12)
- https://km.drafare.co

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**១. ឧបសម្ព័ន្ធទី១ ៖** នីតិវិធីនៃការលែងលះ

- តារាងលំហូរនៃនីតិវិធីលែងលះ
- បញ្ជីអាពាហ៍ពិពាហ៍
- សំបុត្រអាពាហ៍ពិពាហ៍
- សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
- ការលែងលះដោយគ្មានកូន

**២. ឧបសម្ព័ន្ធទី២ ៖** នីតិវិធីនៃការដាក់ពាក្យលែងលះនៃអាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀង

- ពាក្យសុំលែងលះតាមការព្រមព្រៀង
- ពាក្យបណ្តឹង
- ដីកាកោះចុងចម្លើយ
- ដីកាកោះដើមចោទ
- កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូង
- ដីកាសម្រេច

**៣. ឧបសម្ព័ន្ធទី៣ ៖** នីតិវិធីនៃការដាក់ពាក្យលែងលះនៃអាពាហ៍ពិពាហ៍ដោយសហព័ទ្ធម្ខាង

- ពាក្យបណ្តឹងលែងលះ
- ដីកាកោះចុងចម្លើយ
- ដីកាកោះដើមចោទ
- ដីកាបញ្ជូន
- កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កំណត់ហេតុស្តីពីនីតិវិធីសាកសួរសាមុីភាគី
- សាលក្រម
- លិខិតបញ្ជាក់សាលក្រមស្ថាពរ
- រូបមន្តអនុវត្តសាលក្រម

# ឧបសម្ព័ន្ធទី១ ៖
# នីតិវិធីនៃការលៃខលះ


តារាងលំហូរនៃនីតិវិធីលែងលះ
បានចុះបញ្ជីអាពាហ៍ពិពាហ៍
YES
ភាគីទាំងពីរបានព្រមព្រៀងលែងលះគ្នា
YES
មានកូនដែលជាអនីតិជន
YES
បានកំណត់អំពីអ្នកមានអំណាចមេបា
YES
"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (ដីកាសម្រេច)"
ពាក្យសុំលែងលះដោយការព្រមព្រៀងផ្អែកតាមបញ្ញត្តិនៃមាត្រា ៩៧៩ នៃក្រមរ/ដ (មាត្រា ៣ និង ចំណុច ៥ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)
NO
"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (សាលក្រម)"
បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃចំណុច ង កថា/ទី ១ មាត្រា ៩៧៨ នៃក្រមរ/ដ (ចំណុច គ មាត្រា ៣ និង កថា/ទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)
NO
"បើមានតែការលែងលះគ្នា (ដីកាសម្រេច)"
ពាក្យសុំលែងលះដោយការព្រមព្រៀងផ្អែកតាមបញ្ញត្តិនៃមាត្រា ៩៧៩ នៃក្រមរ/ដ (មាត្រា ៣ និង ចំណុច ៥ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)
NO
"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (ករណីដែលមានកូនជាអនីតិជន) (សាលក្រម)"
បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃចំណុចនីមួយៗ កថា/ទី ១ មាត្រា ៩៧៨ នៃក្រមរ/ដ (ចំណុច គ មាត្រា ៣ និង កថា/ទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)
NO
"មិនចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ ! !"
ការលែងលះ គឺជានីតិវិធីរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ (យោងវាក្យខណ្ឌទី ២ មាត្រា ៩៧៩ នៃក្រមរ/ដ)។
អាពាហ៍ពិពាហ៍ នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៥៥ នៃក្រមរ/ដ)។ ពោលគឺ ប្រសិនបើមិនបានបញ្ចប់ឲ្យសព្វគ្រប់នូវការចុះបញ្ជីអាពាហ៍ពិពាហ៍ទេ អានុភាពនៃអាពាហ៍ពិពាហ៍នឹងមិនកើតមានឡើងទេ។
ក្នុងករណីដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ គឺពុំចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ!
ប៉ុន្តែ បុគ្គលដែលបានបដិសេធចោលដោយមិនត្រឹមត្រូវនូវ "ទំនាក់ទំនងអនីតិសង្វាស" ត្រូវទទួលខុសត្រូវសងសំណងខូចខាតដោយមូលហេតុនៃអំពើអនីត្យានុកូល ចំពោះភាគីម្ខាងទៀត។ ជាតើជា "ទំនាក់ទំនងអនីតិសង្វាស" ឬយ៉ាងណានោះ ត្រូវវិនិច្ឆ័យទៅលើ ទាំងឆន្ទៈរបស់គូភាគី និង ទៅលើស្ថានភាពជីវភាពជាក់ស្តែង។


តារាងលំហូរនៃនីតិវិធីលែងលះ
បានចុះបញ្ជីអាពាហ៍ពិពាហ៍
ករណីដែលមានកូនជាអនីតិជន
ជាគោលការណ៍៖ ម្តាយ គឺជាអ្នកមានអំណាចមេបា (កថាខណ្ឌទី ១ មាត្រា ១០៣៨ នៃក្រមរ/ដ)
ករណីលើកលែង៖ ករណីដែលឪពុកទទួលស្គាល់កូននោះ (※) និង ការពិភាក្សារបស់ឪពុកម្តាយបានកំណត់យកឪពុកជាអ្នកមានអំណាចមេបា នោះឪពុកជាអ្នកមានអំណាចមេបា (កថាខណ្ឌទី ២ មាត្រា ១០៣៨ នៃក្រមរ/ដ)។
※ការទទួលស្គាល់ និងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៩៧ នៃក្រមរ/ដ)។ ព្រមទាំងករណីដែលបានចុះហត្ថលេខា ឬ ផ្តិតមេដៃនៅក្នុងសៀវភៅកំណើតជាឈ្មោះខ្លួនជាឪពុក ត្រូវចាត់ទុកជាបានទទួលស្គាល់ (មាត្រា ៩៩៨ នៃក្រមរ/ដ)។
អ្នកមានអំណាចមេបា កំណត់ដោយយកនរណាម្នាក់រវាងម្តាយឬឪពុកតាំងពីដើម។ នៅពេលពីរនាក់បែកគ្នា ពុំចាំបាច់កំណត់អ្នកមានអំណាចមេបាជាថ្មីម្តងទៀតទេ។
ករណីដែលចង់ផ្លាស់ប្តូរអ្នកមានអំណាចមេបា ត្រូវដាក់ពាក្យសុំនីតិវិធីដើម្បីផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា (មាត្រា ១០៣៩ នៃក្រមរ/ដ, មាត្រា ៣ និង ចំណុច ១២ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។
NO
"មិនចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ ! !"
ការលែងលះ គឺជានីតិវិធីរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ (យោងវាក្យខណ្ឌទី ២ មាត្រា ៩៧៩ នៃក្រមរ/ដ)។
អាពាហ៍ពិពាហ៍ នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៥៥ នៃក្រមរ/ដ)។ ពោលគឺ ប្រសិនបើមិនបានបញ្ចប់ឲ្យសព្វគ្រប់នូវការចុះបញ្ជីអាពាហ៍ពិពាហ៍ទេ អានុភាពនៃអាពាហ៍ពិពាហ៍នឹងមិនកើតមានឡើងទេ។
ក្នុងករណីដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ គឺពុំចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ!
ប៉ុន្តែ បុគ្គលដែលបានបដិសេធចោលដោយមិនត្រឹមត្រូវនូវ "ទំនាក់ទំនងអនីតិសង្វាស" ត្រូវទទួលខុសត្រូវសងសំណងខូចខាតដោយមូលហេតុនៃអំពើអនីត្យានុកូល ចំពោះភាគីម្ខាងទៀត។ ជាតើជា "ទំនាក់ទំនងអនីតិសង្វាស" ឬយ៉ាងណានោះ ត្រូវវិនិច្ឆ័យទៅលើ ទាំងឆន្ទៈរបស់គូភាគី និង ទៅលើស្ថានភាពជីវភាពជាក់ស្តែង។


ករណីមានវិវាទលើទ្រព្យសម្បត្តិ
តារាងលំហូរនៃនីតិវិធីលែងលះ
ដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង។ ព្រមទាំងដាក់ពាក្យសុំបែងចែកទ្រព្យសម្បត្តិ ផ្អែកតាមមាត្រា ៣ និង ចំណុច ៦ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។
ដាក់បណ្តឹងទាមទារលែងលះគ្នា។ ព្រមទាំងដាក់ពាក្យសុំចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ផ្អែកតាមកថា/ទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។
ដោយសារតែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ហេតុនេះនាំឲ្យមិនមានទ្រព្យសម្បត្តិរួមដែលកំណត់នៅក្នុងមាត្រា ៩៧៣ នៃក្រមរ/ដទេ។ ទ្រព្យសម្បត្តិដែលមានកម្មសិទ្ធិតែម្ខាង គឺជាទ្រព្យសម្បត្តិដែលបុគ្គលនោះមានកម្មសិទ្ធិ។ ពុំចាំបាច់បែងចែកទ្រព្យសម្បត្តិទេ។
បន្ទាប់ពីបានកំណត់ទ្រព្យសម្បត្តិដែលមានវិវាទ សូមពិចារណាលើការដាក់បណ្តឹងរដ្ឋប្បវេណី ដើម្បីដោះស្រាយវិវាទនោះ។

# នីតិវិធីនៃការលែងលះ

## ✧ ក្នុងករណីប្តីប្រពន្ធមានសំបុត្រអាពាហ៍ពិពាហ៍(អេតាស៊ីវិល)

**ការលែងលះ** គឺសំដៅដល់ការផ្តាច់ ឬរំលាយនូវចំណងអាពាហ៍ពិពាហ៍ដែលស្របច្បាប់ រវាងប្តី និងប្រពន្ធ ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។





ច្បាប់ LAW
អង្គការច្បាប់កម្ពុជា
ការលែងលះ
ការព្រមព្រៀង ពាក្យស្នើសុំលែងលះ
ការស្ម័គ្រចិត្ត របស់ភាគីទាំងសងខាង ។
យោងតាម មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី
ការលែងលះដែលច្បាប់ទទួលស្គាល់លុះត្រាណា តែមានដីការសម្រេចពីតុលាការ តែប៉ុណ្ណោះ !
-សហព័ទ្ធ ប្ដី ឬ ប្រពន្ធ ឬទាំងពីរ ។
-បដិទាន គឺការស្ដារឡើងវិញនូវស្ថានភាពដើម ។
គ្មានការព្រមព្រៀង ពាក្យបណ្ដឹងសុំលែងលះ
មានតែភាគីម្ខាងតែប៉ុណ្ណោះដែលចង់លែងលះ ។
ត្រូវមានមូលហេតុដូចខាងក្រោម
ក.បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ
ខ. បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ។
គ. បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង ១ឆ្នាំ ។
ឃ. បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។
ង. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។
យោងតាម មាត្រា ៩៧៨ ចំណុច១ នៃក្រមរដ្ឋប្បវេណី

រាជធានី ខេត្ត (១)..... ភ្នំពេញ ..........
ក្រុង ស្រុក ខណ្ឌ (២).... ជ្រោយចង្វារ ........
ឃុំ សង្កាត់ (៣)...... បាក់ខែង ........

លេខ (៤)................ ០៥ ............................
សៀវភៅអាពាហ៍ពិពាហ៍លេខ (៥)...០១/២០១៥..
ឆ្នាំ (៦).......... ២០១៥.................................

# បញ្ជីអាពាហ៍ពិពាហ៍

| ព័ត៌មាន ប្តី ប្រពន្ធ | ប្តី | | ប្រពន្ធ | |
|---|---|---|---|---|
| នាមត្រកូល (៧) | សាយ | | អ៊ូ | |
| នាមខ្លួន (៨) | សំអាន | | នួនស្រី | |
| ជាអក្សរឡាតាំង (៩) នាមត្រកូល | SAY | | OU | |
| ជាអក្សរឡាតាំង (៩) នាមខ្លួន | SAM ANN | | NUON SREY | |
| សញ្ជាតិ (១០) | ខ្មែរ | | ខ្មែរ | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៨៣ | | ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៨៦ | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា | | ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | សាស្ត្រាចារ្យ | | គ្រូពេទ្យ | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | | ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| លេខអត្តសញ្ញាណប័ណ្ណ (១៥) | | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៦) | មួយ | | មួយ | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៧) | ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥ | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៨) | សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | | | |
| លេខ និងថ្ងៃ ខែឆ្នាំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (១៩) | ០៥ ប.ខ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ | | | |
| **ព័ត៌មានឪពុក ម្ដាយ** | **ខាងប្តី** | | **ខាងប្រពន្ធ** | |
| នាមត្រកូល និង នាមខ្លួនឪពុក (២០) | សាយ សំអឿន | (២១) សញ្ជាតិ ខ្មែរ | អ៊ូ សែម | (២១) សញ្ជាតិ ខ្មែរ |
| ជាអក្សរឡាតាំង (២២) | SAY SAM OEUN | (២៣) រស់ ឬ ស្លាប់ | OU SEM | (២៣) រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៥៦ | | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥ | |
| មុខរបរបច្ចុប្បន្ន (២៥) | កសិករ | | ជាងសំណង់ | |
| ទីលំនៅបច្ចុប្បន្ន (២៦) | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | | ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២៧) | សែម បុប្ផា | (២៨) សញ្ជាតិ ខ្មែរ | នួន ផល្លា | (២៨) សញ្ជាតិ ខ្មែរ |
| ជាអក្សរឡាតាំង (២៩) | SEM BOPHA | (៣០) រស់ ឬ ស្លាប់ | NUON PHALLA | (៣០) រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣១) | ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៥៨ | | ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០ | |
| មុខរបរបច្ចុប្បន្ន (៣២) | ជាងកាត់ដេរ | | លក់ដូរ | |
| ទីលំនៅបច្ចុប្បន្ន (៣៣) | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | | ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| **ព័ត៌មានសាក្សី** | **សាក្សី** | | **សាក្សី** | |
| នាមត្រកូល និង នាមខ្លួន (៣៤) | សោម មុយ | (៣៥) ភេទ ប្រុស | សេង ភក្តី | (៣៥) ភេទ ស្រី |
| សញ្ជាតិ (៣៦) | ខ្មែរ | | ខ្មែរ | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៧២ | | ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧០ | |
| មុខរបរបច្ចុប្បន្ន (៣៨) | កសិករ | | គ្រូបង្រៀន | |
| ទីលំនៅបច្ចុប្បន្ន (៣៩) | ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | | ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| លេខអត្តសញ្ញាណប័ណ្ណ (៤០) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋដែលមកសុំ ជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។

(៤២) ធ្វើនៅ..... បាក់ខែង ........... ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥

(៤១) **ស្នាមមេដៃស្តាំ**

| ប្តី | ប្រពន្ធ | សាក្សី | សាក្សី |
|---|---|---|---|
| សាយ សំអាន | អ៊ូ នួន ស្រី | សោម មុយ | សេង ភក្តី |

(៤៣) **មន្ត្រីអត្រានុកូលដ្ឋាន**
ចៅសង្កាត់
(៤៤) ហត្ថលេខា និងត្រា
តែ សុទី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ~~ខេត្ត~~ (១) ----- ភ្នំពេញ -----

~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ (២) ----- ជ្រោយចង្វារ -----

~~ឃុំ~~ សង្កាត់ (៣) ----- បាក់ខែង -----

លេខ (៤)------ ០៥ ----------------------

សៀវភៅអាពាហ៍ពិពាហ៍លេខ (៥)-០១/២០១៥

ឆ្នាំ (៦)------- ២០១៥ ----------------------

# សំបុត្រអាពាហ៍ពិពាហ៍

| ព័ត៌មានប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល (៧) | | សាយ | អ៊ូ |
| នាមខ្លួន (៨) | | សំអាន | នួនស្រី |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | OU |
| | នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (១០) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣ | ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩ |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា | ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | សាស្ត្រាចារ្យ | គ្រូពេទ្យ |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥ | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | |
| ព័ត៌មានឪពុក ម្តាយ | | ខាងប្តី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | សាយ សំអឿន | អ៊ូ សែម |
| ជាអក្សរឡាតាំង (១៨) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៩) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦ | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥ |
| នាមត្រកូល និង នាមខ្លួនម្តាយ (២១) | | សែម បុប្ផា | នួន ផល្លា |
| ជាអក្សរឡាតាំង (២២) | | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២៣) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៥៨ | ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០ |

(២៥) ធ្វើនៅ.... បាក់ខែង .... ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥

(២៦) **មន្ត្រីអត្រានុកូលដ្ឋាន**

**ចៅសង្កាត់**

(២៧) ហត្ថលេខា និងត្រា

ណៃ សុទី

# សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (នៅសាលាឃុំ សង្កាត់)

| លេខរៀង | ថ្ងៃខែឆ្នាំ ចេញ សេចក្ដីចម្លង | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | សៀវភៅ | | សំបុត្រ | | ប្ដី ប្រពន្ធ | | | | | អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | | មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃខែឆ្នាំ | នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំ កំណើត | ទីកន្លែងចុះបញ្ជី អាពាហ៍ពិពាហ៍ ឬ បញ្ជាក់អាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំចុះបញ្ជី អាពាហ៍ពិពាហ៍ ឬ បញ្ជាក់អាពាហ៍ពិពាហ៍ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬ បញ្ជាក់អាពាហ៍ពិពាហ៍ | ស្នាមមេដៃស្ដាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្ដីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| 0១ | ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 0១/២០១៥ | ចាក់ខែង | 05 | ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ | សាយ សំអាន<br>អ៊ុំ នួនស្រី | ខ្មែរ<br>ខ្មែរ | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៨៣<br>ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៨៤ | សង្កាត់ចាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | ថ្ងៃសុក្រ ទី២១ ខែ កុម្ភៈ ឆ្នាំ២០១៥ | សាយ សំអាន | ភូមិចាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | សាមីខ្លួន | | ផែ សុខី | ចៅសង្កាត់ | 05 សន្លឹក | |
| | | | | | | | ប្ដី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្ដី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

## សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (នៅសាលាក្រុង ស្រុក ខណ្ឌ)

| លេខរៀង | ថ្ងៃខែឆ្នាំចេញសេចក្តីចម្លង | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | សៀវភៅ | | សំបុត្រ | | ប្តី ប្រពន្ធ | | | | | អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | | មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃខែឆ្នាំ | នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំ កំណើត | ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ស្នាមមេដៃស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្តីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| ០១ | ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ | ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | ០១/២០០៥ | ព្រែក កយ | ១២ | ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ | ទេព សឿង<br>ភួង វណ្ណា | ខ្មែរ<br>ខ្មែរ | ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៤៨<br>ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣ | ឃុំព្រែកកយ ស្រុកស្អាង ខេត្តកណ្ដាល | ថ្ងៃសុក្រ ទី១៥ ខែសីហា ឆ្នាំ២០០៥ | ទេព សឿង | ភូមិសំប៉ាងលើ ឃុំព្រែកកយ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា | សាមីខ្លួន | | គង់ គឹមយ៉ន | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | ០៦ សន្លឹក | |
| | | | | | | | ប្តី...... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្តី...... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត (១) ----- *ភ្នំពេញ*-----
ក្រុង ស្រុក ខណ្ឌ (២) ---- *ជ្រោយចង្វារ*--
ឃុំ សង្កាត់ (៣) ----- *បាក់ខែង* ----

# សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍

| ចម្លងសំបុត្រអាពាហ៍ពិពាហ៍ចេញពី | | (៤) សៀវភៅអាពាហ៍ពិពាហ៍ លេខ ៖--- *០១/២០១៥*------ | (៥) សំបុត្រអាពាហ៍ពិពាហ៍ លេខ *០៥* ចុះថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥* |
|---|---|---|---|
| អំពីប្ដី ប្រពន្ធ | | ប្ដី | ប្រពន្ធ |
| នាមត្រកូល (៦) | | *សាយ* | *អ៊ូ* |
| នាមខ្លួន (៧) | | *សំអាន* | *នួនស្រី* |
| ជាអក្សរឡាតាំង (៨) | នាមត្រកូល | SAY | OU |
| | នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១០) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៨៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៨៥* |
| ទីកន្លែងកំណើត (១១) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១២) | | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥* | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | *សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ* | |
| អំពីឪពុក ម្ដាយ | | ខាងប្ដី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៦) | | *សាយ សំអឿន* | *អ៊ូ សែម* |
| ជាអក្សរឡាតាំង (១៧) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៨) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៥៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២០) | | *សែម បុប្ផា* | *នួន ផល្លា* |
| ជាអក្សរឡាតាំង (២១) | | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២២) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៥៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |

(២៤) ធ្វើនៅ.... *បាក់ខែង* .... ថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**-----
***ចៅសង្កាត់***
(២៦) *ហត្ថលេខា និងត្រា*
*ថៃ សុទី*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត (១) ----- កណ្ដាល -----
ខណ្ឌ ស្រុក ក្រុង (២) ----- ស្អាង -------
ឃុំ សង្កាត់ (៣) -----ព្រែកគយ-------

# សេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

| ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចេញពី | | (៤) សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ លេខ ៖ ០១/២០០៥ | (៥) សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខ១២ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ |
|---|---|---|---|
| អំពីប្ដី ប្រពន្ធ | | ប្ដី | ប្រពន្ធ |
| នាមត្រកូល (៦) | | ទេព | ភួង |
| នាមខ្លួន (៧) | | សឿង | វណ្ណា |
| ជាអក្សរឡាតាំង (៨) | នាមត្រកូល | TEP | PHUONG |
| | នាមខ្លួន | SOEUNG | VANNA |
| សញ្ជាតិ (៩) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១០) | | ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៥៨ | ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣ |
| ទីកន្លែងកំណើត (១១) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | ភូមិកណ្ដាល ឃុំព្រែកល្ពៅ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា | ភូមិសំរោងលើ ឃុំព្រែកអំពិល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា |
| មុខរបរពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១២) | | គ្រូបង្រៀន | ជាងកាត់ដេរ |
| ទីលំនៅពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៣) | | ភូមិទួលស្វាគី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា | ភូមិទួលស្វាគី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៤) | | ថ្ងៃ សុក្រ ទី ១៥ ខែ សីហា ឆ្នាំ ២០០៥ | |
| ទីកន្លែងចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៥) | | ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល | |
| អំពីឪពុក ម្ដាយ | | ខាងប្ដី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៦) | | ទេព សួង | កៅ សៀម |
| ជាអក្សរឡាតាំង (១៧) | | TEP SUONG | KAO SEAM |
| សញ្ជាតិ (១៨) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩២៣ | ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩២២ |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២០) | | ប្រាក់ សម្បត្តិ | សុខ សាន |
| ជាអក្សរឡាតាំង (២១) | | PRAK SAMBATH | SOK SAN |
| សញ្ជាតិ (២២) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩២៥ | ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩២៦ |

លេខ (ក)..... ០៥ ស.ប.អ ............
យើង (ខ).... អភិបាលស្រុកស្អាង ..........................
បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្ដាំនេះ ជាហត្ថលេខា
របស់លោក (គ)...... គុជ្ជ គីមយ៉ន....... ជាមន្ត្រីរក្សាសៀវភៅ
អត្រានុកូលដ្ឋាន (ឃ)...... ស្រុកស្អាង..........ពិតប្រាកដមែន ។
(ង) ធ្វើនៅ...ស្អាង.... ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤
(ច) ហត្ថលេខា និងត្រា
ទឹម ច័ន្ទគីរី

(២៤) ធ្វើនៅ....ស្អាង ..... ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤
(២៥) មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន----
ហត្ថលេខា
គុជ្ជ គីមយ៉ន

របស់អ្នក។ ចៅក្រមម្នាក់នឹងពិនិត្យព័ត៌មានហិរញ្ញវត្ថុរបស់អ្នក ហើយសម្រេចថាតើអ្នកត្រូវនឹងលក្ខខណ្ឌដើម្បីទទួល "ការលើកលែងការបង់ប្រាក់" ដែរឬទេ។ ប្រសិនបើការលើកលែងត្រូវបានបដិសេធ អ្នកត្រូវតែបង់ថ្លៃដាក់ឯកសារក្នុងរយៈពេល 7ថ្ងៃ។ បើសិនអ្នកទទួលបានការលើកលែងអ្នកនឹងមិនចាំបាច់បង់ប្រាក់មួយចំនួន ឬទាំងអស់នោះទេ។

**របាយការណ៍ហិរញ្ញវត្ថុ៖** អ្នកត្រូវតែដាក់របាយការណ៍ហិរញ្ញវត្ថុ (Financial Statement) ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកមិនយល់ស្របចំពោះរបៀបបែងចែកទ្រព្យសម្បត្តិរបស់អ្នក ប្រាក់ឧបត្ថម្ភសហព័ទ្ធ (សោធនអាហារកិច្ច) ឬ ថ្លៃសេវាមេធាវី។ ទម្រង់បែបបទនេះគឺមាននៅលើគេហទំព័ររបស់ផ្នែកយុត្តិធម៌ (Judicial Branch) តាមរយៈ៖ http://courts.maine.gov/fees_forms/forms/index.shtml ឬ មាននៅការិយាល័យរបស់ក្រឡាបញ្ជីតុលាការមណ្ឌលណាមួយ។ បន្ទាប់ពីអ្នកបំពេញរួច សូមដាក់សំណៅដើមទៅក្រឡាបញ្ជី និងផ្ញើសំណៅចម្លងទៅប្តី/ប្រពន្ធរបស់អ្នក។ អ្នកត្រូវតែធ្វើដូច្នេះតាមកាលបរិច្ឆេទដែលបញ្ជាក់នៅក្នុងសេចក្តីបង្គាប់ពីការកំណត់ពេល (Scheduling Order) (សូមមើលជំហានទីបួន)។ ប្តី/ប្រពន្ធរបស់អ្នកក៏ត្រូវតែដាក់ទម្រង់មួយក្នុងចំណោមទម្រង់ទាំងនេះ និងផ្តល់សំណៅចម្លងមួយច្បាប់ដល់អ្នក។

**លិខិតបញ្ជាក់ជំនួសឲ្យរបាយការណ៍ហិរញ្ញវត្ថុ៖** ប្រសិនបើមិនមានវិវាទអំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួន អចលនទ្រព្យ ប្រាក់ឧបត្ថម្ភប្តី/ប្រពន្ធ ឬ ថ្លៃមេធាវីទេនោះ អ្នកគួរតែដាក់លិខិតបញ្ជាក់ជំនួសឲ្យរបាយការណ៍ហិរញ្ញវត្ថុ (Certificate in Lieu of Financial Statement)។ ទម្រង់បែបបទនេះមាននៅលើគេហទំព័រ៖ http://courts.maine.gov/fees_forms/forms/index.shtml ឬ មាននៅការិយាល័យរបស់ក្រឡាបញ្ជីតុលាការមណ្ឌលណាមួយ។ បន្ទាប់ពីអ្នកបំពេញរួច សូមដាក់សំណៅដើមទៅក្រឡាបញ្ជី និងសំណៅចម្លងទៅប្តី/ប្រពន្ធរបស់អ្នក។

**ជំហានទីបួន៖ កំណត់ពេល**

បន្ទាប់ពីប្តី/ប្រពន្ធរបស់អ្នកដាក់ពាក្យផ្តល់ចម្លើយការឆ្លើយតប ឬ ចូលមកបង្ហាញខ្លួន តុលាការនឹងចេញសេចក្តីបង្គាប់កំណត់ពេលដែលកំណត់ពីកាលបរិច្ឆេទសម្រាប់ដាក់ឯកសារនានា និងបញ្ចប់បញ្ហាមុនការជំនុំជំរះផ្សេងៗទៀត។ អ្នកនឹងទទួលបានសំណៅចម្លងនៃសេចក្តីបង្គាប់មួយច្បាប់តាមប៉ុស្តិ៍ប្រៃសណីយ៍។ ការសម្រុះសម្រួលនឹងត្រូវបានកំណត់ពេល ហើយអ្នកនឹងត្រូវបានតម្រូវឲ្យបង់ថ្លៃសេវាសម្រុះសម្រួល ឬ ដាក់សំណើសុំការលើកលែងថ្លៃសេវានេះ។ ការប្រជុំអំពីការគ្រប់គ្រងការជំនុំជម្រះមួយនឹងត្រូវបានកំណត់ពេលបន្ទាប់ពីកាលបរិច្ឆេទនៃការសម្រុះសម្រួល។ (សូមមើលជំហានទីប្រាំ និងទីប្រាំមួយ)។

បើសិនប្តី/ប្រពន្ធរបស់អ្នកមិនដាក់ពាក្យផ្តល់ចម្លើយការឆ្លើយតប ឬ ចូលមកបង្ហាញខ្លួនទេ ក្រឡាបញ្ជីនឹងកំណត់ពេលសំណុំរឿងរបស់អ្នកសម្រាប់សវនាការគ្មានការជំទាស់ (uncontested hearing)។ (សូមមើលជំហានទីប្រាំមួយ)

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកឈានដល់ការព្រមព្រៀងគ្នា អ្នកអាចស្នើសុំឲ្យមានការកំណត់ពេលសវនាការគ្មានការជំទាស់ តាមរយៈការបញ្ជូនលិខិតសំណើទៅកាន់ក្រឡាបញ្ជី។

**ជំហានទីប្រាំ៖ ការសម្រុះសម្រួល**

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកមិនព្រមព្រៀងលើបញ្ហាទាំងអស់ទេ ជំហានបន្ទាប់របស់អ្នកគឺការសម្រុះសម្រួល។ អ្នកនឹងត្រូវបានតម្រូវឲ្យបង់ថ្លៃសេវាសម្រុះសម្រួល ហើយជាទូទៅត្រូវបែងចែករវាងអ្នក និងប្តី/ប្រពន្ធរបស់អ្នក។ ប្រសិនបើអ្នកមិនមានលទ្ធភាពបង់ថ្លៃសេវានេះអ្នកអាចដាក់សំណើសុំលើកលែងបង់ថ្លៃសេវានេះ។ ទម្រង់សំណើសុំនេះគឺមាននៅក្រឡាបញ្ជីតុលាការ។

នៅក្នុងការសម្រុះសម្រួល អ្នកសម្រុះសម្រួលដែលបានទទួលការបណ្តុះបណ្តាលម្នាក់នឹងព្យាយាមជួយអ្នកទាំងពីរឲ្យយល់ពីចំណុចណាដែលអ្នកព្រម និងចំណុចណាដែលអ្នកមិនព្រម។ អ្នកត្រូវតែធ្វើការសម្រុះសម្រួលដោយសុចរិត។ នេះមានន័យថាអ្នកត្រូវតែចូលរួម និងខិតខំព្យាយាមដោយស្មោះត្រង់ក្នុងការដោះស្រាយបញ្ហានៃការខ្វែងគំនិតគ្នា។ ប្រសិនបើបញ្ហានៅតែមិនអាចដោះស្រាយបានបន្ទាប់ពីការសម្រុះសម្រួល អ្នកអាចយល់ព្រមធ្វើការសម្រុះសម្រួលលើកទីពីរ ឬ ដោះស្រាយតាមសវនាការរបស់តុលាការ។

**ជំហានទីប្រាំមួយ៖ ការប្រជុំមុនការជំនុំជម្រះ និងសវនាការតុលាការ**

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកមិនអាចឈានដល់ការព្រមព្រៀងគ្នាតាមការសម្រុះសម្រួលនោះទេ អ្នកនឹងត្រូវមានការប្រជុំអំពីគ្រប់គ្រងការជំនុំជម្រះ/ការប្រជុំមុនការជំនុំជម្រះ (Trial



Management/Pretrial Conference) ដើម្បីកំណត់ថាតើតុលាការត្រូវការពេលវេលាប៉ុន្មានដើម្បីធ្វើសវនការរឿងក្តីរបស់អ្នក។

ប្រសិនបើប្តី/ប្រពន្ធរបស់អ្នកមិនបានដាក់ពាក្យផ្តល់ចម្លើយតបចំពោះពាក្យបណ្តឹងរបស់អ្នក ឬអ្នកយល់ព្រមធ្វើការសម្រុះសម្រួល អ្នកអាចនឹងត្រូវបានកំណត់ពេលសម្រាប់ "សវនាការគ្មានការជំទាស់"។ សវនាការនេះ ត្រូវរៀបចំយ៉ាងយោចណាស់ 60ថ្ងៃ បន្ទាប់ពីប្តី/ប្រពន្ធរបស់អ្នកទទួលបានពាក្យបណ្តឹងសុំលែងលះ។ អ្នកត្រូវតែបំពេញទម្រង់បែបបទបញ្ជាក់អះអាងសហព័ន្ធ (Federal Affidavit) (អាចស្នើសុំបានពីក្រឡាបញ្ជី) និងដាក់ទម្រង់នោះនៅក្រឡាបញ្ជី។ ចៅក្រមនឹងមិនបើកសវនាការសំណុំរឿងរបស់អ្នកនោះទេ រហូតទាល់តែអ្នកដាក់សេចក្តីបញ្ជាក់អះអាងនេះ។ អ្នកត្រូវតែចុះហត្ថលេខាលើសេចក្តីបញ្ជាក់អះអាងនេះនៅចំពោះមុខសារការីសាធារណៈ។ នៅពេលសំណុំរឿងត្រូវបានកំណត់ពេលសម្រាប់សវនាការរួច សូមត្រៀមខ្លួនផ្តល់សក្ខីកម្ម និងផ្តល់ភស្តុតាងដើម្បីគាំទ្រជំហររបស់អ្នក។ បន្ទាប់ពីបើកសវនការសំណុំរឿងរបស់អ្នក ចៅក្រមនឹងសម្រេចពីលក្ខខណ្ឌនៃការលែងលះរបស់អ្នក។

**ប្រភពជំនួយនានា**

**វីដេអូ៖** តុលាការភាគច្រើនមានវីដេអូដែលពន្យល់ពីដំណើរការតុលាការ ព្រមទាំងសិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក។ ប្រសិនបើអ្នកចង់ទស្សនាវីដេអូនេះ សូមទាក់ទងក្រឡាបញ្ជី។

**ការសម្រុះសម្រួល៖** អ្នកសម្រុះសម្រួលអាចនឹងជួយអ្នក និងភាគីម្ខាងទៀតឲ្យឈានដល់ការព្រមព្រៀងគ្នាលើបញ្ហានានាទាក់ទងនឹងរឿងក្តីរបស់អ្នក។ តុលាការមានវីដេអូមួយដែលពន្យល់ថាអ្វីទៅដែលជាការសម្រុះសម្រួល។ ការសម្រុះសម្រួលអាចត្រូវបានរៀបចំឡើងតាមរយៈតុលាការ ឬ អ្នកសម្រុះសម្រួលឯកជន។

សម្រាប់ព័ត៌មានបន្ថែមអំពីប្រភពទាំងនេះ សូមទៅជួបក្រឡាបញ្ជីតុលាការ ឬ ចូលកាន់គេហទំព័រផ្នែកយុត្តិធម៌របស់រដ្ឋ Maine ដែលមានអាសយដ្ឋាន៖ http://courts.maine.gov ។

# ឧបសម្ព័ន្ធទី២ ៖
# នីតិវិធីនៃការដាក់ពាក្យលែងលះនៃ
# អាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀង

*ទម្រង់នេះធ្វើឡើងដោយផ្អែកតាមទម្រង់នៅក្នុងតុលាការគ្រួសារប្រទេសជប៉ុន និងសម្របជាមួយបញ្ញត្តិច្បាប់របស់កម្ពុជា សម្រាប់ធ្វើជាឯកសារយោង។* BAKC-JFBA Seminar, March 15, 2018 (Miha Isoi)

(តម្លៃ ៥០០០រៀល)

**ពាក្យសុំលែងលះតាមការព្រមព្រៀង**

**គោរពជូន**

ប្រធានសាលាដំបូងរាជធានីភ្នំពេញ

អ្នកដាក់ពាក្យសុំ B ៖ ផ្ទះលេខ ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ភាគីម្ខាងទៀត A ៖ ផ្ទះលេខ 34 សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ផ្នែកទី១ ដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ
១. ការលែងលះរវាងអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត

ផ្នែកទី២ មូលហេតុនៃការដាក់ពាក្យសុំ
១. អ្នកដាក់ពាក្យសុំបានរៀបការជាមួយភាគីម្ខាងទៀតនៅថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០០៥ ហើយកូនស្រី C បានកើតនៅថ្ងៃទី ២ ខែមេសាឆ្នាំ ២០០៧ ដែលមានអាយុ ១០ ឆ្នាំ។

២. អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានរស់នៅជាមួយគ្នាអស់រយៈពេល ១២ ឆ្នាំបន្ទាប់ពីរៀបការ។ ក្រោយមក ក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះភាគីម្ខាងទៀតជារឿយៗផឹកស្រា យកលុយទៅផឹកហើយជួនកាលថែមទាំងប្រើអំពើហិង្សាផង។ ដូច្នេះហើយ អ្នកដាក់ពាក្យសុំបានចាកចេញពីផ្ទះរបស់ខ្លួននៅដើមខែធ្នូ ឆ្នាំ 2017 ជាមួយកូនស្រី C ទៅរស់នៅជាមួយឪពុកម្តាយវិញ។ អ្នកដាក់ពាក្យសុំ ចង់លែងលះគ្នាជាមួយភាគីម្ខាងទៀត ។

៣. ភាគីម្ខាងទៀតក៏យល់ព្រមជាមួយអ្នកដាក់ពាក្យសុំដែរ។

៤. កូនស្រី C ចង់រស់នៅជាមួយអ្នកដាក់ពាក្យសុំ ហើយភាគីម្ខាងទៀតក៏យល់ព្រមដែរ។

៥. ភាគីម្ខាងទៀត បានព្រមព្រៀងបង់ប្រាក់ ៦០០.០០០ រៀលនៅរៀងរាល់ចុងខែ ចាប់ពីខែមេសាឆ្នាំ ២០១៨ ដល់ខែមេសា ឆ្នាំ ២០២២ និង ៩០០.០០០ រៀលពីខែឧសភា ឆ្នាំ ២០២២ ដល់ខែមេសា ឆ្នាំ ២០២៥ ទៅឲ្យអ្នកដាក់ពាក្យសុំសម្រាប់ការចំណាយសម្រាប់ការចិញ្ចឹមកូនស្រី C។

៦. ភាគីម្ខាងទៀតបានយល់ព្រមបង់ប្រាក់ចំនួន ៤០ លានរៀលដល់អ្នកដាក់ពាក្យសុំ សម្រាប់ការបែងចែកទ្រព្យសម្បត្តិរួម។

ភ្នំពេញថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០១៨

*ទម្រង់នេះធ្វើឡើងដោយផ្អែកតាមទម្រង់នៅក្នុងតុលាការគ្រួសារប្រទេសជប៉ុន និងសម្របជាមួយបញ្ញត្តិច្បាប់របស់កម្ពុជា សម្រាប់ធ្វើជាឯកសារយោង។* BAKC-JFBA Seminar, March 15, 2018 (Miha Isoi)

(ស្នាមមេដៃ)

អ្នកដាក់ពាក្យសុំ B

(ហត្ថលេខា និង ត្រា)

អ្នកតំណាងនៃអ្នកដាក់ពាក្យសុំ B, មេធាវី D

ការិយាល័យច្បាប់ Orange

ជាន់ទី ២៤, អគារភ្នំពេញ, លេខ ៤៤៥, មហាវិថីព្រះមនីវង្ស, ខណ្ឌ ៧ មករា, រាជធានីភ្នំពេញ,

**ឯកសារភ្ជាប់**

១. សំបុត្រអាពាហ៍ពិពាហ៍

២. សំបុត្រកំណើត C

គំរូ
ពាក្យសុំលែងលះ
ដោយព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន...............................................................។

**ចុងចម្លើយ** ៖ ឈ្មោះ..................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន...............................................................។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូង**.........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖
១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។
២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........
៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។
៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
....................................................................................................
....................................................................................................
៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
....................................................................................................
....................................................................................................
៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)...............................................................................
....................................................................................................
៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)...............................................................................
....................................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។
- ..................................................................................................

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់......................... តាមលិខិតលេខ............ ចុះថ្ងៃទី.................... ។ នៅពេលនេះ យើងខ្ញុំបានអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធនឹងគ្នាទៀតហើយ ។ យើងខ្ញុំបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនិងសម្រេចតាមការស្នើសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី........ ខែ........ ឆ្នាំ២០១.....

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

..................

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)

.....................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូ
ពាក្យសុំលែងលះ
គ្មានការព្រមព្រៀង

## ពាក្យបណ្ដឹងលែងលះ

**ដើមចោទ** ៖ ឈ្មោះ..................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន.............................................................។

**ចុងចម្លើយ** ៖ ឈ្មោះ..................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន.............................................................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូង**.........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖
១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្ដាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។
២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........
៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខ
កូនតាមច្បាប់កំណត់ ។
៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
.............................................................................................................
៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
.............................................................................................................
៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................
៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។
- ...........................................................................................................

កាលពីថ្ងៃទី.....ខែ....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បាចចអាពាហ៍ពិពាហ៍ ជាឈ្មោះ......................... ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) .......................
...........................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្ដឹងសុំខាងលើដោយក្ដីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១......

ស្នាមមេដៃស្ដាំចុងចម្លើយ
(ស្នាមមេដៃស្ដាំ)

ស្នាមមេដៃស្ដាំដើមចោទ
(ស្នាមមេដៃស្ដាំ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

**•ជូនចំពោះ:** **ឯកឧត្តមប្រធានសាលាដំបូងខេត្ត/រាជធានី.........................................**

**•<u>ដើមចោទ:</u>** *ឈ្មោះ.........................ភេទ.....អាយុ.............ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:..................ចុះថ្ងៃទី.................. ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់................ស្រុក/ខណ្ឌ................ខេត្ត/រាជធានី..................លេខទូរស័ព្ទ........................។*

**•<u>អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ:</u>** *លោកមេធាវី.........................................*
*ការិយាល័យស្ថិតនៅអាគារលេខ...........ផ្លូវលេខ.................ឃុំ/សង្កាត់........ ស្រុក/ខណ្ឌ.........................ខេត្ត/រាជធានី.........................................។*

**•<u>ចុងចម្លើយ:</u>** *ឈ្មោះ..............................ភេទ.....អាយុ............ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:........................ចុះថ្ងៃទី.............. ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់................ស្រុក/ខណ្ឌ..................ខេត្ត/រាជធានី..................លេខទូរស័ព្ទ........................។*

**• កម្មវត្ថុ ឬខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ:**
*សូមឲ្យតុលាការសម្រេចនូវសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម:*

១- ________________________________________

២- ________________________________________

**• <u>អង្គហេតុចាំបាច់សម្រាប់បញ្ជាក់ការទាមទារ:</u>**

________________________________________
________________________________________
________________________________________

**•<u>អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗដែលពាក់ព័ន្ធ:</u>**

________________________________________
________________________________________
________________________________________

*អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម* **ឯកឧត្តមប្រធាន** *មេត្តាទទួលនូវពាក្យបណ្តឹង និងចាត់ការតាមនិតិវិធីច្បាប់ ដោយសម្រេចតាមការទាមទារខាងលើ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ/នាងខ្ញុំ។*

*សូម* **ឯកឧត្តមប្រធាន** *មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។*

*រាជធានី/ខេត្ត............. ថ្ងៃទី......ខែ............ឆ្នាំ............*

**ស្នាមមេដៃស្តាំអ្នកប្តឹង**

*សូមភ្ជាប់មកជាមួយ:*

១-...................

CS Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

| | |
|---|---|
| បង្គាប់មកចុងចម្លើយឈ្មោះ ................ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ធិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។ | |
| សញ្ញាណនៃរឿងក្តី (លេខ និងភាគី) | សំណុំរឿងក្តីរដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ................ ចុងចម្លើយ: ................ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ២០២០ វេលាម៉ោង៨:០០ ព្រឹក<br>មន្ទីរសៀបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី |
| ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់) | ១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល ☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់) | |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |
| សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃព្រហស្បតិ៍ ៥ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣<br>ធ្វើនៅរតនគិរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០<br>**ចៅក្រម** | |

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ដីកាកោះ

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី

| | |
|---|---|
| បង្គាប់មកឈ្មោះ: ................ ជាដើមចោទ ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ធិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។ | |
| សញ្ញាណនៃរឿងក្តី (លេខ និងភាគី) | សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៦៤/២០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០២០<br>ដើមចោទឈ្មោះ: ................ ចុងចម្លើយ: ................ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០២០ វេលាម៉ោង៨:០០ ព្រឹក<br>មន្ទីរស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី |
| ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់) | ១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ<br>(សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់) | |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ៣.៩៩៩$ (បីពាន់បួនរយកៅសិបប្រាំបួនដុល្លាអាមេរិក)។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |
| សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃព្រហស្បតិ៍ ៥ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣<br>រតនគិរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០<br>**ចៅក្រម** | |

**បញ្ជាក់**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

*សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង*
*លេខ.........................*

**កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូង**

*បានឃើញមាត្រា១១៣ ដល់មាត្រា១២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស់ឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។*

*សញ្ញាណរឿងក្តី*

*ប្តីងសុំតុលាការអនុវត្តដោយបង្ខំដូចខាងក្រោម*

*១. សុំលែងលះរវាងពីប្តីឈ្មោះ .................... និងប្រពន្ធឈ្មោះ .................... ។*

*២. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន១នាក់ឈ្មោះ .................... ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ .................... ។*

*លោក ................ ប្រធាននិងចៅក្រមសាលាដំបូងខេត្តរតនគិរី*

*លោក .................... ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី*

***អ្នកដាក់ពាក្យសុំឈ្មោះ*** .................... *ភេទស្រី អាយុ២២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ បុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។*

***ភាគីម្ខាងទៀតឈ្មោះ*** ................ *ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ បុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។*

***ឆ្នាំពីរពាន់មួយម្ភៃ ខែឧសភា ថ្ងៃទីប្រាំពីរ វេលាម៉ោងដប់ និងសាមសិបនាទីព្រឹក*** *នៅសាលាដំបូងខេត្តរតនគិរី បានធ្វើនីតិវិធីផ្សះផ្សារដល់គូភាគីដើម្បីឲ្យបានរស់នៅជាប្តីប្រពន្ធនិងគ្នាវិញ ប៉ុន្តែគូភាគីនៅតែមិនអាចរស់នៅជាមួយគ្នាបាន ហេតុនេះតុលាការបញ្ឈប់នីតិវិធីផ្សះផ្សារ ដោយបន្តនីតិវិធីបញ្ជាក់ដំបូងរវាងអ្នកដាក់ពាក្យសុំឈ្មោះ ................ ជាមួយនិងភាគីម្ខាងទៀតឈ្មោះ ............ ។*

*-អ្នកដាក់ពាក្យសុំឈ្មោះ .............................. បានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នៅសាលាសង្កាត់បឹងកន្សែង។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍នាងខ្ញុំមានកូនចំនួន១នាក់ ។ នាងខ្ញុំសុំសិទ្ធគ្រប់គ្រង ចំពោះទ្រព្យសម្បត្តិរួម និងប្រាក់បំណុល នាងខ្ញុំនិងប្តីបានព្រមព្រៀងគ្នារួចរាល់*

អស់ហើយ សុំឲ្យលោកចៅក្រម ទទួលស្គាល់ការព្រមព្រៀងនេះផង មានក្នុងកំណត់ហេតុ ផ្សះផ្សាសម្របសម្រួលលេខ ៦៤/០១,០៤,២០១៩ ។

មកដល់ដំណាក់កាលនេះ នាងខ្ញុំអស់មនោសញ្ចេតនានិងគ្នាហើយ នាងខ្ញុំបានធ្វើកិច្ចព្រមព្រៀងលែងលះ ជាមួយភាគីប្តី បន្ទាប់មកបានដាក់ពាក្យសុំឲ្យតុលាការសម្រេចលែងលះតាមការព្រមព្រៀង និងសុំសិទ្ធិគ្រប់គ្រងកូនចំនួនមួយនាក់។

-ភាគីម្ខាងទៀតឈ្មោះ ................ បានធ្វើសេចក្តីថ្លែងការណ៍តបថា៖ ខ្ញុំបាទឯកភាពតាមសេចក្តីថ្លែងការណ៍របស់ភាគីអ្នកដាក់ពាក្យសុំ ដោយយល់ព្រមលែងលះពីប្រពន្ធឈ្មោះ ...................... និងយល់ព្រមប្រគល់កូនចំនួន១នាក់ឲ្យទៅអ្នកដាក់ពាក្យសុំ។ ចំពោះទ្រព្យសម្បត្តិរួម និងប្រាក់បំណុលរូបខ្ញុំបាទនិងប្រពន្ធបានព្រមព្រៀងគ្នារួចរាល់អស់ហើយ។

រីឯប្រាក់អាហារកិច្ចសុំបង់ជូនក្នុងមួយខែៗ ចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) រហូតដល់កូនធំពេញវ័យ ។

-អ្នកដាក់ពាក្យសុំឈ្មោះ ...................... បានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំឯកភាព ចំពោះសេចក្តីថ្លែងការណ៍របស់ភាគីប្តី ដោយមិនមានសំណូមពរអ្វីទៀតនោះឡើយ។

**យើងបានបញ្ចប់សេចក្តីបញ្ជាក់ដំបូង នៅវេលាម៉ោងដប់មួយ ព្រឹកថ្ងៃខែឆ្នាំដដែល។**

**បានអានកំណត់ហេតុនៃនីតិវិធីនៃសេចក្តីបញ្ជាក់ដំបូងជូនភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ធ្វើយថាត្រឹមត្រូវសូមផ្តិតមេដៃទុកជាភស្តុតាង ។**

| | | | |
|---|---|---|---|
| **អ្នកដាក់ពាក្យសុំ** | **ភាគីម្ខាងទៀត** | **ក្រឡាបញ្ជី** | **ចៅក្រម** |
| ...................... | ...................... | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណីមិនមែន
បណ្តឹងលេខ.................................
ដីកាសម្រេចលេខៈ .............. /២០

## ដីកាសម្រេច

យើង ................. ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

អមដោយលោក .................. ជាក្រឡាបញ្ជី

-បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០១៧ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦។

-បានបញ្ចប់នីតិវិធីបញ្ជាក់ដំបូងនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ៦៤ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០។

**រវាង**

អ្នកដាក់ពាក្យសុំឈ្មោះ .................... ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

**និង**

ភាគីម្ខាងទៀតឈ្មោះ .............. ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

កម្មវត្ថុនៃបណ្តឹង

១. សុំលែងលះរវាងពីប្តីឈ្មោះ .............. និងប្រពន្ធឈ្មោះ .................. ។

២. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន១នាក់ឈ្មោះ .......... ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ .................. ។

បានឃើញកំណត់ហេតុស្តីពីសេចក្តីបញ្ជាក់ដំបូងចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ រវាងអ្នកដាក់ពាក្យសុំឈ្មោះ ..................... និងភាគីម្ខាងទៀតឈ្មោះ ................. ដោយភាគីទាំងពីរស្នើសុំឲ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំរបស់ខ្លួនដោយលែងលះតាមការព្រមព្រៀង។

## យល់ឃើញថា

១-ពាក្យសុំចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់អ្នកដាក់ពាក្យសុំឈ្មោះ ..................... និងភាគីម្ខាងទៀតឈ្មោះ .............. ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២- នៅតំណាក់កាលនៃនីតិវិធីបញ្ជាក់ដំបូង តុលាការបានព្យាយាមធ្វើការផ្សះផ្សាររួចហើយ ប៉ុន្តែគូភាគីនៅតែមិនព្រមសះជានឹងគ្នាវិញទេ ដោយគូភាគីនៅតែស្នើសុំឲ្យតុលាការ សម្រេចលែងលះឲ្យខ្លួនដដែល។ គប្បីតុលាការលើកយកការស្នើសុំរបស់ភាគីទាំងពីរមកពិចារណា។

៣-គូភាគីបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ០៣៧ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ នៅសាលាសង្កាត់ បឹងកន្សែង ក្រុងបានលុង បញ្ជាក់ថា គូភាគីគឺពិតជាមានអាពាហ៍ពិពាហ៍ស្របច្បាប់ប្រាកដមែន។ ដូចនេះដើម្បីចៀសវាងបញ្ហាផ្សេងៗកើតឡើងជាយថាហេតុ គប្បីតុលាការសម្រេចឲ្យលែងលះរវាងគូភាគីតាមការព្រមព្រៀង។

៤-នៅក្នុងនីតិវិធីបញ្ជាក់ដំបូង ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

ក-លែងលះជាប្តី-ប្រពន្ធ

ខ-ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួនមួយនាក់ឈ្មោះ .................. ភេទស្រី កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ឲ្យទៅឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ .................. ជាម្តាយអ្នកគ្រប់គ្រង។

៥- តាមបញ្ញត្តិមាត្រា៤៧ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីកាតព្វកិច្ចរបស់មាតាបិតា ក្នុងការរួមគ្នាចិញ្ចឹមបីបាច់ ថែរក្សាកូនឲ្យក្លាយទៅជាពលរដ្ឋល្អក្នុងសង្គម និងមាត្រា ១០៣៧ ក្រមរដ្ឋប្បវេណី (ការសម្រេចអំពីអ្នកមានអំណាចមេបា) គប្បីគូភាគី រួមគ្នាបំពេញកាតព្វកិច្ចរបស់ខ្លួនតាមបញ្ញត្តិច្បាប់។

៦-ដោយសម្ព័ន្ធភាពជីវិតអាពាហ៍ពិពាហ៍របស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតបានធ្វើឲ្យសហព័ទ្ធម្ខាងៗទទួលរងសម្ពាធផ្លូវចិត្តធ្វើឲ្យផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ។ គប្បីតុលាការលើកយកការស្នើសុំ និងការព្រមព្រៀងគ្នារបស់ភាគីតាមនីតិវិធីបញ្ជាក់ដំបូង មកសម្រេចដោយយោងតាមបញ្ញត្តិមាត្រា៩៧៨ និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៧-ភាគីនៃអាពាហ៍ពិពាហ៍ មានបំណងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ គប្បីតុលាការទទួលយកមកពិចារណា និងសម្រេចតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

៨-ទ្រព្យសម្បត្តិរួមនិងប្រាក់បំណុល នៅក្នុងកំណត់ហេតុនៃនីតិវិធី សេចក្តីបញ្ជាក់ដំបូង ភាគីអ្នកដាក់ពាក្យសុំឈ្មោះ .................... និងភាគីម្ខាងទៀតឈ្មោះ .................. បានបញ្ជាក់ថាខ្លួនបានព្រមព្រៀងគ្នារួចរាល់អស់ហើយ ចំណុចនេះមិនគប្បីតុលាការលើកមកធ្វើការពិចារណានោះឡើយ ។

៩-នៅក្នុងដំណាក់កាលនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតបានឯកភាពគ្នាក្នុងការបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូន ក្នុងមួយខែៗចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) គប្បីតុលាការសម្រេចតាមការព្រមព្រៀង ។

ជាការសន្និដ្ឋាន គប្បីសម្រេចលែងលះរវាងអ្នកដាក់ពាក្យសុំឈ្មោះ .................... និងភាគីម្ខាងទៀតឈ្មោះ ................ តាមពាក្យសុំលែងលះតាមការព្រមព្រៀងរបស់ភាគី ទៅតាមបញ្ញត្តិមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

**ហេតុដូច្នេះសម្រេច**

ក/-ឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................. និងភាគីម្ខាងទៀតឈ្មោះ ............... ផ្តាច់សមគ្គសង្វាសតាមការព្រមព្រៀងរបស់គូភាគី មាត្រា ៧៧៨ និងមាត្រា ៧៧៩ នៃក្រមរដ្ឋប្បវេណី។

ខ/-ប្រគល់សិទ្ធិចិញ្ចឹម បីបាច់ ថែរក្សាកូនចំនួនមួយនាក់ឈ្មោះ .................. ភេទស្រី កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ................... ជាម្តាយជាអ្នកមានអំណាចមេបាតាមមាត្រា ៤៧ រដ្ឋធម្មនុញ្ញ និង មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

គ/-ភាគីដែលមិនបានគ្រប់គ្រង ថែរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូនបានគ្រប់ពេលវេលាតាមមាត្រា ១០៣៨ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។ ភាគីដែលគ្រប់គ្រងថែរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលឲ្យភាគីម្ខាងទៀតបានបំពេញកិច្ចការនេះ។

ឃ/-បង្គាប់មកឈ្មោះ ................ បង់ប្រាក់អាហារកិច្ចចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) សម្រាប់ចិញ្ចឹមកូនរហូតដល់ធំពេញវ័យជូនទៅអ្នកស្រី ជឿន ច័ន្ទលីដា ក្នុងមួយខែៗ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ ។

ង/-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំដែលបានបង់រួច។

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ចៅក្រម**

..............................

**បានឃើញនិងឯកភាព**

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ប្រធានសាលាដំបូង**

បានចម្លងតាមច្បាប់ដើម

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

# ឧបសម្ព័ន្ធទី៣ ៖

# នីតិវិធីនៃការដាក់ពាក្យលែងលះនៃ
# អាពាហ៍ពិពាហ៍ដោយសហព័ទ្ធម្ខាង

## ពាក្យបណ្តឹងសុំលែងលះប្តី ប្រពន្ធ

ៜៜៜៜ

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ពាក្យបណ្តឹង</u>

នាងខ្ញុំឈ្មោះ..................... អាយុ............ឆ្នាំ ជាតិ ............... មុខរបរ...............
ទីលំនៅភូមិ.................. ឃុំ.................. ស្រុក.................. ខេត្ត.................. ។

### សូមគោរពជូន

លោកប្រធានតុលាការក្រុង...................

កម្មវត្ថុ ៖ សុំប្តឹងលែងលះប្តីឈ្មោះ.................. ភេទ......... អាយុ........ឆ្នាំ សញ្ជាតិ.............. មុខរបរ.................. ។

នាងខ្ញុំសូមជំរាបជូនលោកប្រធានតុលាការដូចតទៅ ៖

នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ចំនួន.........ឆ្នាំកន្លងមកហើយ ដូចមានសំបុត្រអាពាហ៍ពិពាហ៍ចុះថ្ងៃទី.........ខែ............ឆ្នាំ..........ធ្វើនៅសង្កាត់ភ្ជាប់មកជាមួយស្រាប់ ។ សព្វថ្ងៃនេះយើងខ្ញុំមានកូនចំនួន.....នាក់ និងមានទ្រព្យសម្បត្តិមួយចំនួន ។

ដោយប្តីរបស់នាងខ្ញុំចេះតែវាយដំលើរូបកាយរបស់នាងខ្ញុំ និងជេរប្រមាថមើលងាយលើញាតិមិត្តបងប្អូនរបស់នាងខ្ញុំ ធ្វើអោយនាងខ្ញុំមិនអាចទ្រាំរស់នៅជាមួយគាត់តទៅទៀតបាន ទើបនាងខ្ញុំសំរេចចិត្តសុំលែងលះគ្នា ចាប់តាំងពីពេលនេះតទៅ ។

ហេតុនេះ សូមលោកប្រធានតុលាការមេត្តាសំរេចចំពោះរឿងនេះអោយបានដាច់ស្រឡះ តាមសំណូមពរ ៖

- សុំផ្តាច់សមត្ថភាពស្វាស

www.budinst.gov.kh www.elibraryofcambodia.org



- សុំកូនចំនួន.....នាក់ ឈ្មោះ.............. និងឈ្មោះ..............
- សុំអោយឈ្មោះ.............. ផ្តល់អាហារកិច្ចដល់កូនចំនួន.....នាក់
- សុំចែកទ្រព្យសម្បត្តិ..............
- ផ្សេងៗ..........

សូមលោកប្រធានមេត្តាទទួលនូវការគោរពយ៉ាងជ្រាលជ្រៅអំពីនាងខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី........ ខែ.......... ឆ្នាំ.........

ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

| | |
|---|---|
| បង្គាប់មកដើមចោទឈ្មោះ ............ ភេទស្រី អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។ មានលេខទូរស័ព្ទ ០៩៧ ៧៦០ ៥៩ ៩៣ | |
| សញ្ញាណនៃរឿងក្តី (លេខ និងភាគី) | សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៧៩ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ដើមចោទឈ្មោះ ............ ចុងចម្លើយ: ............ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៨:០០ នាទីព្រឹក បន្ទប់ស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី |
| ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់) | ១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑ ៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ត្រូវការ) | |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១-ចំពោះគូភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចអង្គហេតុរបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ៣.៤៩៩$ (បីពាន់បួនរយកៅសិបប្រាំបួនដុល្លាអាមេរិក)។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |

សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។

ថ្ងៃ.......................... ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅរតនគិរី, ថ្ងៃទី ............ ខែមិថុនា ឆ្នាំ២០២០
**ចៅក្រម**

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។
-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
លេខ ................./២០

# ដីកាបញ្ជូន

## ផ្ញើជូន
## លោក អធិការនៃអធិការដ្ឋាននគរបាលស្រុកអូរយ៉ាដាវ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | គោលដៅ |
| --- | --- | --- | --- |
| ០១ | -ដីការកោះ ជើងបណ្តឹង<br>ឈ្មោះ ..................... | ០២ ច្បាប់ | ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្តន៍។ |
| ០២ | -ដីការកោះ ចុងចម្លើយ<br>ឈ្មោះ ..................... | ០២ ច្បាប់ | |
| | | | |
| | សរុបចំនួន | ០៤ច្បាប់ | |

ថ្ងៃ............................ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរតនគិរី,ថ្ងៃទី............. ខែមិថុនា ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរ**

**បានទទួល**
ធ្វើនៅរតនគិរី,ថ្ងៃទី.................ខែឧសភា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី
លេខ.........................

## កំណត់ហេតុស្តីពីនីតិវិធីត្រៀម សម្រាប់ការនាយហេតុផល

បានឃើញមាត្រា១០៩,១១០,១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

### សង្ខេបរឿងក្តី

ប្តឹងសុំឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម៖

១. សុំផ្តាច់ នីតិសង្វាសឈប់រួមរស់ជាមួយគ្នា រំលាយសំបុត្រអាពាហ៍ពិពាហ៍ ០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិនៅក្នុងក្រុមហ៊ុន និងទទួលខុសត្រូវលើបំណុលទាំងអស់ ។

៤. ប្រគល់ដីលំនៅដ្ឋានចំនួន ០២កន្លែង និងរថយន្តចំនួន ០១គ្រឿង ជូនទៅភាគីប្តី ។

លោក .................. ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

លោក ........................ ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

ចុងចម្លើយឈ្មោះ ...................... ភេទ ប្រុស អាយុ ៤១ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មុខរបរ មន្ត្រីកងរាជអាវុធហត្ថ លេខទូរស័ព្ទ ០៣១ ៦៦៦ ៦៥ ២៨ ។

**ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងដប់ និងសូន្យ១នាទីព្រឹក** នៅសាលាដំបូងខេត្តរតនគិរី

**ស.ឆ** ចុងចម្លើយ បានឆ្លើយបញ្ជាក់ថា ខ្លួនឯកភាពតាមការលើកឡើងរបស់ដើមបណ្តឹង និងការបញ្ជាក់របស់លោកមេធាវី ដើម្បីបានបញ្ចប់បញ្ហាគ្រួសារតាមច្បាប់ដោយសន្តិវិធី ។

**ស.ឆ** ចំពោះទ្រព្យសម្បត្តិរួម ប្រាក់បំណុល ឯកភាពតាមពាក្យបណ្តឹង ចំពោះកូនមានចំនួន ០២នាក់ ឯកភាពប្រគល់ជូនភាគីប្រពន្ធតាមការស្នើសុំ តែខ្លួនសុំសិទ្ធិទំនាក់ទំនង និងសួរសុខទុក្ខកូន ហេតុនេះ សុំលោក ចៅក្រម ចេញសេចក្តីសម្រេចតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោងដប់ និងសាមសិបនាទីព្រឹក បានអានអោយចុងចម្លើយស្តាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្តិតមេដៃទុកជាភស្តុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **ចុងចម្លើយ**

.......................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
**មន្ទីរស៊ើបសួរ ទី១**

## កំណត់ហេតុស្តីពីនីតិវិធីសាកសួរសាម៉ីភាគី

(មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

| | |
|---|---|
| សញ្ញាណរឿងក្តី | បណ្តឹងលេខ ...... ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២០<br>បណ្តឹងលែងលះជានីតិសង្វាស |
| កាលបរិច្ឆេទ | ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២០<br>វេលាម៉ោងប្រាំបួន និងសូន្យ១នាទីព្រឹក |
| កន្លែងបើក/បិទ | **សាលាដំបូងខេត្តរតនគិរី** |
| ចៅក្រម | លោក ........................ |
| ក្រឡាបញ្ជី | លោក ........................ |
| ភាគីដែលបានបង្ហាញខ្លួន | -ដើមបណ្តឹងឈ្មោះ .................. ភេទស្រី អាយុ ៣៧ ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។<br>-ចុងចម្លើយឈ្មោះ ...................... ភេទប្រុស អាយុ ៤១ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។ |

### សេចក្តីថ្លែងការណ៍របស់ភាគីមានដូចខាងក្រោម៖

**ស.ឆ ៖** ភាគីដើមបណ្តឹង បានឆ្លើយបញ្ជាក់ថា ខ្លួនសុំឲ្យ លោកចៅក្រម ចេញសាលក្រម មានខ្លឹមសារដូចខាងក្រោម៖

១. សុំផ្តាច់នីតិសង្វាសពីភាគីប្តី និងរំលាយសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

- ឈ្មោះ ........................ ភេទ ស្រី អាយុ ១៤ឆ្នាំ
- ឈ្មោះ ........................ ភេទ ប្រុស អាយុ ១១ឆ្នាំ

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិមាន

- គ្រប់គ្រងក្រុមហ៊ុន និងរថយន្តដឹកអ្នកដំណើរគ្រប់សាខាទាំងអស់ ឈ្មោះ រតនសម្បត្តិ
- ប្រព័ន្ធលេខទូរស័ព្ទគ្រប់លេខទាំងអស់ប្រើប្រាស់ក្នុងក្រុមហ៊ុនសព្វថ្ងៃ
- ទទួលរ៉ាប់រងសងបំណុលធនាគារ អេស៊ីលីដា ចំនួន ៤៥ម៉ឺនដុល្លារអាមេរិក

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងរដ្ឋប្បវេណីលេខ ____
ចុះថ្ងៃទី ខែ ឆ្នាំ
**សាលក្រមលេខ:**
ចុះថ្ងៃទី ខែ ឆ្នាំ

*តាងនាមប្រជារាស្ត្រខ្មែរ*
**សាលាដំបូងខេត្តកណ្តាល**
បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់
នៅថ្ងៃទី ខែ ឆ្នាំ
ដោយមានសមាសភាព:
-លោក **ជួន ចន្ថា** ចៅក្រម
-លោក **ឈី អៀង** ក្រឡាបញ្ជី

-ដើមចោទឈ្មោះ ____ ភេទ ____ កើតនៅឆ្នាំ ____ ជនជាតិខ្មែរ មុខរបរកសិ បុគ្គលិកក្រុមហ៊ុន អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

-មានលោក ____ ជាមេធាវីតំណាងដោយអាណត្តិ ។

ចុងចម្លើយឈ្មោះ ____ ភេទ ____ កើតនៅឆ្នាំ ____ ជនជាតិខ្មែរ មុខរប មេផ្ទះ អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

*១-<u>ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:</u>*

១-សុំលែងលះពីប្រពន្ធឈ្មោះ ____ ។

២-សុំសិទ្ធិគ្រប់គ្រងកូន៖

២.១.ឈ្មោះ ____ ភេទ ____ កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

២.២.ឈ្មោះ ____ ភេទ ____ កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៨ ។

៣-បែងចែកទ្រព្យសម្បត្តិរួមមាន:ដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ____ ឃុំ ____ ស្រុក ____ ខេត្ត ____ ជាពីរចំណែកស្មើគ្នា។

*២-<u>ការពន្យល់ត្រួសៗអំពីរឿងក្តី:</u>*

ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ ២០០៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ____ ចុះថ្ងៃទី ____ ខែ ____ ឆ្នាំ ____ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ____ ។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍អ្នកទាំងពីររស់នៅជាមួយគ្នាមានកូនចំនួន ០២នាក់ មានឈ្មោះ ____ ភេទ ____ កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ ____ ភេទ ____ កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៨ ។

ប៉ុន្តែក្រោយពេលដែល មានកូន ០២ នាក់ អ្នកទាំងពីរតែងតែមានភាពរកាំរកូសជាមួយគ្នាជាញឹកញាប់ ការរស់នៅមិនចុះសម្រុងគ្នា និងបានបែកលំនៅសង្វាសអស់មួយរយៈមកហើយ ជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តី ប្រពន្ធតទៅមុខទៀត។ ហើយក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការ ។

៣-*ការអះអាងរបស់ភាគី*:

-ដើមចោទឈ្មោះ ................ បានអះអាងថា: ខ្លួនប្តឹងសុំឲ្យតុលាការចេញសាលក្រម ដូចការទាមទារខាងលើ ដោយហេតុថា ខ្លួនបានរៀបការជាមួយឈ្មោះ ............ កាលពីថ្ងៃទី ខែ ឆ្នាំ និងបានទៅចុះ សំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ ។ ការរួមរស់នៅជាមួយគ្នាមានកូនចំនួន ០២ នាក់ គឺឈ្មោះ .............. ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ .................. ភេទប្រុស កើតថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៨។ ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ........... ឃុំ ............ ស្រុក ........... ខេត្ត ........... ដែលមានលិខិតលក់ទិញចុះថ្ងៃទី ០៩.០២.២០១២ និងបានឃេញនឯបញ្ជាក់លេខ:០១៨/១២ ចុះថ្ងៃទី ខែ ឆ្នាំ របស់មេឃុំអូរបាក់រទេះ និងផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ...... ............... ចុះថ្ងៃទី .... ខែ ..... ឆ្នាំ ..... ដែលកំពុងបង់រំលោះនៅធនាគារបានចំនួន ១០ខែ ស្មើទឹកប្រាក់ចំនួន .......................... ដុល្លាអាមេរិក និងមានគ្រឿងអល័ង្កាសរុបស្មើទឹកប្រាក់ចំនួន ...................... ដុល្លាអាមេរិក សូមបញ្ជាក់ថា ពួកខ្លួនពុំមានជំពាក់បំណុលគេទេ ហើយដីខាងលើក៏ពុំមានជាប់ពាក់ព័ន្ធនឹងការធានាបំណុលគេដែរ ។

-ចុងចម្លើយឈ្មោះ .......... បានចូលមកធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្លួនឯកភាពក្នុងការលែងលះ សុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ សុំប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងពីតនាក់ក្នុងមួយខែចំនួន ៣០០$(បីរយ) ក្នុងករណីកូនទាំងពីរនាក់រស់នៅជាមួយខ្លួន និងទទួលស្គាល់ថាមានទ្រព្យសម្បត្តិរួមដូចការលើកឡើងរបស់ដើមចោទប្រាកដមែន។

ក្រោយការផ្សះផ្សាសម្រុះសម្រួលរួចមកគូរភាគីបានឯកភាពគ្នាដូចខាងក្រម៖

-ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ........... ឃុំអូរ ........... ស្រុក ............. ខេត្ត .............. ដែលមានលិខិតលក់ទិញចុះថ្ងៃទី ...................... និងបានឃើញនិងបញ្ជាក់លេខ: ........ ចុះថ្ងៃទី .... ខែ ... ឆ្នាំ ...... របស់មេឃុំ ............ នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .......................... ....... ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ..... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់រពហារកិច្ចចិញ្ចឹមកូន។

-កូនទីមួយឈ្មោះ ...................... ភេទប្រុស និងកូនទីពីរឈ្មោះ ........................ ភេទប្រុស ទុកសិទ្ធិឲ្យកូនគាត់ស្រេចចិត្តដោយខ្លួនគាត់។

-មេធាវីការពារសិទ្ធិដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-មេធាវីការពារសិទ្ធិចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-*<u>ចំណុចវិវាទ:</u>* ការលែងលះ និងសិទ្ធិគ្រប់គ្រងកូន។

៥-*<u>ចំណុចគ្មានវិវាទ</u>*: ឯកភាពលើការបែងចែកទ្រព្យសម្បត្តិរួម។

## សំអាងហេតុ

១-តាមការអះអាងរបស់គូភាគីឃើញថា ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីកាលពីថ្ងៃទី ... ខែ ... ឆ្នាំ ... និងបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ... ។ ដូច្នេះឃើញថា ដើមចោទ និងចុងចម្លើយ បានបំពេញករណីយកិច្ចជាប្តីប្រពន្ធស្របច្បាប់ ចំពោះការទាមទារសុំលែងលះនេះតុលាការអាចពិចារណាសម្រេចបាន។ តុលាការបានសាកល្បងធ្វើការផ្សះផ្សាគូភាគីរួចហើយ ប៉ុន្តែគូភាគីនៅតែទាមទារលែងលះគ្នា ដោយសារអស់មនោសញ្ចេតនា អាណិតស្រលាញ់គ្នាជាប្តីប្រពន្ធទៀតហើយ ។

២-នៅក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីមានកូនចំនួន ០២នាក់មាន ៖

.ឈ្មោះ ... ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

.ឈ្មោះ ... ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-ទ្រព្យសម្បត្តិរួមមាន៖

-ទ្រព្យសម្បត្តិរួមចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ... ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ... ឃុំ ... ស្រុក ... ខេត្ត ... ដែលមានលិខិតលក់ទិញចុះថ្ងៃទី ... និងបានឃើញនិងបញ្ជាក់លេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ របស់មេឃុំ ... នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់អាហារកិច្ចចិញ្ចឹមកូន។

គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-កូនទីមួយឈ្មោះ ... ភេទប្រុស បានសុំរស់នៅជាមួយម្តាយ និងកូនទីពីរឈ្មោះ ... ភេទប្រុស បានសុំរស់នៅជាមួយឪពុក គប្បីតុលាការសម្រេចតាមការណ៍ស្នើរសុំ។

យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ យោងតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នាមានសិទ្ធិ

ចូលចូប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន" ។

៥-ចំពោះប្រាក់ប្រដាប់ក្តីតុលាការគប្បីឲ្យដើមចោទ និងចុងចម្លើយ ទទួលបន្ទុកម្នាក់ពាក់កណ្តាល (មាត្រា ៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី )។

## សេចក្តីសម្រេចបញ្ចប់

១-ឲ្យដើមចោទឈ្មោះ ………… លែងលះពីចុងចម្លើយឈ្មោះ ………… ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

២-ប្រគល់សិទ្ធិអំណាចមេបាឲ្យទៅ៖

២.១.ដើមចោទឈ្មោះ ………… លើកូនឈ្មោះ ………… ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

២.២.ចុងចម្លើយឈ្មោះ ………… លើកូនឈ្មោះ ………… ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

ទុកសិទ្ធិឲ្យភាគីដែលមិនបានទទួលសិទ្ធិអំណាចមេបាទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូន និងផ្តល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៣-ប្រគល់ទ្រព្យសម្បត្តិរួមមាន៖

៣.១-ដីទំហំ ………… ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ………… ឃុំ ………… ស្រុក ………… ខេត្ត ………… ដែលមានលិខិតលក់ទិញចុះថ្ងៃទី ………… និងបានឃើញនិងបញ្ជាក់លេខ: ………… ចុះថ្ងៃទី … ខែ ឆ្នាំ ………… របស់មេឃុំ ………… ប្រគល់ឲ្យកូនទាំងពីរនាក់គ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូរភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

៣.២-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

៣.៣-ផ្ទះមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ………… ………… ចុះថ្ងៃទី … ខែ …… ឆ្នាំ …… ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និង ត្រា **ជួន ឧណ្ណារ:**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣

ធ្វើនៅខេត្តកណ្តាល,ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
លេខ: ...... /២០២០

## លិខិតបញ្ជាក់សាលក្រមស្ថាពរ

យើង **ឃី អៀង** ក្រឡាបញ្ជីនៃសាលដំបូងខេត្តកណ្ដាល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ...... ចុះថ្ងៃទី ...... ខែ ... ឆ្នាំ ...... របស់សាលាដំបូងខេត្តកណ្ដាល។

បានឃើញ សាលក្រមលេខ: ...... ចុះថ្ងៃថ្ងៃទី ... ខែ ... ឆ្នាំ ...... របស់សាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ពាក្យសុំបញ្ជាក់ការចូលជាសាលក្រមស្ថាពរនៃសាលក្រម ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ...... របស់មេធាវីឈ្មោះ ............ ជាមេធាវីតំណាងដោយអាណត្តិរបស់ឲ្យចុងចម្លើយ។

សូមបញ្ជាក់ថា សាលក្រមលេខ: ...... ចុះថ្ងៃទី ... ខែ ឆ្នាំ ...... របស់សាលាដំបូងខេត្តកណ្ដាល បានចូលជាស្ថាពរពីថ្ងៃទី ...... ខែ ... ឆ្នាំ ...... តទៅហើយដោយភាគីពុំបានប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

យើងចេញលិខិតបញ្ជាក់នេះ ដើម្បីអនុញ្ញាតឲ្យដាក់របមន្តអនុវត្តលើសាលក្រមនេះ សម្រាប់ភាគីសុំយកទៅអនុវត្តតាមច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣
ខេត្តកណ្ដាល , ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០
**ក្រឡាបញ្ជី**

ឃី . អៀង

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

លេខ: /២០២០

## រូបមន្តអនុវត្តសាលក្រម

យើង **ឃី អៀង** ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល ។

បានឃើញ មាត្រា ៣៥៤,៣៥៥ និងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ លិខិតបញ្ជាក់សាលក្រមស្ថាពរលេខ: ចុះថ្ងៃទី ... ខែ ...... ឆ្នាំ របស់ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល ។

បានឃើញ ពាក្យសុំចុះថ្ងៃទី ... ខែ ...... ឆ្នាំ ...... របស់អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយឈ្មោះ .............. ។

**សូមបញ្ជាក់ពីខ្លឹមសារអនុវត្តដូចខាងក្រោម:**

-ម្ចាស់បំណុល នៃការអនុវត្តឈ្មោះ .............. ភេទ ... កើតនៅឆ្នាំ ...... អាសយដ្ឋានផ្ទះលេខ៦២E0 ផ្លូវលេខ២(បុរីភិភពថ្មី) ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

-កូនបំណុលនៃការអនុវត្តឈ្មោះ ........ ភេទ ... កើតនៅឆ្នាំ ...... អាសយដ្ឋានផ្ទះលេខ៦២E0 ផ្លូវលេខ២(បុរីភិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

-អនុវត្តតាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ: ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ..... របស់សាលាដំបូងខេត្តកណ្តាល ដែលបានចូលជាស្ថាពរពីថ្ងៃទី ... ខែ ... ឆ្នាំ ....... គ្រប់ចំណុចទាំងមូលនៃសាលក្រម។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលក្រម ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍ អនុវត្តសាលក្រមនេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។*

ថ្ងៃព្រហស្បតិ៍ ០១ ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ខេត្តកណ្តាល, ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

ឃី . អៀង